ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jan-2017, 08:30
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពិរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៤៥៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

លោកស្រី ស្តាវរ៉ូឡា ប៉ាប៉ាដូប៉ូឡូស
*(Ms. Stavroula PAPADOPOULOS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោកស្រី ដូរីន ជិន *(Ms. Doreen CHEN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD*

លោក ឡៅ ជុនធី

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ុនណា

លោកស្រី ជេត វណ្ណលី

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោកស្រី ដូរីន ជិន | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោក នឹម អ៊ឹម (2-TCW-854) | ខ្មែរ |
| លោកស្រី មុំ រុន (2-TCCP-283) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក នឹម អ៊ឹម** (2-TCW-854)

សួរបន្តដោយលោក ឌេល លីសាក់ ផ្តើមពី ........................................ ទំព័រ ៣
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........................................ ទំព័រ ១៦
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........................................ ទំព័រ ១៧
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី........................................ ទំព័រ ២៧

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ÷ លោកស្រី មុំ ខុន** (2-TCCP-283)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ៣០
សួរដោយលោកស្រី ជេត វណ្ណលី ផ្តើមពី........................................ ទំព័រ ៣២
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........................................ ទំព័រ ៥២
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី........................................ ទំព័រ ៥៤
សួរដោយលោក លីវ សុវណ្ណា ផ្តើមពី ........................................ ទំព័រ ៧២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:២៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី នឹម អ៊ឹម បន្តបញ្ចប់ និងចាប់ផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-283 ពាក់ព័ន្ធនឹងអង្គហេតុបទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍។

ក្រឡាបញ្ជីសវនាការកញ្ញា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលទាំងឡាយ ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។ សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែលោកមេធាវី ពេជ អង្គ មេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជូនដំណឹងមកថា នឹងអវត្តមាននៅសវនាការថ្ងៃនេះ ដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក នឹម អ៊ឹម លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ទៀតនៅថ្ងៃនេះ មានរហស្សនាម 2-TCCP-283។ សូមអរគុណលោកប្រធាន។

[០៩:០៣:៥៩]

**ប្រធានអង្គជំនុំ៖**

អរគុណកញ្ញា ស៊ីវហ័ង។ អរគុណកញ្ញា ស៊ីវហ័ង។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួម

សវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឱ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងដោយមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០១៦។

មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះ មានអាការៈឈឺចង្កេះ អង្គុយយូរកាន់តែឈឺខ្លាំង និងបានផ្ដល់អនុសាសន៍ សូមឱ្យអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៥:២២]

ផ្អែកលើមូលដ្ឋាននេះ និង យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាដល់សហព្រះរាជអាជ្ញា បន្តសំណួរទៅសាក្សីនេះ។ អង្គជំនុំជម្រះសូមរំឭកដល់ព្រះរាជអាជ្ញាថា លោកព្រះរាជអាជ្ញាបានប្រើពេលអស់៧៤នាទីហើយ នៅសល់៥០នាទីទៀត សម្រាប់ពីរក្រុមរបស់លោក។ សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបលោកសួរមេធាវី សូមជម្រាបសួរលោកសាក្សី។

[០៩:០៦:៣០]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ខេល លីសាក់៖**

**ស៖** កាលពីម្សិលមិញយើងបាននិយាយអំពី ញ៉ែម អេន តើ ញ៉ែម អេន ហ្នឹងគាត់បានមកធ្វើការ និងរស់នៅក្នុងមន្ទីរស-២១ដែរឬទេ មុនពេលដែលគេចាត់តាំងគាត់ឲ្យចូលមកក្នុងកងយុវជនខាងថតរូបហ្នឹង?

**លោក នឹម អ៊ុំ៖**

**ឆ៖** ចំពោះ ញ៉ែម អេន ខ្ញុំអត់បានដឹងដែរ ព្រោះកាលហ្នឹង ដល់ពេលបញ្ជូនមកឲ្យរៀន បានខ្ញុំដឹង។ តែមិនដឹងគាត់នៅអង្គភាពណា មួយអ្នកណាដែរទេណា ព្រោះខ្ញុំដឹងតែពេលគាត់យក គាត់បញ្ជូនមកឲ្យខ្ញុំបង្រៀន។

**ស៖** ឥឡូវនេះខ្ញុំនឹងលើកយកឯកសារ E3/7618, <E3/7618> ខ្មែរមានលេខ 00164437, អង់គ្លេសមានលេខ 00164441 និងបារាំងមានលេខ 00164445។ គេបានសួរលោកនូវសំណួរដូចតទៅនេះ៖ "តើ ញ៉ែម អេន មក<រស់នៅជាមួយលោកនៅ>ឆ្នាំណា? លោកឆ្លើយថា៖ គាត់មកធ្វើការជាមួយខ្ញុំប្រហែលជាពាក់កណ្ដាលឆ្នាំ៧៨ គឺប្រហែល៦ខែមុនពេលបែកភ្នំពេញឆ្នាំ១៩៧៩។ មុនពេលមកធ្វើការកន្លែងថតរូប តើញ៉ែម អេន នៅកន្លែងណា? លោកឆ្លើយថា៖ ពីមុនគាត់នៅក្រុមកុមារ នៅជាមួយ ឌុច។" ដូច្នេះខ្ញុំចង់សួរថា ហេតុអ្វីបានជាលោកឆ្លើយថា មុនពេលដែល ញ៉ែម អេន មកធ្វើការជាមួយលោកហ្នឹង គឺគាត់នៅក្នុងក្រុមកុមារ នៅជាមួយ ឌុច?

[០៩:០៨:៣៧]

**ឆ៖** ព្រោះកុមារ មិនដឹងឯណា ប៉ុន្តែគ្រាន់តែថា បើគាត់ៗ ឃើញថាមកដល់កន្លែងខ្ញុំហើយបានខ្ញុំដឹងថា តាឌុច បញ្ជូនមកទេ ប៉ុន្តែអារឿងថាឲ្យខ្ញុំដឹងនៅកន្លែងណា កន្លែងណា ក៏ខ្ញុំអត់ដឹង។

**ស៖** លោកនិយាយថា គឺមានកុមារពីរបីនាក់ទៀតដែលលោកបង្រៀនក្រៅពី ញ៉ែម អេន នុ៎ងតើលោកចាំឈ្មោះទេ គឺឈ្មោះក្មេងៗពីរបីនាក់ទៀត ដែលគេចាត់តាំងឲ្យមករៀនជាមួយលោក គឺមក

រៀនជាមួយ ញ៉ែម អេន នោះ<មានឈ្មោះអីដែរ>?

**ឆ៖** ក៏អត់បានចាំ ប៉ុន្តែគ្រាន់ថា ដឹងថាម្នាក់ដែលទៅជាមួយខ្ញុំ រត់ឡើងភ្នំ គឺគាត់ស្លាប់នៅក្នុងលើភ្នំទៅ វ៉ៃទល់ជាមួយយៀកណាមហ្នឹង។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាមួយអ្នកស៊ើបអង្កេត គឺឯកសារE3/7639 លោកបាននិយាយ<ដូចគ្នាដែរ គឺលោកចាំតែ> ញ៉ែម អេន <មួយទេ។> ហើយលោកនិយាយថា៖ "ក្រៅពីគាត់គឺខ្ញុំភ្លេចឈ្មោះក្មេងៗផ្សេងទៀត" ដូច្នេះខ្ញុំចង់ដឹងថា ហេតុអ្វីបានជាលោកភ្លេចឈ្មោះក្មេងៗផ្សេងៗទៀត ប៉ុន្តែលោកចាំតែឈ្មោះរបស់ ញ៉ែម អេន ទៅវិញ? ខ្ញុំចង់ដឹងថាហេតុអីបានជាគាត់ -- ហេតុអីបានជាលោកចាំតែ ញ៉ែម អេន ចំណែកក្មេងៗផ្សេងៗទៀតលោកអត់ចាំ?

**ឆ៖** ព្រោះកាលនុ៎ងរយៈពេលខ្លីពេក តែ ញ៉ែម អេន កន្លែងខ្ញុំធ្លាប់ឮឈ្មោះ ឮសួរតាមមកប៉ុស្ដិ៍អាស៊ីសេរីទេ ដែលថាជាងថតស-២១នោះ បានខ្ញុំចាំ នឹកឃើញៗ ញ៉ែម អេន មួយទៅ។ តែក្រៅពីនោះខ្ញុំអត់ចាំទាំងអស់ ព្រោះវាៗនៅជាមួយខ្ញុំរយៈពេលខ្លីពេក។

[០៩:១០:៥៤]

**ស៖** អ៊ីចឹងបានន័យថា នៅពេលដែលលោកឮឈ្មោះ ញ៉ែម អេន ដំបូងហ្នឹងគឺលោកឮ នឹកឃើញឈ្មោះហ្នឹង ដោយសារនៅពេលដែលគាត់និយាយនៅក្នុងវិទ្យុ គឺនៅក្រោយរបបខ្មែរក្រហមទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ហ្នឹងខ្ញុំឮតាមហ្នឹង បានខ្ញុំនឹកឃើញឈ្មោះហ្នឹងវិញ។

**ស៖** ឥឡូវនេះខ្ញុំនឹងលើកនូវប្រធានបទថ្មីមួយទៀត កាលពីម្សិលមិញលោកនិយាយអំពីក្មេងៗដែលជាប់គុកនៅស-២១ ជាមួយម្ដាយរបស់ពួកគេ។ គឺដូច្នេះខ្ញុំចង់ដឹងតើមានអ្នកទោសជាមនុស្សចាស់ជរាដែលគេយកមកដាក់ស-២១ ហើយលោកថតរូបដែរឬទេ?

**ឆ៖** មានអ្នកចាស់ជរា ប៉ុន្តែខ្ញុំអត់បានចាំឈ្មោះអីៗទេ ប៉ុន្តែគ្រាន់ថាគាត់ហ្នឹងអាយុប្រហែលខ្ទង់៧០ ហើយឃើញម្នាក់ដែលខ្ញុំបានថត ប៉ុន--។

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតផ្ដល់នូវរូបថតមួយចំនួនទៀត ជូនទៅដល់សាក្សី ហើយនៅពេលដែលផ្ដល់ហើយហ្នឹង គឺខ្ញុំនឹងផ្ដល់នូវលេខឯកសារយោង។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកឯកសារនេះជូនសាក្សី។

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

[០៩:១២:៣៧]

**លោក ខេល លីសាក់៖**

ដើម្បីជាកំណត់ត្រាប្រតិចារឹក រូបថតដែលខ្ញុំប្រគល់ជូនទៅសាក្សីហ្នឹងគឺ រូបថតលេខ៧៩១ នៅក្នុងបណ្ដុំរូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ E3/9837 នៅត្រង់លេខ P01223809។ ហើយរូបថតបួនផ្សេងទៀតគឺឯកសារ E3/8639 គឺ E3/8639.5110, .2484, <.1975,> .3668 និង .4034។ ដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធានផងដែរ ដើម្បីដាក់បង្ហាញនៅលើអេក្រង់ ហើយខ្ញុំនឹងសួរពួកគាត់។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីសោតទស្សន៍បង្ហាញឯកសារនេះនៅលើអេក្រង់ទូរទស្សន៍។

**លោក ខេល លីសាក់៖**

រូបថតទី១ដែលខ្ញុំផ្ដល់ឲ្យលោកហ្នឹង គឺជាឯកសារដែលមានរូបលេខ៧៩១ ហើយគាត់មានលេខសម្គាល់គឺមានឈ្មោះ យាយសំ កាលបរិច្ឆេទគឺ២៨ មីនា ៧៨។ លោក លោកស្រីចៅក្រមគឺគាត់មាននៅក្នុងបញ្ជីរបស់ ក.ស.ច.ស គឺ<៨៨៥៥>។ គាត់កំណត់ថា បានគេកំណត់អត្តសញ្ញាណថាជាមនុស្សចាស់មានអាយុ<៧១>ឆ្នាំ មកពីពាយ័ព្យ។ រូបថតបន្ទាប់គឺ5110 សូមអនុញ្ញាតបង្ហាញផងដែរគឺ5110។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីសោតទស្សន៍ដាក់បង្ហាញរូបថតនេះនៅលើអេក្រង់។

[០៩:១៥:១៥]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** រូបថតបន្ទាប់គឺជាលេខ E3/8639.5110 <ស្ត្រី>ដែលមានស្លាកសញ្ញាថ្ងៃ១៨ មករា ៧៨ ដែលត្រូវគ្នានឹងបញ្ជីរបស់ ក.ស.ច.ស លេខ៨០៤២ គឺបញ្ជីស-២១ របស់ ក.ស.ច.ស លេខ៨០៤២ គឺឈ្មោះបួយ ជាស្ត្រីធ្វើការនៅខាងស្ពានីយរថភ្លើង។ ហើយខ្ញុំបង្ហាញនូវរូបថតបន្ទាប់នៅក្នុងឯកសារនេះដែរ គឺ .2484។ រូបថតបន្ទាប់មកទៀតគឺលេខ .1975 ហើយ .3668។ រូបថតនេះគឺជារូបថតលេខ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<2484> ហើយសូមបង្ហាញបន្ទាប់មួយទៀតគឺ1975។

សូមអរគុណ គឺរូបថតនៅលើអេក្រង់នេះហើយ គឺE3/8639.3668 លោកសាក្សី តើលោក <ស្គាល់ថា>រូបថតរបស់អ្នកទោសទាំងនេះ<ត្រូវបាន>គេថតនៅ ស-២១ ទេ?

**លោក នឹម អ៊ឹម៖**

**ឆ៖** បាទ ចាំបានៗ ព្រោះអាហ្នឹងចុង វាចុងក្រោយហើយ ជិតៗនេះហើយណ៎ា នៅក្នុងខ្ទង់ចិត ជាង ៧៨អីហើយ។

**ស៖** តើលោកចាំទេថា គេមានអនុវត្តអី -- គេអនុវត្តលក្ខណៈផ្សេងចំពោះ<>អ្នកទោសចាស់ៗ នៅស-២១ទេ? <តើមានអាគារផ្សេងគ្នាទេ កន្លែងឃុំឃាំងហ្នឹង?> ថាតើគេប្រព្រឹត្តផ្សេងចំពោះមនុស្ស ចាស់ ឬក៏ប្រព្រឹត្តដូចគ្នាទេមនុស្សចាស់ ឬក៏អ្នកនៅក្មេងជាដើម?

**ឆ៖** ព្រោះអានេះខ្ញុំអត់បានដឹងដែរ ប៉ុន្តែវាគ្រាន់តែចូលគុកចូលដូចគ្នា តែរឿងអនុវត្តអីផ្សេង ខ្ញុំ អត់បានដឹងទេណ៎ា ព្រោះខ្ញុំដឹងតែថត ហើយចូលមកកន្លែងខ្ញុំវិញ។

[០៩:១៨:៣៣]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំនឹងនិយាយអំពីបញ្ហាមួយចំនួនដែលលោកបាន ជជែកជាមួយមេធាវីការពារក្តីកាលពីម្សិលមិញ គឺការនិយាយអំពីការថតអ្នកទោសដែលគេបញ្ជូនទៅ ព្រៃស។ ប្រសិនបើខ្ញុំយល់មិនខុសទេ គឺថាលោកបាននិយាយអំពីស្ថានភាពខ្លះដែលថា លោកត្រូវត្រឡប់ ទៅថតរូបឡើងវិញ អ្នកទោស គឺថាក្នុងករណីដែលហ្វីលហ្នឹងវាខូច ហើយលោកមិនអាចប្រើហ្វីលហ្នឹង ដើម្បីផ្តិតរូបថតអ្នកទោសហ្នឹង តើអីចឹងមែនទេ?

**ឆ៖** បាទ វាពិតមែន ព្រោះតែខូចហើយ បើភ្លាមៗអីចឹងយើងត្រូវស្នើទៅដល់ តាឌុច បានខ្ញុំបាន ទៅថតទៅអ្នកព្រៃសណោះ កន្លែងធ្វើស្រូវ ធ្វើបន្លែ ធ្វើដំណាំងណោះ។

**ស៖** ខ្ញុំយល់មិនច្បាស់ចំណុចមួយ ហើយខ្ញុំចង់ឲ្យលោកបញ្ជាក់ផងដែរ។ ប្រសិនបើហ្វីលហ្នឹង វាខូច បានន័យថា កាលណាវាខូចហើយលោកមិនអាចមើលឃើញរូប មិនអាចអីទាំងអស់នោះទេ។ ដូច្នេះខ្ញុំចង់ដឹងថាតើលោកធ្វើយ៉ាងម៉េចដើម្បីឲ្យដឹងថា តើត្រូវថតរូបអ្នកណា ព្រោះហ្វីលនោះវាខូចទៅ ហើយ យើងមិនអាចមើលឃើញរូបអីទេ?

**ឆ៖** ព្រោះបានដឹងថាខូច យើងចំណាំថតលើកទី១ ទី១ពីណា ទី២ពីណាហ្នឹង ដល់ពេលយើង លាង យើងចូលស្ទីលទៅ វាប៉ះគ្នា ប៉ះគ្នាដល់យើងលាងទៅ វាជិតប៉ុន្មាននាក់ហ្នឹង យើងដឹងថា អូ! អ្នក

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នេះនៅនេះ ទៅតែសួរ ធីៗ គេប្រាប់ហើយ។

**ស៖** ប៉ុន្តែខ្ញុំចង់ដឹងថា លោកធ្វើម៉េចបានដឹងឈ្មោះមនុស្សដែលរូបហ្នឹងគាត់ខូចហ្នឹង? តើលោកមានកត់បញ្ជីឈ្មោះអ្នកទោស ឬក៏មានតារាងអ្នកទោស? ឧទាហរណ៍ថាឈ្មោះនេះត្រូវនឹងលេខនេះជាដើម អីជាដើមហ្នឹង ដូច្នេះចង់ដឹងថានៅពេលដែលហ្វីលវាខូចហើយ លោកមើលអីអត់ឃើញទេ ប៉ុន្តែខ្ញុំចង់ដឹងថាធ្វើម៉េចលោកអាចដឹងថា-- អ៎! ហ្វីលដែលខូចហ្នឹងឈ្មោះអ្នកទោសនេះ អ្នកទោសនោះអីចឹង?

[០៩:២១:០៥]

**ឆ៖** ព្រោះអាចខ្ញុំដឹង ព្រោះយើងថតទៅ យើងដឹងខូចប៉ុន្មាននាក់ ថាខូចពីរប្រឡោះអីចឹង យើងយកអាថតរូបថតហ្នឹងយកទៅឱ្យ ធី ពិនិត្យមើលថាឈ្មោះអីបាត់ ធី គេប្រាប់ហើយ។

**ស៖** អីចឹងគឺ សួស ធី ជាអ្នកប្រាប់ឈ្មោះអ្នកទោសដែលត្រូវថតឡើងវិញ តើអីចឹងមែនទេ?

**ឆ៖** យករូបថតទៅឱ្យគាត់ ៗពិនិត្យមើលហើយ ឈ្មោះណា ឈ្មោះណា។ ដល់ហើយយើងយករូបថតផ្ទៀងទៅ វាបាត់ឈ្មោះណាក្នុងចំណោមមក ៗប្រាំនាក់ បាត់ពីរទៅ យើងដឹងហើយ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកទៅព្រៃស ខ្ញុំចង់ដឹងថាតើលោកទៅព្រៃសហ្នឹងតាមមធ្យោបាយអ្វីដែរ?

**ឆ៖** ជិះកង់ទៅ។

**ស៖** ពីស-២១ទៅព្រៃសហ្នឹង វាមានចម្ងាយប្រហែលជាប៉ុន្មានដែរ? ហើយលោកចំណាយពេលប៉ុន្មាននាទីដែរដើម្បីជិះកង់ពីស-២១ទៅព្រៃស?

**ឆ៖** ប្រហែលជាចូលជាងជិតមួយម៉ោងហើយ ជិះកង់ទៅហ្នឹង។

**ស៖** នៅពេលដែលលោកជិះកង់ចេញពីស-២១ទៅព្រៃស តើលោកត្រូវការលិខិតដើរផ្លូវទេ?

**ឆ៖** ព្រោះលិខិតសុំបញ្ជាក់ពី តាឌុច ទៅៗឱ្យគេ គាត់ធ្វើឱ្យបន្តិច គាត់នេះ ប៉ុន្តែកន្លែងហ្នឹងគេស្គាល់ ភាគច្រើនគេតាមផ្លូវហ្នឹង គេមិនសូវមានអ្នកយាមផងកាលហ្នឹង។

[០៩:២៣:២៥]

**ស៖** នៅពេលដែលលោកទៅដល់ព្រៃស តើលោកទៅជួបអ្នកណាដែរដើម្បីប្រាប់គេថាលោកត្រូវការធ្វើនេះធ្វើនោះ? ដូច្នេះខ្ញុំចង់ដឹងថានៅពេលដែលលោកទៅដល់ព្រៃស លោកទៅទាក់ទងអ្នកណា?

**ឆ៖** ទាក់ទង ហ៊ុយ – ហ៊ុយ ស្រែ។ ឈ្មោះ ហ៊ុយ ដែរ ប៉ុន្តែ ហ៊ុយ ស្រែ គេដាក់ ហ៊ុយ ស្រែ ខ្ញុំហៅតែ ហ៊ុយ ស្រែ។

**សះ** អ៊ីចឹង ហ៊ុយ ស្រែ ជាអ្នករកមនុស្សដែលលោកត្រូវការថតហ្នឹងមែនទេ?

**ផះ** បាទ ព្រោះដឹងថាបញ្ជូនមកថ្ងៃណា គាត់ប្រាប់ថានៅអង្គភាពនេះ អង្គភាពនោះហើយ។

**សះ** មេធាវីការពារក្តីបានអាននូវសម្រង់ចេញពីកំណត់ហេតុស្តាប់ចម្លើយរបស់លោក ហើយលោកបាននិយាយថា "អ្នកដែលត្រូវគេបញ្ជូនទៅព្រៃស គឺអ្នកតូចៗ"។ ខ្ញុំចង់ដឹងថា ធ្វើយ៉ាងម៉េចបានលោកដឹងថា អ្នកដែលគេបញ្ជូនទៅព្រៃសនោះ សុទ្ធតែអ្នកតូចៗទេ?

**ផះ** ព្រោះអ្នកតូចៗ មិនមែនចំពោះថាអ្នកហ្នឹងតូច រូបរាងគេ គេថាឋានៈតូចតាច។ ដូច តាឌុច គាត់ – និយាយទៅវាគ្មានពាក់ព័ន្ធអីធំដុំ គាត់បញ្ជូនទៅហើយ។

**សះ** ខ្ញុំយល់ ប៉ុន្តែខ្ញុំចង់ដឹងថា លោកមានការងារជាអ្នកថតរូប ប៉ុន្តែចង់ដឹងម៉េចបានលោកដឹងថាអ្នកណាមានឋានៈអ្វី អ្នកណាមានតួនាទីអ្វី? ហើយអ្នកដែលគេបញ្ជូនទៅព្រៃសហ្នឹងមានឋានៈតួនាទីអ្វី?

**ផះ** ព្រោះបានខ្ញុំដឹង ព្រោះភាគច្រើនខ្ញុំឃើញនៅកងអង្គភាពជាមួយខ្ញុំ នៅជំនាន់វ៉ៃ លន់ នល់ហ្នឹងណ៎ា ខ្លះឋានៈជាយុវជនអីហ្នឹង ធ្លាប់ស្គាល់គ្នាច្រើន ជំនាន់ខ្ញុំនៅធ្វើការវ៉ៃ ធ្វើទ័ពហ្នឹង។ បានខ្ញុំស្គាល់បានដឹង សន្និដ្ឋានថាជាអ្នកតូចតាច ព្រោះអ្នកធំៗ ខ្ញុំមិនអាចស្គាល់ ភាគច្រើនកាលជំនាន់ហ្នឹង។

[០៩:២៦:០៧]

**សះ** ឥឡូវនេះខ្ញុំបញ្ជាក់ឲ្យច្បាស់បន្តិចគឺថា លោកនិយាយថា អ្នកដែលទៅព្រៃសហ្នឹងគឺអ្នកតូចៗហ្នឹង ដោយសារលោកស្គាល់ពួកគេមួយចំនួន ដោយសារតែលោកស្គាល់ពួកគាត់មួយចំនួនហ្នឹង ដែលនៅក្នុងទាហានហ្នឹង មុនពេលដែលលោកមកស-២១ អ៊ីចឹងមែនទេ?

**ផះ** បាទ។

**សះ** ខ្ញុំនឹងអាននូវសម្រង់មួយចំនួន មកដកស្រង់ចេញពីសាក្សីដទៃទៀត ដែលគាត់បានមកផ្តល់សក្ខីកម្ម។ ម្សិលមិញមេធាវីការពារក្តីបានអានឲ្យលោកស្តាប់នូវសម្រង់មួយរបស់ ហ៊ឹម ហ៊ុយ ដែលគាត់មកផ្តល់សក្ខីកម្ម។ ដូច្នេះខ្ញុំសូមអាននូវសម្រង់របស់គាត់ នៅថ្ងៃ០៥ <ឧសភា> ២០១៦ នៅក្នុងតុលាការនេះគឺ <E1/428.1> នៅម៉ោងប្រហែលជា<១០:៥០ នាទី>ព្រឹក។ ហ៊ឹម ហ៊ុយ បានផ្តល់សក្ខីកម្មដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "នៅពេលដែលគេបញ្ជាខ្ញុំឲ្យបញ្ជូនអ្នកទោសទៅព្រៃស ពួកគេមិនបានថតរូបអ្នកទោសនោះទេ គឺផ្លូវមកពីពេទ្យចិន និងមកពីវិទ្យាល័យយុគន្ធរ។ គេឈប់ឡាននៅទីនោះ ហើយខ្ញុំត្រូវប្រើឡានមួយផ្សេងទៀត ដើម្បីដឹកអ្នកទោសហ្នឹងទៅព្រៃស។ ហើយខ្ញុំអត់ដែលឃើញគេថតរូបអ្នកទោសទាំងអស់នោះនៅក្នុងគុកទេ។" សូមបញ្ចប់ការដកស្រង់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយទី២ សួស ធី ខ្ញុំគិតថាលោកស្គាល់គាត់។ សួស ធី នៅក្នុងតុលាការមួយនេះ នៅថ្ងៃ០៦ មិថុនា ២០១៦គឺ E1/432.1 នៅប្រហែលជាម៉ោង១៥:២៥នាទី នៅរសៀល គាត់បានឆ្លើយដូចតទៅនេះ៖ "វាអាចដែលថាអ្នក<ទាំងនោះ>ត្រូវបានគេថត" <> គឺថាគាត់និយាយអំពីអ្នកដែលគេបញ្ជូនទៅព្រៃសហ្នឹង។ គឺថា "វាអាចដែលថាអ្នក<ទាំងនោះត្រូវ>គេថតរូប<>នៅផ្នែកខាងក្រៅមុនពេលដែលពួកគេ<ត្រូវបាន>បញ្ជូនទៅវាលស្រែ។ ហើយតាមខ្ញុំដឹង អ្នកដែលគេបញ្ជូនទៅក្នុង ហើយថតរូបហ្នឹងគឺមិនដែលបញ្ជូនទៅស្រែវិញទេ។ គេត្រូវបានឃុំខ្លួននៅក្នុងអគារទាំងអស់នោះ។" សូមបញ្ចប់ការដកស្រង់។

ដូច្នេះខ្ញុំចង់សួរលោកថា វាត្រឹមត្រូវទេដែល សួស ធី ហើយ ហ៊ឹម ហ៊ុយ គាត់បានឆ្លើយថា ការថតរូបអ្នកទោសដែលបញ្ជូនទៅ<ព្រៃស> គឺគេធ្វើឡើងនៅក្រៅបរិវេណទេ? ហើយអ្នកទោសដែលចូលដល់ក្នុងបរិវេណហើយនុ៎ង គឺមិនបញ្ជូនត្រឡប់ទៅព្រៃសទេ តើអ៊ីចឹងមែនទេ?

[០៩:២៩:១៨]

**ឆ៖** ព្រោះថតហ្នឹងគឺ ជួនណាថតនៅខាងក្រៅ ហើយបានថតក្រៅទៅ វាខូតទៅ តាមសុំគាត់ទៅថតឯណោះវិញ។ តែភាគច្រើនគឺថា ពេលដែលថតបានហើយ គឺខ្ញុំផ្ដិតទុកឲ្យ យកឲ្យ ធី ដដែល ព្រោះដាក់ក្នុងសំណុំរឿងឯកសារនេះហ្នឹង ឯកសាររូបថតហ្នឹង។ ប៉ុន្តែគ្រាន់ថា កន្លងមកវាច្រើនភាំង វាភ្លេចច្រើនដែរ បើយូរឆ្នាំដែរហើយ។ ប៉ុន្តែគ្រាន់ថាការងារកន្លងមក វាមិនសូវភ្លេចទាំងអស់ទេ ទាល់នឹកបានយូរ បាននឹកឃើញ។

**ស៖** សូមអរគុណ ខ្ញុំយល់ហើយ។ ខ្ញុំដឹងថា វាយូរមកហើយ។ ឥឡូវនេះខ្ញុំសូមបង្ហាញនូវរូបថតបន្តទៀត ហើយនិងមាននូវបញ្ជីឈ្មោះអ្នកទោសផងដែរ។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្ដល់រូបថតនេះជូនទៅដល់សាក្សី ហើយខ្ញុំនឹងផ្ដល់នូវលេខឯកសារយោងនៅពេលបន្ទាប់។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ យកឯកសារនេះជូនសាក្សី!

**លោក ឌេល លីសាក់៖**

ឯកសារទី១ សូមឲ្យលោកចាប់ផ្ដើមមើល <ហើយដើម្បីកំណត់ត្រាប្រតិចារឹក>មានរូបថតឯកសារ E3/8639.3998។ លោកប្រធាន សូមអនុញ្ញាតបញ្ចាំងនៅលើអេក្រង់។

[០៩:៣១:១១]

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីសោតទស្សន៍បញ្ចាំងនេះនៅលើអេក្រង់ទូរទស្សន៍!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** យើងមើលរូបថតអ្នកទោស។ រូបថតមួយនេះ តើខាងអេ.វី អាចបញ្ចាំងទេរូបថត3998 <បានទេ?> អ្នកទោសនៅក្នុងរូបថតទី១ ដែលខ្ញុំបានផ្តល់ជូនលោកសាក្សី គឺមានស្លាកសម្គាល់ហៅ -- <គាត់ជាស្ត្រីម្នាក់>មានឈ្មោះថា យឹម ខន ហៅ ធឿន គឺថ្ងៃហ្នឹង គេកំណត់ថ្ងៃ -- គេដាក់ថាថ្ងៃ០៥ ខែកុម្ភៈ ឆ្នាំ៧៨។ សូមបញ្ចាំងលើអេក្រង់។ លោកសាក្សី ហេតុផលដែលខ្ញុំសួរអំពីអ្នកទោសមួយនេះ នៅក្នុងរូបថតលើអេក្រង់ ឈ្មោះអ្នកទោស ហើយនិងថ្ងៃ រូបថតនេះគឺមានលេខ<3989>។ អ៊ីចឹងលេខហ្នឹងវាមិនឃ្លាតគ្នាឆ្ងាយទេ សូមដាក់មករូបថត3998។ ហេតុផលដែលខ្ញុំសួរអំពីរូបថតនេះ គឺឈ្មោះអ្នកទោស និងថ្ងៃខែ គឺវាត្រូវនឹងលេខអ្នកទោស៧៧០៨ នៅក្នុងបញ្ជីអ្នកទោសរបស់ ក.ស.ច.ស។ អ្នកទោសរូបនេះ គឺបានចុះនៅក្នុងបញ្ជីបញ្ជូនមកពីព្រៃស <គឺ>ស-២១<(ឃ)> ហើយមានលេខ៣១នៅក្នុងបញ្ជីហ្នឹង។ ឯកសារហ្នឹងមានលេខ E3/10248 ខ្មែរ ERNគឺ 01016745។ ខ្ញុំសូមអានឡើងវិញបញ្ជីអ្នកទោសដែលបញ្ជូនមកពីស-២១(ឃ) គឺឯកសារ E3/10248, ERN ជាភាសាខ្មែរគឺ 01016 745។ យើងមានបញ្ហាបច្ចេកទេសបន្តិចចំពោះពាក់ព័ន្ធនឹងការបញ្ចាំងរូបថតនៅលើអេក្រង់ សូមរង់ចាំបន្តិច។ យើងអាចបញ្ចាំងរូបថតនេះនៅលើអេក្រង់បាន។

[០៩:៣៤:៥៧]

យើងមានបញ្ហាក្នុងការបញ្ចាំងឯកសារនេះនៅលើអេក្រង់។ លោកមានឯកសារហ្នឹង រូបថតហ្នឹងនៅក្នុងដៃហើយ។ អ្នកទោសហ្នឹងគឺបានចុះនៅក្នុងបញ្ជី ថាបានបញ្ជូនពីព្រៃសចូលមកស-២១ នៅថ្ងៃទី០៥ កុម្ភៈ ឆ្នាំ៧៨។ ហើយយើងមានរូបថតមួយទៀតដែលលោកបានឃើញឈ្មោះហ្នឹង ចុះកាលបរិច្ឆេទហ្នឹងគឺថាថ្ងៃទី០៥ កុម្ភៈ ៧៨។ នៅពេលដែលយើងមើលកំណត់ហេតុ ហើយនិងបញ្ជីរូបថតទាំងអស់នេះ តើវាអាចឲ្យលោកនឹកឃើញទេ ដែលថាអ្នកទោសត្រូវបានចុះឈ្មោះ កត់ឈ្មោះ ហើយនិងថតរូបនៅពេលដែលគេបញ្ជូនពីព្រៃសមកស-២១ ដូចបានបង្ហាញតាមរយៈរូបថតស្ត្រីអ្នកទោសនេះ? តើត្រឹមត្រូវដែរឬទេ គឺអ្នកទោសដែលបញ្ជូនពីព្រៃសមកស-២១នោះ គឺអ្នកទាំងអស់នោះ ត្រូវបានគេបានថតរូបនៅពេលដែលមកដល់ស-២១ តើអ៊ីចឹងទេ លោកនឹកឃើញអ៊ីចឹងទេ?

**លោក នឹម អ៊ុំ៖**

**ឆ៖** ចំពោះអ្នកទោស -- អ្នកដែលបញ្ជូនទៅព្រៃស គឺថានេះដល់ហើយ ទាល់គេស្រាវជ្រាវរកឃើញ គេយកពីព្រៃសបញ្ជូនមក អ្ហ៎! ពីព្រៃសមកដាក់ស-២១វិញ ព្រោះកន្លងមកមានច្រើនដែរ ច្រើនដងដែរដែលខ្ញុំដឹង។

**ស៖** ករណីស្ត្រីអ្នកទោសរូបនេះ <តើពួកគេត្រូវបានថតរូបនៅពេលដែលពួកគេ>ត្រូវបានគេបញ្ជូនមកពីព្រៃសមកដល់ស-២១ <ហើយចូលទៅក្នុងបរិវេណ>ស-២១ មែនដែរឬទេ?

**ឆ៖** បាទ ពិតមែនហើយ។ តែចូលមកដល់គេថត ថតហើយបានបញ្ជូនឡើងលើអគារ។

[០៩:៣៧:២០]

**ស៖** ខ្ញុំនឹងរំលងឧទាហរណ៍ផ្សេងទៀត ប៉ុន្តែ<ខ្ញុំសូមអាន ដើម្បីឲ្យមាននៅក្នុងកំណត់ត្រាប្រតិចារឹក។> យើងដឹងថាមានរូបថតបីផ្សេងទៀត គឺ E3/8639.4082, .3989 ហើយនិង .4084។ នេះគឺជារូបថតអ្នកទោសចំនួនបីនាក់ ដែលមានស្លាកដាក់ថាអ្នកទាំងអស់ហ្នឹងចូលមកថ្ងៃ១៩ ខែមេសា ឆ្នាំ៧៨។ អ្នកទាំងបីនេះគឺស្ថិតនៅក្នុងបញ្ជីឈ្មោះអ្នកទោស <E3/10365> ដែលក្នុងនោះគឺបានបញ្ជាក់ថាបញ្ជូនមកពីឃ – ស-២១(ឃ) <គឺលេខ២២, ៣៣ និងលេខ៣៦ នៅក្នុងបញ្ជីនោះ>។ ខ្ញុំសូមចូលទៅដល់ប្រធានបទចុងក្រោយ គឺពាក់ព័ន្ធទៅនឹងចំនួនអ្នកទោសដែលបានថតរូបនៅស-២១។ តើលោកអាចជម្រាបតុលាការបានដែរឬទេ អំពីការប៉ាន់ស្មានណាមួយដែលវាត្រឹមត្រូវ ឬក៏អាចជឿជាក់បាន ថាតើមានអ្នកទោសចំនួនប្រហែលជាប៉ុន្មាននាក់ដែលត្រូវបានគេថតរូបនៅស-២១? បើសិនជាលោកមានតួលេខណាមួយជាក់លាក់ ឬក៏អាចស្មានឲ្យបានជាក់លាក់ណាមួយ ថាមានចំនួនប៉ុន្មានដែរ ដែលត្រូវបានគេថតរូបនៅស-២១?

**ឆ៖** ព្រោះការខ្ញុំចូលទៅនៅហ្នឹងគឺថា បើតាមខ្ញុំគិតដោយខ្លួនខ្ញុំ ហើយនិងកូនចៅខ្ញុំពីរនាក់អ្នកថតហ្នឹង ប្រហែលជាខ្ទង់ប្រហែលបួនប្រាំម៉ឺន អស់លើ អ្ហ៎! បួនប្រាំពាន់ អស់លើសហើយ ច្រឡំ!។

**ស៖** តើធ្វើដូចម្ដេចបានជាលោកអាចស្មានចំនួន ថាមានចំនួនប៉ុណ្ណឹងបានទៅ? តើលោករាប់រូបថត ចំនួនរូបថតជារៀងរាល់ឆ្នាំ ឬក៏យ៉ាងម៉េច? តើធ្វើម្ដេចទើបលោកអាចប្រាប់ថា មានចំនួនប៉ុណ្ណឹងនៅអង្គភាពរបស់លោកដែលបានថតរូប? តើដោយសារលោករាប់ជារៀងរាល់ឆ្នាំលើរូបថត ឬក៏យ៉ាងម៉េច?

**ឆ៖** ព្រោះខ្ញុំអាងហ្វីល ខ្ញុំតម្កល់ទុកនៅកន្លែងក្នុងបន្ទប់ខ្ញុំ ប៉ុន្តែខ្ញុំអត់ឃើញហ្វីលហ្នឹងសុទ្ធ។

[០៩:៤០:១៦]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សះ** តើហ្វីលហ្នឹងមានប៉ុន្មានដុំ? ហើយលោកយកមកពីណាដែរ?

**ធះ** ហ្វីលៗដែលខ្ញុំនេះហ្នឹង ខ្ញុំប្រមូលតាំងពីបែកភ្នំពេញភ្លាម ប្រមូលទុកដាក់គរ តាំងពីខ្ញុំចូលធ្វើជាង រៀនជាងថតហ្នឹង ខ្ញុំដើរប្រមូលគ្រប់កន្លែងទាំងអស់នៅផ្ទះជាងថត យកមកទុកកន្លែងរក្សាថែរក្សាសុវត្ថិភាពទុកវិញ។

**សះ** តើលោកធ្លាប់មាននៅមើលឡើងវិញទៅលើបញ្ជីឈ្មោះអ្នកទោសដែលបានចូលមក ស-២១ រៀងរាល់ខែទេ លោកមានបានមើលឡើងវិញទេលើបញ្ជីនុ៎ង?

**ធះ** អ្ហូ ! អាហ្នឹងខ្ញុំអត់ដែលបានមើលទេ ដឹងតែថតហើយទុកលាង ផ្តិតហើយលាងហ្វីល ផ្តិតទុកហ្វីលស្រួលក្នុងបន្ទប់តែម្តង។ ព្រោះអត់មានកត់កំណត់ហេតុទុកទេ តាំងពីខ្ញុំនេះមក គ្រាន់តែដឹងថាថតបានប្រគល់ឲ្យ ធី ថតបានបញ្ជូនឲ្យ ធី។

**សះ** តើធ្វើរបាយការណ៍ប្រចាំទៀងទាត់ ហើយនិងប្រចាំខែ ហើយបូកទៅនឹងរូបថតដែលលោកបានថតពីខែមួយទៅខែមួយទេនៅក្នុងសម័យនុ៎ង?

**ធះ** សម័យហ្នឹងអត់ដែលបានធ្វើរបាយការណ៍អីៗទៅថ្នាក់ៗលើទេ ទៅ តាឌុច ទេណ៎ា ព្រោះខ្ញុំដឹងតែថតហើយដឹងបញ្ជូនទៅ ថតបញ្ជូនទៅ ប៉ុន្តែរឿងរាយការណ៍រាល់ខែគ្មាន អត់ដែលបានរាយ-ការណ៍ទេ។

**សះ** មូលហេតុដែលខ្ញុំសួរសំណួរហ្នឹង គឺនៅក្នុងភស្តុតាងក្នុងពេលជំនុំជម្រះនេះ គឺមានរូបថតជាង៦.១៧០នៅស-២១ ដែលរូបថតហ្នឹងវានៅសល់ <ហើយត្រូវបានគេរកឃើញ>។ តើខ្ញុំនិយាយនេះលើកឡើងត្រឹមត្រូវដែរឬទេ? លោកបានបញ្ជាក់ថា មានរូបថត ថតហ្នឹងប្រហែលជាបួនប្រាំពាន់ គឺលោកផ្អែកថាមានរូបថតប្រហែលជា៤.០០០ ឬក៏៥.០០០នោះ ដោយសារតែផ្អែកទៅលើហ្វីលដែលលោកបានប្រមូល ហើយទុកនៅផ្ទះ។ អ៊ីចឹងដែរឬទេ?

[០៩:៤២:៥៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េះ**

*(គ្មានការបកប្រែ)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

លោក១មេធាវី នួន ជា ផ្អាកបន្តិចសិន អ្នកបកប្រែខាងភាសាខ្មែរអត់មានសំឡេងទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

-- អ៊ីចឹងគឺតួលេខហ្នឹងគឺមិនត្រឹមត្រូវទេ តាមខ្ញុំដឹង --

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីបន្ត!

[០៩:៤២:៣៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងលើកឡើង១វិញ យើងជំទាស់ចំពោះការប្រើប្រាស់តួលេខ៦.១០០ជាងហ្នឹង។ ដូចដែលយើងបានដឹងហើយជាច្រើនលើកច្រើនសា គឺយើងខ្ញុំបានលើកឡើងនូវហ្វីលដែលផ្តិតរួចហ្នឹង ប្រមូលបានមកហ្នឹង គឺគេបានកំណត់ដោយអ្នករូបថតអាមេរិកាំងពីររូប គឺគេបានផ្តល់តួលេខហ្នឹងត្រឹមតែប្រហែលជា៥.០០០តែប៉ុណ្ណោះ។ ប្រសិនបើសហព្រះរាជអាជ្ញានៅពេលនេះបន្ថែមតួលេខរូបថតថ្មីដែលថាបានលើកឡើងកាលពីម្សិលមិញ គ្មានភស្តុតាងណាមួយដែលបង្ហាញថា មានរូបថតនៅសល់បន្ថែម១.០០០ជាងនោះទេ។ ប្រហែលជារូបថតដែលសល់នោះអាចជារូបថតដែលមនុស្សដដែល ដែលគ្រាន់តែវារូបថតជាន់គ្នា<ជាមួយនឹងរូបថត ដែល>អ្នកថតរូបអាមេរិកាំងពីររូប<>បាន<រកឃើញ>។ <ដូច្នេះការ>លើកឡើងតួលេខ<៦.១០០>ជាងនោះ គឺថាវា<ខុសគ្នាឆ្ងាយណាស់ តាមដែលខ្ញុំដឹងហើយវាគ្មានភស្តុតាងជាមូលដ្ឋានផង>។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមបញ្ជាក់ថា សៀវភៅរបស់ ដេវីដ ឆេនដ៍ល័រ “សំឡេងពី ស-២១” គឺឯកសារ E3/1684 ត្រង់ ERN ជាភាសាអង់គ្លេស 00192706, ខ្មែរ 00191861, បារាំង 00357291 បានលើកឡើងអំពីរូបថតអ្នកទោស ដែលថាមានជាង៦.០០០រូបថតដែលបានថតដោយអង្គភាពហ្នឹងនៅសល់។ ហើយនៅលេខសម្គាល់ចុង -- នៅទំព័រចុងក្រោយនៃសៀវភៅនោះ គឺលេខសម្គាល់៣៨ <ជំពូកទី១> ត្រង់<ទំព័រភាសាអង់គ្លេស> 00192859 មិនមានការបកប្រែជាភាសាខ្មែរនោះទេ។ ក្នុងហ្នឹងគឺខ្ញុំសូមដកស្រង់ថា៖ “<>ក្រុមដែលរក្សារូបថតរបស់ នីរីន និង <រ៉េល្លី> ហ្នឹងគឺបានធ្វើការប្រមូល និងផ្តិតរូបហ្នឹង ហើយមាន<ហ្វីល>រហូតទៅដល់ជាង៦.០០០ <>រូបថត <នៅក្នុងសារមន្ទីរនេះ នៅឆ្នាំ១៩៩៤-១៩៩៥>។”

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<បញ្ចប់ការដកស្រង់។> ដូច្នេះដែលខ្ញុំលើកឡើង<៦.១៧៤>ហ្នឹង គឺខ្ញុំផ្អែកទៅលើរូបថតដែលបានបូកបញ្ចូលនៅក្នុងឯកសារ E3/8639 ដែលក្នុងហ្នឹងគឺបានបង្ហាញថាមានរូបថត៥.១៨៦ បូកនឹង៩៨៨<រូបថត>ទៀត <ដែល>មជ្ឈមណ្ឌលឯកសារកម្ពុជា<ប្រមូលចងក្រងថ្មីនេះ ហើយដែលត្រូវបានបញ្ជាក់ច្បាស់ថាជាអ្នកទោស>។ នេះជាមូលដ្ឋានដែលយើងផ្អែកតួលេខ៦.០០០ជាងនេះ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំចង់សូមសួរលោកថា មានរូបថតជាង៦.០០០ជាងរូបថតដែលនៅសល់។ តើត្រឹមត្រូវដែរឬទេ គឺការដែលលោកថាមាន៤.០០០ ឬក៏៥.០០០រូបថតតែប៉ុណ្ណោះនោះ គឺដោយសារតែលោកផ្អែកទៅលើដុំហ្វីលដែលលោកប្រមូលបាន។ តើអ៊ីចឹងដែរឬទេ?

[០៩:៤៧:០៥]

**លោក នឹម អ៊ុំ៖**

**ឆ៖** ព្រោះដុំហ្វីលដូចខ្ញុំប្រាប់អ៊ីចឹង ប្រាប់អ៊ីចឹងថា ពេលខ្ញុំថតគឺផ្តិតហើយៗ មូរចូលដុំវិញដាក់នៅក្នុងបន្ទប់រូបថត ហ្នឹងសម្រាប់រង្វង់អាហ្វីលថតហើយ។ តែបើតាមដែលលោកនិយាយថាប្រាំ ទាំង៦.០០០ហ្នឹងប្រហែលជា ខ្ញុំដឹងប្រហែល អាស្រ៊ុំ ដែលវាថតនៅអាកន្លែងការងារធំៗហ្នឹងណ៎ា ហើយបញ្ចូលក្នុងហ្នឹងទៀត បានខ្ញុំអត់ ព្រោះទាក់ទងអត់បានទេអាហ្នឹង ព្រោះខ្ញុំអត់ដែលចេញចូលកន្លែងគេទេ គឺកន្លែងខ្ញុំគឺនៅកន្លែងខ្ញុំ កន្លែងគេគឺកន្លែងគេ អត់មានឆ្លងកាត់ឯណាបានទេជំនាន់នុ៎ង។

**ស៖** តើអ្នកដែលជាអ្នកថតរូបម្នាក់ទៀត ដែលលោកលើកឡើងអំមិញហ្នឹងមានឈ្មោះអ្វីដែរ? សូមលោកបញ្ជាក់សាជាថ្មី។

**ឆ៖** អាស្រ៊ុំ។ អាហ្នឹងគឺគេខាងបក្ខជនហើយណ៎ា ជំនាន់ហ្នឹងគេហៅបក្ខជន អាហ្នឹងគ្រប់គ្រងធ្វើការកន្លែងឃាំងអ្នកធំៗទុកដោយឡែកនោះ ជំនាន់ហ្នឹង។

**ស៖** សំណួរចុងក្រោយមួយមុនពេលដែលខ្ញុំផ្តល់វេទិកាទៅដល់សហមេធាវីនាំមុខ។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ តួលេខដែលលោកប៉ាន់ស្មានអម្បាញ់មិញនេះ គឺផ្អែកទៅលើ<ការចងចាំពីចំនួន>ដុំហ្វីល<>តែប៉ុណ្ណោះ មិនមែនគឺផ្អែកទៅលើតួលេខដែលលោកកត់ត្រានៅសម័យ នោះពេលដែលលោកនៅស-២១នោះទេ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[០៩:៤៨:៥៧]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

សាក្សី! សាក្សី! មីក្រូហ្វូនលោកអត់ទាន់ប្រតិបត្តិការទេ! ចាំមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហម ចាំលោកឆ្លើយ។

**លោក នឹម អ៊ុម៖**

**ឆ៖** ព្រោះពេលហ្នឹងគឺដែលខ្ញុំសន្និដ្ឋានអ៊ីចឹង ព្រោះខ្ញុំពេលក្រុមខ្ញុំផ្តិត លាងរូបថតហើយ ផ្តិតហើយ គឺប្រមូលហ្វីលទុកម្ដុំ ទុកកន្លែងហិបមួយម៉ុំដោយឡែក ព្រោះការពារក្រែងលោត្រូវការខ្វះខាតខូចអី វាមានអាហ្នឹងយកមកផ្តិតវិញ។ គេរកឈ្មោះណា រូបណាអី យើងផ្តិតមកវិញ។ ហើយផ្នែកនេះហ្នឹង ពួកខាងដូច ស្រ៊ី ខ្ញុំប្រាប់អំមិញអ៊ីចឹងថា កន្លែងគេអាអ្នកធំ គេអត់ឲ្យមាន ខ្ញុំចូលថតបានទេ រឿងអីក៏ដោយក៏អត់ទេ មានខ្ញុំបានមានតួនាទីក្នុងបន្ទប់អាកន្លែងគេធំហ្នឹងហើយ កន្លែង ស្រ៊ី ក្តោបក្តាប់ហ្នឹងហើយ អាហ្នឹងគេហៅខ្ញុំទៅ ពួកខ្ញុំទៅ បើថាចូលអ្នកកន្លែងសំខាន់ៗខ្ញុំអត់ដែលបានចូលទេ។

**ស៖** ខ្ញុំព្យាយាមសួរបញ្ជាក់ម្តងទៀត។ លោករក្សាទុកនូវរូបថតហ្នឹង ក៏ប៉ុន្តែលោកអត់មានដាក់កត់ត្រាលេខប៉ុន្មានៗៗទេ សម័យនោះ មែនដែរឬទេ គ្រាន់តែរក្សាទុកនូវដុំហ្វីលតែប៉ុណ្ណោះ?

**ឆ៖** បាទ ពិតមែន អត់ដែលបានកត់អីទាំងអស់។

**លោក ខេល លីសាក់៖**

អរគុណលោកសាក្សី ដែលបានចំណាយពេលវេលាផ្តល់នូវចម្លើយ និងសក្ខីកម្មនេះ។

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

ពេលវេលាសម្រាប់លោកទាំងពីរក្រុម គឺអស់ហើយ។ តើលោកស្រីមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីលោកមានទេ?

[០៩:៥០:៥៥]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ លោកប្រធានខ្ញុំមានសំណួរតែបីទេ។ យើងចាប់ផ្តើមនៅម៉ោងប្រាំបួនប្រាំនាទី អ៊ីចឹងខ្ញុំនៅសល់ប្រហែលជាបីបួននាទីលោកប្រធាន។ អ៊ីចឹងសូមមេត្តាផ្តល់បីបួននាទីឲ្យខ្ញុំ ខ្ញុំសួរតែពីរបីសំណួរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណច្រើនលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍។ ខ្ញុំជាតំណាងឱ្យក្រុមជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំនុំរឿងនេះ។ ខ្ញុំមានសំណួរពីរបី ដើម្បីសួរបន្តទៅលោក ក្រោយពីមេធាវី នួន ជា សួរលោកកាលពីម្សិលមិញ។ កាលពីម្សិលមិញ លោកបាននិយាយពីពេទ្យម្នាក់ដែលត្រូវបានគេចាប់ខ្លួន ហើយសម្លាប់ចោល ដោយសារតែគាត់ជាប់ពាក់ព័ន្ធនឹងការរំលោភអ្នកទោសស្រីម្នាក់។ ចុះអ្នកទោសស្ត្រីដែលត្រូវគេរំលោភនោះ លោកដឹងថាតើមានរឿងអ្វីកើតឡើងចំពោះគាត់ទេ?

[០៩:៥២:១៥]

**លោក នឹម អ៊ុំ៖**

**ឆ៖** បើតាមខ្ញុំឮសួរពួកអ្នកស្គាល់គ្នានៅក្បែរនុ៎ង គេប្រាប់ថា អ្នកទោសនុ៎ងមកពីបារាំង ហើយដល់គ្នាឈឺ គ្នាមកពិនិត្យពេទ្យ ហើយខាងពេទ្យគេ អើ!ឃើញថាឆ្ងាយ អាងតែថាស្ងាត់ រំលោភមែន ដល់មានអ្នកគេឃើញ គេរាយការណ៍ ក៏ជាប់ពិរុទ្ធទៅ។ អស់ហើយ។

**ស៖** លោកដឹងថា ស្ត្រីដែលមកពីបារាំងហ្នឹង ក្រោយពីគេរំលោភហើយហ្នឹង តើគេធ្វើយ៉ាងម៉េចចំពោះគាត់ដែរ? លោកដឹងពីរឿងហ្នឹងទេ? តើមានហេតុការណ៍អ្វីកើតឡើងចំពោះគាត់ ក្រោយពីត្រូវបានពេទ្យនោះរំលោភមក?

**ឆ៖** អត់បានដឹងទេ ព្រោះខ្ញុំគ្រាន់តែឮសួរគេប្រាប់តែបញ្ហាហ្នឹងហើយ គេបញ្ជូនទៅគុកវិញទៅក្នុងគុកវិញទៅ។

**ស៖** សំណួរចុងក្រោយលោកប្រធាន។ តើការរំលោភហ្នឹង ត្រូវបានចាត់ទុកថាជាការប្រព្រឹត្តខុសសីលធម៌ទេ? លោកធ្លាប់ឮពាក្យហ្នឹងទេ ពាក្យថា "ខុសសីលធម៌" ហ្នឹង?

**ឆ៖** ឮសួរ ជំនាន់នុ៎ង តែឱ្យតែមានអ្នកគេរំលោភ រឿងនេះសុទ្ធតែ សីលធម៌កាលហ្នឹង គឺថាសុទ្ធតែស្លាប់ៗ គ្មានរស់មួយទេ។

[០៩:៥៤:១៤]

**សៈ** តើមានករណីប្រព្រឹត្តខុសសីលធម៌ហ្នឹងផ្សេងទៀតទេនៅស-២១ ក្រៅពីហេតុការណ៍ដែលលោកបានឃើញ ហើយនិងបានស្តាប់ឮហ្នឹង? <ខ្ញុំនិយាយពីអំពើខុសសីលធម៌ដែលលោកបានដឹង ឬដែលលោកបានឮបន្ថែមទៅលើ>ការរំលោភទៅលើស្ត្រីដែលមកពីបារាំងហ្នឹង តើមានករណីខុសសីលធម៌បែបហ្នឹង កើតឡើងទៀតទេ នៅស-២១?

**ឆៈ** តាំងពីហ្នឹងមក អត់ដែលឮសូរទេ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន សូមអរគុណដែលបានផ្តល់ឲ្យខ្ញុំប៉ុន្មាននាទីចុងក្រោយនេះ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។

លោក -- សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**សៈ** លោកសាក្សី កាលពីម្សិលមិញលោកឆ្លើយថា គេដាក់គុកលោកអស់រយៈពេលប្រហែលជា១០ឆ្នាំ គឺពីឆ្នាំ១៩៩៦ដល់ឆ្នាំ២០០៦។ ខ្ញុំចង់ដឹងថាពេលហ្នឹងគេមានកាត់ទោសលោកទេ? ហើយបើលោកត្រូវបានកាត់ទោសនោះ តើតុលាការណាជាអ្នកកាត់ទោសលោក? ហើយកាត់ទោសពីបទអ្វីដែរ?

[០៩:៥៥:៣៨]

**លោក នឹម អ៊ុំ៖**

**ឆៈ** ឥឡូវខ្ញុំសូមជម្រាបរឿងដែលខ្ញុំជាប់គុក១០ឆ្នាំនៅជំនាន់ហ្នឹង គឺដោយសារអ៊ីចេះ ដោយសារខ្ញុំកាលហ្នឹងខ្ញុំធ្វើ មកដល់ភ្លាមខ្ញុំប្រែឈ្មោះខ្ញុំដាក់ នឹម អ៊ុំ វិញ គេអត់ដឹងប្រវត្តិរូបខ្ញុំ ដល់ខ្ញុំនេះគេឲ្យខ្ញុំធ្វើប្រធានក្រុម។ ដល់ប្រធានក្រុម ដល់ពេលហើយមួយគ្រួសារហ្នឹង គឺពេលផឹកស៊ីលេងល្បែងមកវិញ ប្រពន្ធឆ្លងទន្លេបានប្រហែលជា១១ថ្ងៃ ប្រពន្ធហេវច្រានគ្នាឡើងដាំបាយ អត់មានម្ហូបស៊ី ក៏ហូបមួយទឹកត្រី។ ដល់ពេលអាប្តីមកលេងល្បែងផឹកស៊ីវិញ រកស៊ីមិនបាន វ៉ៃប្រពន្ធ ចងសសរទ្រូង ម៉ែវាមកប្តឹងខ្ញុំ

មឹងវាក៏មកប្ដឹងខ្ញុំ តាវាមកប្ដឹងខ្ញុំ។ ខ្ញុំអត់នឹកថាខ្ញុំអត់ទៅ ព្រោះដឹងថាអាមួយហ្នឹងវាឃោរឃៅពេក ខ្ញុំក៏អត់ទៅ បងថ្លៃខ្ញុំក៏ស្រែកពីកើតមក ថាអូនអ្អែងទៅមើលផង តិចនាងទាស់ងាប់។ ខ្ញុំក៏ឡើង ដល់ហើយនឹកឃើញអ៊ីចឹង ឡើងទៅ។ ក៏សួរអ៊ីចឹង ដើរ *(ឮមិនច្បាស់)* ហ្នឹងនិយាយកាត់ៗចុះ ព្រោះវាវែងពេក។ អស់រយៈកាលប្រហែលជាប្រាំប្រាំមួយខែក្រោយមក បានវាលេងយកមែនទែនតែម្តង--

**ស៖** លោកសាក្សី រឿងហ្នឹងខ្ញុំអត់ចាំអារម្មណ៍ទេ សូមអភ័យទោស។ អ្វីដែលខ្ញុំចង់ដឹងនោះ គឺខ្ញុំចង់សួរលោកថា លោកមានបង្ហាញខ្លួននៅចំពោះមុខតុលាការណាទេ? មានការវិនិច្ឆ័យទោសលោកទេ? <តើលោកបានឃើញចៅក្រមណាមួយទេក្នុងរយៈពេល១០ឆ្នាំដែលលោកជាប់ឃុំ>នោះ?

**ផ៖** ពេលនោះខ្ញុំមានការ ថាជ្រុលជ្រួសដៃទៅ ក៏ខ្ញុំអត់រត់ទៅណា គឺដើរៗខ្លួនចូលឲ្យច្បាប់គេកាត់ទោសតាមច្បាប់ តុលាការឯខេត្តកណ្តាលយើងហ្នឹង។

**ស៖** ហើយគេប្រកាសលោកថា មានពិរុទ្ធហ្នឹងដោយពីបទអីដែរ?

[០៩:៥៧:៤៧]

**ផ៖** សម្លាប់ដោយអចេតនា។

**ស៖** អ៊ីចឹងមានន័យថា គេផ្តន្ទាទោសហ្នឹង ដោយសារតែលោកបានសម្លាប់មនុស្ស មានន័យថាគេផ្តន្ទាទោសលោកដោយសារតែលោកបានសម្លាប់មនុស្សដោយអចេតនា មែនទេ?

**ផ៖** បាទ។

**ស៖** បាទ សូមអរគុណ។ កាលពីម្សិលមិញលោកបានពន្យល់ថា ក្នុងពេលលោករៀនថតរូបហ្នឹង តាណាត បានយកអ្នកថតរូបអាជីពមកបង្រៀន ហើយអ្នកថតរូបអាជីពហ្នឹងគឺ អ្នកថតរូបនៅសម័យមុន។ ហើយពេលហ្នឹងគេមានប្រាប់លោក<ពីរបៀប>ប្រើប្រាស់សម្ភារៈដើម្បីថតរូប។ ខ្ញុំចង់ដឹងថា អ្នកថតរូបដែលមកបង្រៀនលោកហ្នឹង ក្រោយមកតើគេធ្វើយ៉ាងម៉េចចំពោះពួកគាត់ដែរ?

**ផ៖** ព្រោះ -- កាលម្សិលមិញខ្ញុំនិយាយហ្នឹងថា ពេលដែលខ្ញុំរកឯកសាររបស់ជាងថតគ្រប់ផ្ទះប្រមូលទៅបានឯកសារត្រូវលាយថ្នាំ ឯកសារលាងហ្វីលអីហ្នឹង ពិបាក ខ្ញុំទៅសូម តាណាត ទៅរកនេះជាងថតដែលគេជម្លៀសពីភ្នំពេញទៅហ្នឹង ដើម្បីឲ្យគាត់បកប្រែ ខ្ញុំក៏ទៅៗ សូមប្រធានភូមិគេហ្នឹងដើម្បីយកឈ្មោះហ្នឹងឲ្យបកប្រែ ហើយខ្ញុំក៏បានដឹកអង្ករពីភ្នំពេញទៅឲ្យមួយប៉ាវ។ តែរឿងក្រោយមកទៀតមិនដឹងយ៉ាងម៉េចទេ ព្រោះខ្ញុំអត់ដឹង ព្រោះបានៗតែត្រឹមគាត់កសាងមកឲ្យខ្ញុំហើយហ្នឹង។

**ស៖** តើការបង្រៀនហ្នឹងប្រព្រឹត្តទៅនៅកន្លែងណា នៅស-២១ ឬក៏នៅកន្លែងផ្សេង? ហើយអ្នក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ថតរូបដែលបង្រៀនលោកហ្នឹងមានត្រូវបានគេឃុំខ្លួនទេ?

[១០:០០:២១]

**ឆ៖** ព្រោះពេលនោះ ខ្ញុំយកតែឯកសារជាភាសាអង់គ្លេស ហើយនិងក្រដាស ហើយសៀវភៅ ហើយនិងប៊ិកទៅ រកប្រជាជននៅមូលដ្ឋានណោះវិញទេ អត់មានមករៀននៅនឹងភ្នំពេញវិញទេ។

**ស៖** អ៊ីចឹងអ្នកថតរូបទាំងអស់ហ្នឹងនៅកន្លែងណា ពួកគាត់នៅស-២១ ឬក៏នៅកន្លែងណាផ្សេង?

**ឆ៖** មិនមែនថា ដូចខ្ញុំប្រាប់ថា ពេលខ្ញុំនេះ ខ្ញុំយល់ហើយន័យដែលសួរហ្នឹងគឺថា ខ្ញុំយកតែឯក-សារដែលភាសាអង់គ្លេស ភាសាអីហ្នឹង យកទៅឲ្យគេអ្នកបកប្រែនៅឯមូលដ្ឋាន។ ហើយយកឲ្យបកប្រែជាភាសាខ្មែរមកឲ្យខ្ញុំរៀនជាក់ស្ដែងនៅ មកអនុវត្តជាក់ស្ដែងនៅកន្លែង៧០៣នេះ។ ជាថត៧០៣ក្បែរខាងលិចផ្សារថ្មីនេះ។

**ស៖** អ៊ីចឹងមានន័យថា លោកមិនដែលបានជួបអ្នកបកប្រែដែលសុំឲ្យ -- ជួបអ្នកថតរូបដែលសុំឲ្យបកប្រែឯកសាររបស់លោកហ្នឹងទេ មែនទេ? គឺគ្រាន់តែជាការរៀនពីចម្ងាយ មែនទេ?

**ឆ៖** ខ្ញុំបានទៅជួបគាត់ដែរ ជួបនៅយើងខេត្តកណ្ដាលនេះ ប៉ុន្តែតែខាងមូលដ្ឋានឲ្យគាត់ ឲ្យប្រធានភូមិគេរក សួរអ្នកដែលចេះ ថាមូលដ្ឋានរឿងអ្នកថតហ្នឹង ដែលជម្លៀសពីភ្នំពេញទៅ ឲ្យគាត់បកប្រែឲ្យទៀត មកខ្ញុំទេ។ តែដល់យកមកដល់ផ្ទះ បានខ្ញុំមើលទៅតាមហ្នឹង ហើយនិងថ្នាំ ឈ្មោះថ្នាំឈ្មោះអីហ្នឹង បានខ្ញុំៗរៀនតាមហ្នឹង ខ្ញុំរៀនលាយ។ លាយទម្រាំធ្វើត្រូវហ្នឹង មិនដឹងអស់ប៉ុន្មានដងទេ ទម្រាំត្រូវមួយៗនោះ។

**ស៖** អ៊ីចឹងលោកមិន ដែលបានឃើញអ្នកថតរូបណា គាត់ផ្ដិតរូបនៅចំពោះមុខលោកផ្ទាល់ទេ មែនទេ? លោកផ្ដិត ឬលាងហ្វីលអីហ្នឹងដោយខ្លួនឯង ដោយគ្រាន់តែអានឯកសារដែលគេបកប្រែឲ្យលោកហ្នឹងមកមែនទេ?

[១០:០៣:០១]

**ឆ៖** បាទ ព្រោះពេលហ្នឹងខ្ញុំយកមករៀនជាក់ស្ដែង។ តែចេះលាយថ្នាំ ចេះថត ចេះលាងហ្វីល ហើយ ខ្ញុំមករៀនផ្ដិត ប៉ុន្តែមិនមែនបានផ្ដិតភ្លាមបានល្អភ្លាមទេ ទម្រាំបានកែសម្រួល ទម្រាំរៀនចេះដឹង ប៉ុន្តែអាងអង្គាល់ណោះក្រដាស ហើយនិងហ្វីលសម្បូរ។

**ស៖** លោកចំណាយពេលប៉ុន្មានដើម្បីប្រមូលសម្ភារៈសម្រាប់ថតរូប ប្រមូលហ្វីលប្រមូលអីហ្នឹងនៅតាមហាងដែលគេបោះបង់ចោលនៅទីក្រុងភ្នំពេញនោះ?

**ឆ៖** ប្រហែលបួនប្រាំប្រាំមួយខែដែរ ទម្រាំប្រមូលអស់គ្រប់កន្លែង ទាំងថ្នាំទាំងហ្វីលទាំងក្រដាស ទាំងម៉ាស៊ីនផ្តិត ម៉ាស៊ីនថត។

**ស៖** តើលោកយកសម្ភារៈហ្នឹងយកទៅទុកនៅកន្លែងណា ពេលដែលលោកប្រមូលហើយ? លោកទុកនៅស-២១ ក្នុងបរិវេណទួលស្លែងសព្វថ្ងៃហ្នឹង ឬក៏នៅកន្លែងណាផ្សេង?

**ឆ៖** បាទ ជំហានទី១ នៅឆ្នាំ៧៥ហ្នឹង ខ្ញុំទុកនៅកន្លែង៧០៣ នៅខាងលិចកន្លែងផ្ទះថតអន្តរជាតិហ្នឹងកាលខ្ញុំនៅ៧០៣។ ដល់ក្រោយមក គេបញ្ជូនខ្ញុំបីនាក់មកនៅស-២១ បានខ្ញុំយកពីណោះមកខ្លះ ហើយចាប់ផ្តើមរកក្រៅៗកន្លែងអគារខ្លះ។

**ស៖** អ៊ីចឹងពេលដែលលោកប្រមូលបានហ្នឹង លោកមាននៅចាំទេកាលពេលហ្នឹង ថាលោកប្រមូលបានទឹកថ្នាំ ហ្វីល ក្រដាសអីហ្នឹងប៉ុន្មានដែរ?

[១០:០៥:១១]

**ឆ៖** គិតទៅច្រើន បើវានេះបើពេញមួយបន្ទប់ហើយ មានតាំង អារូបថតអាផ្តិតពណ៌ រូបអាម៉ាស៊ីនៗផ្តិតពណ៌ក៏មាន ម៉ាស៊ីនស-ខ្មៅ ក៏មាន។ គិតទៅរៀនទៅ បានៗពួកហ្នឹងមកពីចិនវិញ ចាប់ផ្តើមបង្រៀនផ្តិតស-ខ្មៅ -- អាផ្តិតអាពណ៌។

**ស៖** មុននេះលោកបាននិយាយចំនួនរូបថតអ្នកទោសដែលលោកគិតថា ក្រុមរបស់លោកជាអ្នកថតនៅស-២១។ អ៊ីចឹងលោកអាចប្រាប់ពីចំនួនក្រដាសដែលលោកមានបានទេ លោកមានក្រដាសហ្នឹងប៉ុន្មានដុំដែរ? ហើយហ្វីលហ្នឹងប៉ុន្មានដុំ?

**ឆ៖** អ៊ូ! អាហ្នឹងខ្ញុំអត់បានចាំទេ វាច្រើនណាស់។ ព្រោះកាលនេះវា កាលហ្នឹងវាអត់មាន អត់មានដូចថាលក្ខណៈរៀបចំក្នុងខែណាមួយ វាយការណ៍ខែណាមួយ វាយការណ៍អត់ទេ គឺដឹងតែថតហើយ បញ្ជូនទៅរូបថតឲ្យ ធី ហ្នឹង ព្រោះខ្ញុំអត់បានចាំច្បាស់ទេ។ ខ្ញុំគ្រាន់តែថា វាសន្និដ្ឋានរបស់ខ្ញុំថាបួន ឬក៏ប្រាំពាន់ជាងប៉ុណ្ណឹង។

**ស៖** លោកសាក្សី <លោកប្រាប់យើងថា> លោកបានគណនាចំនួនរូបថតអ្នកទោសនៅស-២១ ដោយផ្អែកទៅលើចំនួនហ្វីលដែលលោកមាន។ អ៊ីចឹងបើលោកមិនដឹងថាលោកមានហ្វីលហ្នឹងប៉ុន្មានដុំផង លោកម៉េចទៅដឹងចំនួនរូបថតអ្នកទោស<ដែលថតនៅស-២១>ហ្នឹងបានទៅ លោកអាចពន្យល់បានទេ?

**ឆ៖** ជំនាន់ហ្នឹងគឺថាពួកខ្ញុំថតហើយ ខ្ញុំទុកអាហ្វីលហ្នឹងមូលចូលអាដុំវាវិញ ដើម្បីទុកការពារ

តែពេល នេះខូចអី យើងស្រណុកដឹងរបស់យើងមាន។ តែរឿងចំនួនដុំហ្វីល ក្រដាស ខ្ញុំអត់ដែលបានគិតទេកន្លងមក។

[១០:០៧:៤១]

**ស៖** លោកអាចជម្រាបបានទេ តើលោកទៅថតរូបអ្នកទោសដោយខ្លួនឯងផ្ទាល់ហ្នឹងញឹកញាប់ប៉ុនណាដែរ? លោកថាលោកមិនទៅរាល់ថ្ងៃទេ ដោយសារពេលខ្លះទៅ អត់មានអ្នកទោសច្រើន ហើយលោករវល់ដែរ។ អ៊ីចឹងលោកអាចប្រាប់ពីចំនួនបានទេ លោកទៅថតហ្នឹងមួយអាទិត្យម្ដង ឬក៏មួយអាទិត្យច្រើនដង ប្រហាក់ប្រហែល លោកអាចប៉ាន់ប្រមាណបានទេ?

**ឆ៖** បើតាមដែលខ្ញុំធ្លាប់ដែលមានមើលគឺថាជួនណា ពីរបីថ្ងៃជាប់គ្នាក៏មាន ជួនណាមួយអាទិត្យ ឬអីអ៊ីចឹង ប៉ុន្តែថាឲ្យដាច់ វាមិនសូវដាច់ប៉ុន្មានទេ គ្រាន់តែថាវាជួនណាមិនច្រើនពេក ជួនណាមិនតិចទៅ។ តែអារឿងឲ្យដាច់ គ្មានទេក្នុងខែមួយៗ វាអត់ដែលដាច់ទេណា តែគ្រាន់តិច និងច្រើន។

**ស៖** ពេលដែលលោកទៅថតរូបហ្នឹង គឺថាថតហ្នឹងស្មើនឹងចំនួនកូនចៅលោកទៅថតដែរមែនទេ? លោកមានមនុស្សប្រាំមួយនាក់នៅកន្លែងថតរូបហ្នឹង បីនាក់ដែលត្រូវបានរៀនសូត្រទៅនឹងកន្លែងហ្នឹង ហើយបីនាក់ទៅរៀននៅចិន។ អ៊ីចឹងលោកទៅថតរូបអ្នកទោសហ្នឹងញឹកញាប់ដូចគ្នាទៅនឹងកូនចៅលោកទាំងប្រាំមួយនាក់ដែលទៅថតអ្នកទោសហ្នឹងដែរមែនទេ?

**ឆ៖** ឈប់! ខ្ញុំសំណួរដែលលោកសួរខ្ញុំនេះ គឺខុសអាពេលនេះ ព្រោះ៦ថ្ងៃនេះ និយាយពីនៅក្នុង៧០៣ឯណោះទេ។ តែបីនាក់គឺបញ្ជូនមកពី ៧០៣ មកស-២១ មកបីនាក់ ខ្ញុំ, អានិត, សុង តែប៉ុណ្ណឹងទេ។

**ស៖** បាទ មិនអីទេអ៊ីចឹង។ អ៊ីចឹងនៅក្នុងក្រុមលោកមានអ្នកថតរូបបីនាក់ លោក ហើយនិងពីរនាក់ផ្សេងទៀត។ អ៊ីចឹងឥឡូវខ្ញុំសួរថា លោកទៅថតហ្នឹងក្នុងកម្រិតញឹកញាប់ស្មើគ្នាជាមួយនឹងអ្នកទាំងពីរទៀតដែរហ្នឹង ឬក៏លោកទៅថតហ្នឹងតិចជាងគេទេ ពីរនាក់នុ៎ងគេទៅថតច្រើនជាងលោក?

[១០:១០:០៧]

**ឆ៖** ព្រោះធម្មតាមកច្រើន បានខ្ញុំទៅជួយ បើថាមកតិច ខ្ញុំឲ្យថា ភាគច្រើនខ្ញុំឲ្យ និត ឬសុង *(ឮមិនច្បាស់)* ហើយនេះទុកខ្ញុំនៅធ្វើការ នៅលាង លាយថ្នាំនៅអីឯណោះ។

**ស៖** បើលោកចាំនោះ ថាតើលោកទៅថតរូបអ្នកទោសហ្នឹងប៉ុន្មានដងដែរ?

**ឆ៖** អ៊ូ! បែបមិនបានចាំច្បាស់ទេ ព្រោះរយៈកាលយូរហើយ បើនិយាយពីចំនួន ដូចខ្ញុំប្រាប់

ចំនួនខ្ញុំប៉ាន់ស្មានវាគ្រាន់ខុសត្រូវបន្តិចបន្តួចទេ ប៉ុន្តែថាបើនិយាយឲ្យ ខ្ញុំនេះទៅថតញឹកញាប់ ថាប៉ុន្មានដង ៗ ពិបាកនឹងសន្និដ្ឋានណាស់ ព្រោះពេលហ្នឹងវាយូរឆ្នាំ។ ប៉ុន្តែគ្រាន់តែដឹង ខ្ញុំថាក្នុង១ខែ វាលោះៗយ៉ាងច្រើន ថាអត់បំផុតហើយ និយាយពីអ្នកអត់ចូលមក យ៉ាងច្រើនបួន ប្រាំ ប្រាំមួយ ប្រាំពីរដង ជំនាន់នុំង។ តែចូលមក គេហៅពួកខ្ញុំទៅថត បើខ្ញុំមិនទៅ ឲ្យកូនចៅខ្ញុំទៅ។

**ស៖** លោកនិយាយអំមិញហ្នឹងក្នុងកម្រិតប្រចាំសប្តាហ៍ ឬក៏ប្រចាំខែ?

**ឆ៖** និយាយដល់ទៅខែតែម្តង បើថា លើកទៅថាអត់បំផុត ក៏បួនប្រាំដង តែប៉ុណ្ណឹងទេ។ អាហ្នឹងបើថាថ្ងៃណានេះ ព្រោះខ្ញុំធ្លាប់នៅ ឃើញការ កន្លងមកថាផ្ទួនៗមានពីរបីថ្ងៃជាប់ ក៏មានដែរ បើតិច ឬច្រើន ខ្ញុំមិនដឹងទេ គឺមកជាប់តែម្តង។

**ស៖** តើលោកផ្ទាល់ និងអ្នកថតរូបផ្សេងទៀត នៅក្នុងអង្គភាពរបស់លោកហ្នឹង ធ្លាប់ថតរូបឲ្យបុគ្គលិកមន្ទីរស-២១ ទេ? ឬក៏មានអង្គភាពផ្សេង គេជាអ្នកថតរូបឲ្យបុគ្គលិកស-២១ទេ?

[១០:១២:៣១]

**ឆ៖** សម្តេច ខ្ញុំធ្លាប់ថតឲ្យដែរ អ្នកដែលនេះ តែបើកូនចៅខ្ញុំក៏ធ្លាប់ថតឲ្យដែរ ព្រោះឃើញរូបអ្នកដែលពាក់មួកហ្នឹង សុទ្ធតែអ្នកធ្វើការទេ។ ព្រោះខ្ញុំថតពួកម៉ាកខ្ញុំ វាថាថតឲ្យតែញឹកដែរហ្នឹង។

**ស៖** ចុះលោកដឹងទេថា អ្នកថតរូបផ្សេងទៀតហ្នឹងគាត់ធ្លាប់ថតរូបឲ្យកម្មាភិបាល ឬក៏បុគ្គលិកស-២១ទេ?

**ឆ៖** ធ្លាប់។ ដូចជាធ្វើការ ដូចគ្នា ធ្វើការ អ្នកកម្មាភិបាលអីហ្នឹងក៏មានថត ថតឈរធម្មតាក៏មានថត ថតកូនគាត់ក៏មានថត។

**ស៖** លោកក៏បាននិយាយអំពីអ្នកទោសវៀតណាមផងដែរកាលពីម្សិលមិញ។ លោកដឹងទេ ក្នុងចំណោមអ្នកធ្វើការនៅស-២១ហ្នឹង តើមានអ្នកណាគាត់ទទួលបន្ទុកក្នុងការថតខ្សែភាពយន្តឯកសារទេ?

**ឆ៖** ហ្នឹង កន្លែងខ្ញុំអត់មានទេ មានតែខាងក្រសួងនេះនោះ ក្រសួងសារព័ត៌មានមាន ប៉ុន្តែអ្នកថតក្រោយមក អ្នកថតយួន វៀតណាមហ្នឹង ជាប់គុកវិញដែរ។

**ស៖** <តើលោកអាចរៀបរាប់អំពីបុគ្គលនេះបានទេ?> ម៉េចក៏គេចាប់អ្នកថតហ្នឹង? ហើយ <ម៉េចបាន>លោកដឹង<>ថា គាត់ថតហ្នឹងថត<កុនអំពី>វៀតណាម<>?

**ឆ៖** ថតតាមបណ្តើរវៀតណាមតាមទីក្រុង។

**ស៖** <នរណា ហើយដើម្បីអ្វីដែរ?> លោកបានមើលឃើញកុនហ្នឹងនៅពេលណាដែរ? ហើយ

ក្នុងកុនហ្នឹងគេបង្ហាញពីអីខ្លះ?

**ឆ៖** អត់ដែលបានឃើញសុទ្ធ។

[១០:១៥:៣៩]

**ស៖** ហេតុអីបានជាអ្នកថតកុនរឿងវៀតណាមហ្នឹងត្រូវបានគេចាប់ខ្លួន?

**ឆ៖** ព្រោះអត់បានដឹងដែរ ព្រោះនៅអង្គភាពខុសគ្នា។

**ស៖** អង្គភាពផ្សេងហ្នឹង លោកសំដៅលើអង្គភាពណា? ហើយអង្គភាពហ្នឹងនៅស-២១ ឬក៏នៅកន្លែងណា?

**ឆ៖** មិនមែននៅស-២១ វានៅខាងក្រសួង ខាងកាសែត ខាងទស្សនាវដ្តី ខាងរោងពុម្ព ខាងក្រសួងនោះ ហៅក្រសួងថតដាក់ធ្វើស្រូវធ្វើស្រែដាក់ក្នុងទស្សនាវដ្តីហ្នឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថាដល់ម៉ោងត្រូវឈប់សម្រាកហើយ។ លោកប្រធានខ្ញុំនៅសល់បីបួនសំណួរទៀតលោកប្រធានចង់សម្រាកក៏សម្រាក បើឲ្យខ្ញុំបន្ត ក៏ខ្ញុំបន្តទៅទៀត។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពេលនេះតទៅ។

*(សវនាការសម្រាកពីម៉ោង ១០:១៧ នាទី ដល់ម៉ោង ១០:៣៥ នាទី)*

[១០:៣៥:៣៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក បន្តសំណួរ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សីលោកអាចជម្រាបបានទេថា តើសមាជិកគ្រួសាររបស់លោកហ្នឹងជាបុគ្គលិកនៅមន្ទីរស-២១ ឬក៏<ពួកគេ>ត្រូវបានជាប់ឃុំឃាំងនៅស-២១ ទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក នឹម អ៊ឹម៖**

**ឆ៖** ទេ ចំណែកក្នុងខ្ញុំគ្រួសារខ្ញុំ គឺមានប្អូនប្រុសមួយជានីរសារ។ ដល់ហើយគេដកមកឲ្យធ្វើខាងអង្គ -- ហៅអង្គរក្សយាម អ្នកយាមគុក អ្នកយាមការគុកហ្នឹង។ ដល់ពេលខ្ញុំក្រឡេកឃើញ វាភ័យខ្លួន។ ភ័យខ្លួន ដល់ក្រោយមក ឃើញប្អូនខ្ញុំគេដកពីអង្គរក្សការពារគុកទៅធ្វើបន្លែ។ ធ្វើបន្លែនៅ ចិញ្ចឹមអ្នកស-២១ហ្នឹង។ ផុតពីហ្នឹងក្រោយមក បានប្រហែលជាពីរខែ ឃើញដកប្អូនខ្ញុំទៅឃ្វាលគោនៅស្រុក ស-២១ -- នៅព្រៃស។ ហើយនិងអ្នកជិតខាងខ្ញុំម្នាក់ពីរទៀត ខ្ញុំក្រឡេកឃើញ ខ្ញុំអត់ហ៊ានស្តីរក ខ្លាចក្រែងលោស្គាល់គ្នា កុំឲ្យគេតាមដាន។ មានប្អូនបង្កើតមួយ គេដកពីខាងអ្នកយាមគុកទៅធ្វើបន្លែនៅ ចិញ្ចឹមគេ។ ដកចិញ្ចឹមបន្លែ បានទៅយាមគោឲ្យ ឃ្វាលគោ ឃ្វាលក្របីនៅព្រៃស។

[១០:៣៧:៤២]

**ស៖** ហើយប្អូនលោកហ្នឹងរួចជីវិតពីរបបខ្មែរក្រហមទេ? ហើយពេលគាត់ទៅធ្វើការនៅព្រៃស ហ្នឹងគេមានថតរូបគាត់ទេ?

**ឆ៖** អត់បាន អត់បានថតទេអង្កាល់ហ្នឹង។ ប៉ុន្តែប្អូនខ្ញុំពេលដែលបែកហ្នឹង វារត់ទៅជាមួយខ្ញុំ រហូតដល់នេះ ដល់ពោធិ៍សាត់ បាត់ដំបងនោះ បាត់បង់ជីវិតទៅត្រឹម ខ្ញុំដឹងដំណឹង ពួកម៉ាក់ប្រាប់ខ្ញុំថា គេបាញ់ត្រូវថ្កាមផ្ទុះសងខាង។ ខ្ញុំថាពេលនោះ តែត្រូវថ្កាមហើយ នៅព្រៃភ្នំដឹងងាប់ហើយ អត់មានអីហូប មិនដឹងនរណាចិញ្ចឹមនរណាទេ។

**ស៖** លោកដឹងទេថាហេតុអីបានជាគេដកគាត់ចេញពីអង្គភាពកងការពារនៅស-២១? ហើយគាត់ធ្លាប់ធ្វើការនៅកងពល៧០៣ មែនទេ បានជាគេដកគាត់ចេញនោះ?

**ឆ៖** ព្រោះពេលនោះខ្ញុំដឹងថាប្អូនខ្ញុំ មិនដឹងជានីរសារលោកបានទេ អង្កាល់ហ្នឹងណ៎ា ដល់ហើយ គេថាៗ ពេលនោះគេបញ្ជូនពីនីរសារ ដកពីនីរសារទាំងអស់ដែលខ្ញុំតាមដានមើល ឃើញនៅតែពួកអាមួយក្បែរផ្ទះខ្ញុំក៏នីរសារវរសេនាតូច វរសេនាធំអ៊ីចឹង គេដកអ្នកហ្នឹងយកមកធ្វើខាងអ្នកយាមគុកថែមមើលការខុសត្រូវ អ្នកយាមពួកអ្នកទោសហ្នឹងណ៎ា។ ប៉ុន្តែភាគច្រើនណាស់ដែលឃើញអ្នកសួរចម្លើយក្តី ដែលត្រូវនីរសារអី អត់មានអារឿងអាមេធំៗជាប់មានទោស ដោយទាំងអស់ទៅហើយ។ ដូច អាឡេង នៅប្រាសាទ វានីរសារអ្នកនៅវរសេនាតូច វរសេនាធំអ៊ីចឹង គេដកយកមកធ្វើការនៅក្នុងក្រសួងហ្នឹងទាំងអស់។

[១០:៣៩:៥២]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើលោកមានបានកត់សម្គាល់ឃើញមានខ្សែបណ្ដាញរបស់បុគ្គលិកស-២១ ត្រូវបានបោសសម្អាតទេ? ហើយបើមានហ្នឹង តើអ្នកទាំងអស់ហ្នឹងជាខ្សែកងពល៧០៣ ឬក៏ខ្សែអ្នកណាផ្សេង? ហើយចុះខ្លួនលោកផ្ទាល់នោះ លោកមានភ័យខ្លាចថានឹងត្រូវគេចាប់ខ្លួនទេ? ហើយបើភ័យខ្លាច តើហេតុអ្វី?

**ឆ៖** ព្រោះពេលនោះ វាភ័យៗតែរឿងកាលហ្នឹងខ្ញុំវាតាមរយៈចូលមកក្នុងជាងថត៧០៣ហ្នឹង គឺតាមរយៈជាមួយ ទី១ តាមរយៈ ស្រី មឿន ហៅធារិទ្ធ អាហ្នឹងនាំ ដែលពេលខ្ញុំដើរមកជួបគាត់ ពេលថ្ងៃបែកភ្នំពេញហ្នឹង ខ្ញុំចេញពីពេទ្យមកជួបគាត់នៅយើងសាលាថៅហ្វាយ -- សាលាក្រុង -- សាលាស្រុក -- សាលាខេត្ត ក្នុងខេត្តកណ្ដាលនេះ គាត់ក៏ក្រឡេកឃើញខ្ញុំ ក៏ឲ្យនីរសាគាត់ហៅខ្ញុំមកនេះ។ គាត់ថាៗខ្ញុំលួចរត់មកពីនេះ ពីពេទ្យ ដល់នេះខ្ញុំទើបងើបសន្លប់បានពីរថ្ងៃតើ។ បានខ្ញុំចេញមក ទាស់ជាមួយពេទ្យ ខ្ញុំខឹងពេទ្យហ្នឹង ខ្ញុំចុះមកហ្នឹង។ រត់ចេញមក មកចំថ្ងៃបែកហ្នឹងហ្មង។ ថ្ងៃបែកក៏ជួបគាត់ទៅនេះ គាត់ឲ្យខ្ញុំរៀបចំមើលការខុសត្រូវអ្នកដែលសប្បាយអរជ័យជម្នះ ហើយនិងជិះយកម៉ូតូ ជិះឡាន ខ្លាចទាហានបាញ់ហ្នឹង។ បានគាត់បញ្ជូនខ្ញុំហើយ គាត់បញ្ជូនមកឲ្យនៅជាមួយ តាណាត។ ហើយជួប តាណាតៗឲ្យខ្ញុំយកមកទៅកង -- ទៅកន្លែងជាងថត៧០៣។ គ្នា ពូបង ប៉ែរ ថា មានអាកោយ, មានអាយ៉េង, មានអាមាន មានអានិត មានអាសុង និងខ្ញុំហ្នឹង។ បន្ទាប់មកបានពួកហ្នឹងវា បែបមេវាគ្រោះថ្នាក់ ដល់វាដឹង វាយកខោអាវខ្ញុំ យកមួកខ្ញុំ កាំភ្លើងខ្ញុំរត់ទៅថៃទៅ។ បានខ្ញុំថាពេលនោះ តែមានមេថាគេចាប់ហើយកូនទៅហើយ អ្នកជិតដិតហ្នឹងទៅហើយ។ បានខ្ញុំភ័យ ព្រោះខ្លួនខ្ញុំហ្នឹងឃើញ តាណាត ចូលហ្នឹង បានខ្ញុំភ័យ ហើយណាមួយ វាអាចុងបញ្ចប់នេះ ខ្ញុំភ័យមែនទែន ភ័យលែងចង់ហូបបាយ ដល់នឹកឃើញវាប្អូនផង ឯណេះផង អ្នក ជាប់អ្នកធំៗ ធ្លាប់នៅជាមួយផង ភ័យបណ្ដោយ។

[១០:៤២:៣៥]

**ស៖** កាលពីម្សិលមិញ លោកបានឆ្លើយថា លោកធ្លាប់ថតរូបអ្នកទោសដែលត្រូវបានវាយឲ្យស្លាប់។ អ៊ីចឹងលោកធ្លាប់ថតរូបសាកសពនៅខាងក្រៅបរិវេណស-២១ទេ? ជាពិសេសថតរូបសាកសពដែលគេអារក ឬក៏វះពោះជាដើមដែលត្រូវបានគេកាយចេញមកពីរណ្ដៅនោះ លោកធ្លាប់ទេ?

**ឆ៖** ខ្ញុំបានធ្លាប់ពេលដែលគេសម្លាប់ហើយ គេកប់ កប់ហើយបានប្រហែល អត់មានបានថតទេ ព្រោះអ្នកសំខាន់ៗ បានគេហៅខ្ញុំទៅថតនៅខាងលិចសារៈមន្ទីរនៅក្នុងរបងជាប់របងគុកហ្នឹង ក្នុងគុកហ្នឹងហ្មង។ អាហ្នឹង ប៉ុន្តែដល់ខ្ញុំមិនច្បាស់ថា តាណាត អីស្អី ព្រោះពេលហ្នឹង អត់មានអ្នកណាហ៊ាន

ប្រាប់ខ្ញុំទេ ប៉ុន្តែរាងរៅវាស្រដៀងដែរ ប៉ុន្តែវាហើម វាហើមដែរ ចុះប៉ុន្មានថ្ងៃហើយបានគេគាស់ឲ្យទៅថតនោះ។ មានធ្លាប់ដែរ ហើយគេវារ៉ៃស្លាប់នៅក្នុង យកមកដល់កន្លែងសួរចម្លើយ មកដល់កន្លែង វ៉ៃស្លាប់ ក៏ខ្ញុំ គេឲ្យខ្ញុំឡើងថត។

**ស៖** ហើយលោកបានផ្តិតជារូបថត<ទាំងនោះ>ទេ <ឬក៏លោកបានឃើញទេ>?

**ឆ៖** បានៗផ្តិត។

**ស៖** លោកដឹងថាតើមានថ្ងៃណាដែលមានអ្នកទោសមកច្រើនបំផុត<មកដល់ស-២១> ហើយមាន<អ្នក>ណា<មិនត្រូវបានថតរូប>ទេ?

**ឆ៖** មានៗ ជួនណាមានមកច្រើនទៅ ជួនណាភាគច្រើនមកគរទាំងយប់ ព្រឹកៗឡើង ហៅទៅថតរូប ក៏មានដែរ។

**ស៖** ខ្ញុំចង់សំដៅទៅពេលណាមួយដែលមានអ្នកទោសច្រើន ហើយពេលនុ៎ង គឺថាដោយសារតែមានអ្នកទោសច្រើនពេកអ៊ីចឹង គេសម្រេចថា មិនបាច់ថត មិនបាច់អីទេ។ លោកធ្លាប់ដឹងថា មានករណីបែបហ្នឹងទេ ថាពេលណាមួយនោះមក ដោយសារតែមានអ្នកទោសមកក្នុងចំនួនច្រើនពេកអ៊ីចឹងទៅ គេសម្រេចថា មិនបាច់ថត មិនបាច់អីទេ?

[១០:៤៥:៤០]

**ឆ៖** ហ្នឹងបើតាមខ្ញុំដឹងប្រហែលជា វាមិនដែលជួបប្រទះទេ។ វាធ្លាប់តែពេលព្រលឹម ហៅខ្ញុំចូលទៅថត ហៅទៅថត ប៉ុន្តែអាហ្នឹងវាច្រើនមែនទែនហើយណា៎ គេដាក់បន្ទប់ពន្ធនាគារសិន បានព្រឹកមក គេហៅជាងថតទៅថត ហ្នឹងមាន។ តែរឿងឲ្យថា ចូលហើយ អត់ថត ដូចគ្មាន។

**ស៖** លោកសាក្សី លោកចាំទេថា រូបថតអ្នកទោសចុងក្រោយបំផុតហ្នឹង គឺត្រូវបានថតនៅថ្ងៃណាដែរ នៅស-២១នុ៎ង?

**ឆ៖** អត់បានចាំទេ ព្រោះវានុ៎ង វាយូរឆ្នាំហើយ ណាមួយវាភ្លេចភ្លាំងអស់ទៅ ប៉ុន្តែថាវាអត់ដឹងថ្ងៃណា ថ្ងៃណី ព្រោះអាថ្ងៃបែកហ្នឹង ថតមិនទាន់បានផ្តិតក៏មានដែរ។

**ស៖** ចុះលោកចាំទេថា អ្នកទោសណាដែលលោកបានថតចុងក្រោយគេបំផុត?

**ឆ៖** អត់បានចាំ ព្រោះយូរឆ្នាំហើយ វាភ្លេចភ្លាំងអស់ទៅ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម។

អញ្ជើញលោកស្រីមេធាវីការពារលោក ខៀវ សំផន លោកស្រីមានសំណួរទេ ចំពោះសាក្សីនេះ?

[១០:៤៧:៤០]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំមានសំណួរមួយចំនួនតូចទេ ពីព្រោះខ្ញុំដឹងថា ពេលវេលាសម្រាប់មេធាវីការពារក្ដីហ្នឹង គឺជិតអស់ហើយ។ អ៊ីចឹងខ្ញុំសូមសួរតែបន្តិចបន្តួចទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតជូនលោកស្រី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន។ ខ្ញុំសួរសំណួរមួយចំនួនតូចទេ បន្តទៅនឹងចម្លើយដែលលោកបានឆ្លើយកាលពីព្រឹកមិញនេះ។ ឥឡូវនេះខ្ញុំត្រឡប់មកចម្លើយចុងក្រោយរបស់លោកអម្បាញ់មិញ ទៅនឹងសំណួររបស់ចៅក្រមឡាវែន៍។ លោកថា លោកមិនចាំថាតើលោកថតរូបចុងក្រោយបំផុតនៅថ្ងៃណាទេ។ ក៏ប៉ុន្តែលោកចាំថាពេលដែលលោករត់ហ្នឹង គឺថាហ្វីលមួយចំនួនមិនទាន់បានផ្ដិតទេ។ អ៊ីចឹងពេលដែលលោករត់ហ្នឹង តើហ្វីលដែលមិនទាន់បានប្រើ និងមិនទាន់បានផ្ដិតហ្នឹងគឺទុកនៅកន្លែងដដែល កន្លែងដែលលោកផ្ទុកសម្ភារៈហ្នឹង ឬក៏យ៉ាងណា? មានន័យថា គេទុកនៅកន្លែងសុវត្ថិភាពទាំងអស់ហ្នឹង ឬក៏លោករត់ទៅហ្នឹង លោកយកហ្វីល យកអីទៅតាមខ្លួនដែរ?

[១០:៤៩:០៨]

**លោក នឹម អ៊ីម៖**

**ឆ៖** ខ្ញុំពេលដែលរត់ហ្នឹង គឺខ្ញុំអត់មានបាន តែម៉ាស៊ីនថតអីក៏អត់មានយកទាំងអស់ យកតែខោអាវទេ ហើយនិងប្រដាប់ប្រដាខោអាវបន្តិចបន្តួចទៅទេ។ ហ្វីល ម៉ាស៊ីនថតនៅនុ៎ងទាំងអស់ អត់មាន

បានយកទៅទេ។

**ស៖** ចំណុចមួយទៀតដែលខ្ញុំចង់សួរលោកដែរ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់លោកចៅក្រម ឡាវែន៍ លោកបាននិយាយអំពីបុគ្គលម្នាក់ដែលបានថតកុនទាហានវៀតណាម។ ហើយលោកបាននិយាយថា លោកមិនចាំថាគាត់មកពីក្រសួងណាទេ ក៏ប៉ុន្តែលោកគិតថា ប្រហែលជាក្រសួងព័ត៌មានដែលទទួលបន្ទុកខាងឃោសនាការ។ ដូច្នេះខ្ញុំចង់សួរលោកដូចតទៅ ក្នុងពេលដែលលោកបំពេញការងារនៅស-២១ លោកធ្លាប់ទៅខាងក្រៅថតរូបឃោសនា ឧទាហរណ៍ដូចលោកធ្លាប់ទៅថតរូបប្រឡាយ ទំនប់ ឬក៏នៅកន្លែងណាផ្សេងៗទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? ឬក៏បើមិនមែនជាលោកទេ តើមានអ្នកណានៅស-២១ គាត់ធ្លាប់ចុះទៅថតតាមមូលដ្ឋាន ថតប្រឡាយ ថតទំនប់អីចឹងទេ?

**ឆ៖** ពីព្រោះការថតអ្នកធ្វើស្រូវ អ្នករែកដី អ្នកធ្វើប្រឡាយអីហ្នឹង គឺខាងស-២១ អត់មានបានថតទេ។ គឺខាង -- ដែលកាលខ្ញុំនៅ៧០៣ ខ្ញុំបានចុះទៅថត ថតដែរ តែភាគច្រើន គឺតាមដាក់ទស្សនាវដ្តីតាមទស្សនាវដ្តីនេះវិញ អាហ្នឹងខាង គេខាងឃោសនាការ ខាងសារព័ត៌មានហើយ បើតាមខ្ញុំដឹង។ ព្រោះអាមួយដែលខ្ញុំថាថតកុនហ្នឹង ដែលថតហ្នឹងហ្នឹង ភាគច្រើន ហ្នឹងអ្នកថតហ្នឹងហើយ ព្រោះខ្ញុំធ្លាប់កាលខ្ញុំនៅ៧០៣ ធ្លាប់ជួបគ្នាម្តងហើយ។

[១០:៥១:៤១]

**ស៖** ដើម្បីឲ្យខ្ញុំយល់កាន់តែច្បាស់ នៅពេលដែលលោកនិយាយថា លោកថតរូបឲ្យទស្សនាវដ្តីពេលដែលលោកនៅកងពល៧០៣ហ្នឹង គឺលោកសំដៅទៅពេលមុន ដែលគេបញ្ជូនលោកមកធ្វើការនៅស-២១ មែនទេ?

**ឆ៖** បាទ។

**ស៖** នេះជាសំណួរចុងក្រោយ លោកប្រធាន។ ខ្ញុំសួរសំណួរនេះ ពីព្រោះថានៅក្នុងសវនាការកាលពីថ្ងៃទី២០ មេសា ឆ្នាំ២០១៦ គឺប្រហែលជាក្រោយម៉ោង០៩:១៣នាទីបន្តិច សាក្សី ញ៉ែម អេន គាត់បាននិយាយថា ក្នុងពេលគាត់ធ្វើការនៅស-២១ គាត់ធ្លាប់ត្រូវបានគេអនុញ្ញាតឲ្យចេញក្រៅស-២១ គឺគេឲ្យគាត់ទៅថតរូបដើម្បីឃោសនា។ អីចឹងលោកដឹងទេថា ញ៉ែម អេន ហ្នឹង គាត់ពិតជាបានទៅតាមភូមិភាគ<ចំនួនប្រាំមួយ>នៅទូទាំងប្រទេស ដើម្បីថតរូបឃោសនាទេ នៅពេលដែលគាត់ធ្វើការនៅស-២១នោះ?

**ឆ៖** អានេះ បើតាមបើ អេន និយាយនេះ តែពួកខ្ញុំ តើដើរចេញក្រៅ មិនបានដើរផង។ ទាល់តែ

មានដូចថា ដូចខ្ញុំប្រាប់ថា ទាល់តែខ្ញុំខូចហ្វីលខូចអី អាហ្នឹងខ្ញុំបានសុំគេទៅថតនៅស្រែហ្នឹងណ៎ា។ តែញ៉ែម អេន នេះ ថា១០០ គឺអស់ទាំង១០០ គ្មានការពិតទេ។

**ស៖** សំណួរចុងក្រោយបំផុតហើយ លោកប្រធាន។ កាលពីម្សិលមិញ លោកបាននិយាយថា លោកបានសម្ភាសជាមួយអ្នកប្រវត្តិវិទ្យា។ លោកអាចបញ្ជាក់បានទេថា អ្នកប្រវត្តិសាស្ត្រហ្នឹង ឈ្មោះអីដែរ ដែល<>គាត់<បាន>ទៅ<ដល់>កន្លែង<លោកនោះ>?

[១០:៥៣:៤៥]

**ឆ៖** បាទ សូមដាក់សំណួរមួយសាទៀត ខ្ញុំអត់ទាន់យល់កន្លែងហ្នឹង។ សូមដាក់សំណួរមួយសាទៀត។

**ស៖** ខ្ញុំប្រហែលសួរលឿនពេក មើលទៅ។ កាលពីម្សិលមិញ លោកបាននិយាយថា លោកបានសម្ភាសជាមួយនឹងអ្នកសិក្សាស្រាវជ្រាវខាងប្រវត្តិសាស្ត្រ ហើយលោកបាននិយាយអំពីបទពិសោធន៍របស់លោកនៅស-២១ ជូនគាត់។ អ៊ីចឹងលោកចាំឈ្មោះអ្នកដែលមកសម្ភាសលោកហ្នឹងទេ?

**ឆ៖** ខ្ញុំមានដែរ ដូចជាធ្វើឆ្នាំ ប៉ុន្មានឆ្នាំនោះគឺមកញឹក ប៉ុន្តែឆ្នាំក្រោយនេះខ្ញុំ -- ប៉ុន្មានខែនេះ ខ្ញុំទៅ យើងនៅនេះ សម្ភាសខ្ញុំរឿងប្រវត្តិដែលខ្ញុំឆ្លងកាត់ហ្នឹង។ ឆ្លងកាត់ចូលធ្វើ តាំងធ្វើទ័ព ចូលឆ្នាំ៧០មកហ្នឹង។ ខ្ញុំនិយាយប្រវត្តិឱ្យគាត់ស្ដាប់។ ព្រោះជំនាន់ហ្នឹងគឺខ្ញុំធ្វើការហ្នឹង ខ្ញុំដឹងណាស់ កាលខ្ញុំសឹកពីបួសមកហ្នឹង គឺឆ្នាំ៧០ រដ្ឋប្រហារសម្ដេច សីហនុ ហ្នឹង។ គឺចូលភូមិខ្ញុំ ឃើញមុនដំបូង--

**ស៖** សូមអធ្យាស្រ័យលោកសាក្សី។ ខ្ញុំមិនឱ្យលោករៀបរាប់លម្អិតអីទេ ខ្ញុំគ្រាន់តែចង់ដឹងថាតើអ្នកដែលមកសម្ភាសលោកហ្នឹង គាត់ឈ្មោះអី? លោកនៅចាំទេឈ្មោះគាត់ គាត់ឈ្មោះអី?

**ឆ៖** បរទេសទេណ៎ា ស្រី! នៅខាងកសាងប្រវត្តិសាស្ត្រនៅៗកន្លែងហួសនេះទៅ ភ្លេចឈ្មោះកន្លែងហ្នឹងហើយ។

**ស៖** អ៊ីចឹងមានន័យថា លោកភ្លេចឈ្មោះស្ត្រីដែលមកសម្ភាសលោកហ្នឹងហើយមែនទេ? បើមិនចាំឈ្មោះក៏ហីទៅចុះ អ៊ីចឹងលោកចាំទេ ថាគាត់ហ្នឹងសញ្ជាតិអីដែរ?

**ឆ៖** បារាំងមិនដឹង ស្វីមិនដឹង ស្រីឈ្មោះ បើខ្ញុំដឹង គេហៅឈ្មោះ អានៗ។

[១០:៥៦:១៥]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានខ្ញុំសូមអរគុណដែលបានផ្ដល់ពេលវេលាពីរបីនាទីចុងក្រោយនេះឱ្យខ្ញុំ។ ខ្ញុំសូមអស់

សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។ អង្គជំនុំជម្រះអរគុណលោក នឹម អ៊ឹម ដំណើរការស្ដាប់សក្ខីកម្មរបស់លោកនៅពេលនេះបានដល់ទីបញ្ចប់ហើយ អង្គជំនុំជម្រះអរគុណលោកដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះរយៈពេលពីរថ្ងៃនេះ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះវិលត្រលប់ទៅវិញ។

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

ជាបន្តទៅនេះ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-283 មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងបន្ទប់សវនាការនេះ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ លោកស្រីត្រូវការពាក់វ៉ែនតាខ្មៅជាចាំបាច់នៅពេលនេះ។ អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកស្រីប្រើប្រាស់វ៉ែនតាខ្មៅនេះ។

[១០:៥៩:០៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកស្រីឈ្មោះអីដែរ?

**លោកស្រី មុំ វុន៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** លោកស្រី នៅពេលលោកស្រីឆ្លើយ ចាំមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហមនៅលើក្បាលមីក្រូហ្វូន ចាំលោកស្រីឆ្លើយ។ សូមលោកស្រីឆ្លើយម្ដងទៀត?

**ឆ៖** ខ្ញុំឈ្មោះ មុំ វុន។

**ស៖** អរគុណលោកស្រី។ លោកស្រីកើតនៅថ្ងៃណា ខែណា ឆ្នាំណាដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កុំអាលទាន់ឆ្លើយ! មីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។ អ៊ីចឹងលោកស្រីអាយុប៉ុន្មានសព្វថ្ងៃនេះ ដល់សព្វថ្ងៃហ្នឹង?

**ឆ៖** អាយុ៦៧ ឆ្នាំខាល។

**ស៖** បច្ចុប្បន្នលោកស្រីរស់នៅទីកន្លែងណាដែរ?

**ឆ៖** កាលមុនខ្ញុំនៅសៀមរាប ដល់បច្ចុប្បន្ននេះខ្ញុំអត់មានអីនៅ ខ្ញុំទៅបន្ទាយមានជ័យ។

[១១:០០:១៥]

**ស៖** អរគុណលោកស្រី។ តើសព្វថ្ងៃលោកស្រីប្រកបមុខរបរអីដែរ?

**ឆ៖** ខ្ញុំនៅស៊ីឈ្នួលកាប់ដំឡូងឲ្យគេ ហើយហាលសណ្ដែកឲ្យគេ បានមួយថ្ងៃថវិកាមាន៣០០បាត។

**ស៖** អរគុណលោកស្រី។ តើឪពុកម្ដាយរបស់លោកស្រីឈ្មោះអីដែរ?

**ឆ៖** ម្ដាយឪពុកខ្ញុំឈ្មោះ មុំ ទឹម, ស្រី ម៉ោល ម្ដាយឈ្មោះ ស្រី ម៉ោល, ឪពុកឈ្មោះ មុំ ទឹម។

**ស៖** អរគុណលោកស្រី។ តើប្ដីលោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្ដីខ្ញុំឈ្មោះ តាន់ ហ៊ីង មានកូនប្រាំបីនាក់ តែស្លាប់អស់បី នៅមុនចិត--។

**ស៖** អរគុណលោកស្រី។ លោកស្រី មុំ វុន អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីមកផ្ដល់សក្ខីកម្មថ្ងៃនេះក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះ។ ហេតុដូច្នេះនៅចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោកស្រី ៗអាចមានសិទ្ធិធ្វើសេចក្ដីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខវេទនានិងស្ថានភាពព្យសនកម្ម មានន័យថា ផលអន្តរាយដែលកើតមានចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

តើលោកស្រីធ្លាប់ផ្ដល់សក្ខីកម្ម ឬផ្ដល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ហើយបើសិនបើបានធ្វើ ៗប៉ុន្មានដង ធ្វើនៅកន្លែងណាដែរលោកស្រី?

**ឆ៖** ខ្ញុំបានធ្វើនៅកន្លែងសំឡេងស្ត្រីខ្មែរ បានធ្វើតែម្ដងហ្នឹងទេ។

[១១:០២:១៦]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី។ ក្នុងស្នូរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិ

៨១ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសហមេធាវីនាំមុខ រួមជាមួយតំណាងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គ។

សូមអញ្ជើញមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី! សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមអនុញ្ញាតប្រគល់វេទិកានេះជូនលោកស្រីមេធាវី ជេត វណ្ណលី ដើម្បីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។

[១១:០៣:២៩]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំឈ្មោះ ជេត វណ្ណលី មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់នូវចំណុចមួយចំនួនក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ៧៥ ដល់៧៩។ លោកស្រី មុំ វុន តើនៅឆ្នាំ៧៥ លោកស្រីរស់នៅកន្លែងណា លោកស្រី?

**លោកស្រី មុំ វុន៖**

**ឆ៖** ក្នុងឆ្នាំ១៩៧៥ ខ្ញុំរស់នៅភូមិសង្កែមានជ័យ ឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប។

**ស៖** នៅពេលនោះលោកស្រីមានគ្រួសារទេ?

**ឆ៖** មានគ្រួសារ។

**ស៖** អរគុណលោកស្រី។ ប្តីលោកស្រីឈ្មោះអីដែរ?

**ឆ៖** ឈ្មោះ*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** សូមលោកស្រីចាំភ្លើងក្រហមចេញ ចាំឆ្លើយ។

**ឆ៖** ឈ្មោះ តាន់ ហ៊ឹង។

**ស៖** គាត់អាយុប៉ុន្មាន?

**ឆ៖** គាត់អាយុ ឆ្នាំកុរ។

[១១:០៥:០០]

**ប្រធានអង្គជំនុំ៖**

មេធាវី បើកមីក្រូហ្វូនផង!

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** គាត់អាយុប៉ុន្មានដែរលោកស្រី?

**លោកស្រី ម៉ុំ វុន៖**

**ឆ៖** អាយុប្រហែល៣៣ ពីអង្កាល់នោះ។ ហើយខ្ញុំអាយុប្រហែលជា២៨អីហ្នឹង។

**ស៖** អរគុណលោកស្រី។ តើប្ដីលោកស្រីធ្វើអីដែរនៅសម័យនោះ?

**ឆ៖** នៅសម័យនោះ ប្ដីខ្ញុំឡើងត្នោត។

**ស៖** ជាមួយនឹងប្ដីឈ្មោះ តាន់ ហ៊ឹង តើលោកស្រីមានកូនប៉ុន្មាននាក់ជាមួយឈ្មោះ តាន់ ហ៊ឹង?

**ឆ៖** ជាមួយនឹងលោក តាន់ ហ៊ឹង ខ្ញុំមានកូនប្រាំបីនាក់។

**ស៖** នៅរស់រហូតដល់សម័យខ្មែរក្រហមមែនទេលោកស្រី?

**ឆ៖** មុនៗៗរបបខ្មែរក្រហម គឺកូនខ្ញុំស្លាប់អស់បីនាក់។

**ស៖** មុនសម័យខ្មែរក្រហម លោកស្រីធ្វើអីដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីចាំមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហម ចាំឆ្លើយលោកស្រី។

**លោកស្រី ម៉ុំ វុន៖**

**ឆ៖** ខ្ញុំនៅផ្ទះ ធ្វើស្រែ។

[១១:០៧:០០]

**លោកស្រី ជេត វណ្ណលី៖**

**សៈ** អរគុណលោកស្រី។ ខ្ញុំបានឃើញនៅក្នុងឯកសារ 3/6307, ERN ខ្មែរលេខ 00532030 ហើយគ្មាន ERN ជាភាសាអង់គ្លេស និងភាសាបារាំងទេ បានបញ្ជាក់ថា នៅក្នុងសំបុត្រកំណើតរបស់លោកស្រី ។បានសរសេរថា លោកស្រីកើតនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៤២។ ដូច្នេះខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់តើឆ្នាំណាមួយដែលត្រឹមត្រូវពិតប្រាកដ? ព្រោះបើគិតពីឆ្នាំ១៩៤២ មកដល់ឥឡូវនេះលោកស្រីមិនមែនអាយុ៦៧ឆ្នាំទេ ដូច្នេះខ្ញុំសូមឲ្យលោកស្រីបញ្ជាក់ជូនអង្គសវនាការ។

**ឆៈ** ខ្ញុំអត់ដឹងថាខែឆ្នាំកំណើតនោះយ៉ាងណា ប៉ុន្តែខ្ញុំដឹងថាខ្ញុំឆ្នាំខាល ដូចជាដល់គេគិតទៅថា ដូចជា២០៤៨, ២៩៤៨ *(ស៊ុក)*អ៊ីចឹង ព្រោះខ្ញុំកើតឆ្នាំខាល ដឹងថាមកបច្ចុប្បន្ននេះ ខ្ញុំអាយុ៦៧ហើយ។

**សៈ** អ៊ីចឹងលោកស្រីគិតថា សំបុត្រកំណើតហ្នឹងមិនត្រឹមត្រូវទេមែនទេ?

**ឆៈ** មិនត្រឹមត្រូវទេ វាខុសនឹងឆ្នាំកំណើតរបស់ខ្ញុំ។

**សៈ** អរគុណលោកស្រី។ តើខ្មែរក្រហមចូលដល់ភូមិលោកស្រីនៅថ្ងៃណា ខែណា ឆ្នាំណា?

**ឆៈ** ខ្មែរក្រហមបានចូលដល់ភូមិខ្ញុំនៅឆ្នាំ១៩៧៥។

**សៈ** ខែប៉ុន្មានដែរលោកស្រី?

**ឆៈ** អត់ចាំ។

**សៈ** លោកស្រីនឹកមើល តើនៅមុនចូលឆ្នាំ ឬក្រោយចូលឆ្នាំពេលនោះ?

[១១:០៨:៥៦]

**ឆៈ** ចូលឆ្នាំ។

**សៈ** តើនៅក្នុងរបបខ្មែរក្រហម លោកស្រីត្រូវ--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអភ័យទោសបន្តិច សូមលោកស្រីមេធាវីកាត់បន្ថយឲ្យមានគម្លាតបន្តិច ព្រោះថាអ្នកបកប្រែគាត់ស្តាប់អត់ទាន់ទេ។ ដូច្នេះសូមឲ្យលោកស្រីទុកគម្លាតពីលោកស្រីមេធាវីទៅលោកស្រីដើមបណ្តឹងនិយាយឲ្យមានការផ្អាកបន្តិចនៅចន្លោះនីមួយៗ។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**សៈ** តើនៅក្នុងរបបខ្មែរក្រហម លោកស្រីត្រូវរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង តើគេឲ្យលោកស្រីធ្វើអីខ្លះ? ហើយគេបានធ្វើអីខ្លះ? ហើយមានហេតុការណ៍អីខ្លះដែលកើតឡើងចំពោះលោកស្រី?

**លោកស្រី មុំ វុន៖**

**ឆ៖** កាលដែលខ្មែរក្រហមចូលមកគេឲ្យខ្ញុំធ្វើការ ហើយដែលខ្ញុំកូនខ្ចី គេឲ្យកិនស្រូវ។ ហើយពីមុនដំបូងមក គេល្អជាមួយយើង តែទៅចូលដល់ គិតត្រឹមតែមួយខែ គេប្រមូលទ្រព្យសម្បត្តិយើងដាក់រួមទាំងអស់ អត់មានឲ្យសល់ទេ។ សូម្បីតែគោរក្របី មាស ប្រាក់អីគេប្រមូលទាំងអស់ អត់មានទុកទេ។ ហើយគេប្រើឲ្យកិនស្រូវ ប្រើឲ្យប្ដីឡើងត្នោតនៅក្នុងសហករណ៍។

[១១:១០:៣៨]

**ស៖** ក្រៅពីការងារនេះ តើលោកស្រីត្រូវគេឲ្យធ្វើអីទៀតទេ ចំពោះលោកស្រីផ្ទាល់?

**ឆ៖** កាលដែលកូនខ្ញុំនៅតូច គេឲ្យនៅកិនតែស្រូវហ្នឹងឯង។ អត់មានឲ្យទៅណាទេ នៅក្នុងសហករណ៍សិន។ លុះដល់កូនខ្ញុំស្លាប់ បានគេឲ្យខ្ញុំចល័តទៅលើកភ្លឺស្រែ។

**ស៖** អរគុណលោកស្រី។ ចុះឪពុកម្ដាយលោកស្រី បងប្អូនលោកស្រីនៅឯណាដែរ? ហើយធ្វើអីដែរ? ហើយត្រូវទទួលជួបនឹងហេតុការណ៍អីខ្លះ?

**ឆ៖** ឪពុកម្ដាយខ្ញុំ គាត់នៅជុំជាមួយខ្ញុំ ប៉ុន្តែនៅក្នុងពេលនោះ គេថាឪពុកខ្ញុំជាមេឃុំ ហើយគេហៅគាត់ឲ្យទៅរៀន ទៅបាត់ អត់ឃើញមកវិញ។ ហើយម្ដាយខ្ញុំក៏គាត់នៅនឹងផ្ទះជាមួយខ្ញុំ។

**ស៖** តើលោកស្រីអាចបញ្ជាក់បានទេ តើម្ដាយនុ៎ងនៅរស់ដល់សព្វថ្ងៃ ឬក៏យ៉ាងម៉េច? ហើយបងប្អូនលោកស្រីនៅរស់ដល់សព្វថ្ងៃមែនទេ?

**ឆ៖** គាត់ស្លាប់អស់ហើយ សព្វថ្ងៃអត់មាននៅទេ នៅសល់តែខ្ញុំម្នាក់ទេ។ ស្លាប់អស់បង ៗខ្ញុំក៏ស្លាប់ ៗទាំងអស់ អត់មាននៅសល់ទេ ហេតុការណ៍ដែលកើតឡើង។ បងខ្ញុំគេថា យើងរត់ទៅចូលខ្មាំង គេយកទៅសម្លាប់ទៅឆ្នាំ៧៧។

**ស៖** គេសម្លាប់បងលោកស្រីប៉ុន្មាននាក់ដែរ? ហើយគាត់ធ្វើអីដែរលោកស្រី?

**ឆ៖** គាត់ធ្វើ កាលនោះគេប្រើឲ្យគាត់ដឹងអង្ករ ហើយបងខ្ញុំក៏គាត់នៅខាងស្ទួងដកទៅ ទាំងបីនាក់ហ្នឹងឯង។ តែដល់រួចមក គេថាយើងចង់រត់ទៅចូលខ្មាំង គេស្នើឲ្យទៅរៀនទាំងបីនាក់ហ្នឹង អត់ឃើញមកវិញផង ទៅរៀនទៅរហូត អត់ឃើញមកផង។

**ស៖** ចុះម្ដាយលោកស្រី?

[១១:១៣:១២]

**ឆ៖** ម្ដាយខ្ញុំគាត់ឈឺស្លាប់តាមគ្នាពីក្រោយ។ គាត់ឈឺរីងរៃ ហើយគាត់ស្លាប់ ស្លាប់ដោយបាត់

កូន បាត់ប្ដីគាត់ អត់ឃើញមកវិញ គាត់ឈឺស្លាប់ទៅ។

**ស៖** ចុះប្ដីលោកស្រីទៅណាដែរ ឬក៏នៅរស់ជាមួយលោកស្រីរហូតមក?

**ឆ៖** ប្ដីខ្ញុំពាក់កណ្ដាលឆ្នាំ៧៥ គេស្នើឲ្យទៅរៀន ព្រោះគាត់ គេថាគាត់ហ្នឹងទាហាន លន់ នល់ តែតាមការពិតគាត់ស្រវឹងស្រា ក៏គាត់ចេះតែនិយាយថា ទាហាន លន់ នល់ ទាហានលន់ នល់ ដល់ពួកមិត្តគេឮ គេថាទាហានលន់ នល់ គេបើទាហានលន់ នល់ ហើយត្រូវតែទៅរៀន ដើម្បីមកបង្រៀនគេខាងក្រោយផង។ ដល់ទៅ ៗរហូត អត់ឃើញមកជួបប្រពន្ធវិញ រហូតដល់សព្វថ្ងៃ។

**ស៖** អរគុណលោកស្រី។ ក្រោយពីការបាត់ខ្លួនរបស់ប្ដីលោកស្រីហើយ តើលោកនៅមេម៉ាយរហូត ឬក៏លោកស្រីត្រូវរៀបការទៀត?

**ឆ៖** កាលដែលប្ដីខ្ញុំគេហៅរៀនផុត កន្លងផុតប្រហែលជាពីរខែ ឬក៏បីខែ មិត្តគេបានបង្ខំឲ្យខ្ញុំរៀបការ។ បង្ខំឲ្យរៀបការហើយ ខ្ញុំប្រកែកថា ខ្ញុំអត់រៀបការទេ ខ្ញុំខ្លាចប្ដីខ្ញុំមកវិញ។ អត់ការក៏ត្រូវតែការដែរ គេនិយាយបែបនេះ។

**ស៖** អរគុណលោកស្រី។ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរបស់លោកស្រី ដែលមានលេខ E3/6307 លោកស្រីមិនមាននិយាយអំពីការរៀបការលើកទី២ហ្នឹងទេ។ ហេតុអីបានជាលោកស្រីមិននិយាយពីអង្គហេតុនេះ ប្រាប់អ្នកសរសេរពាក្យបណ្ដឹងនៅតុលាការ ពេលនោះ?

[១១:១៥:២៨]

**ឆ៖** ព្រោះបានជាខ្ញុំអត់ហ៊ាននិយាយ ព្រោះខ្ញុំខ្មាសគេ។ រឿងរ៉ាវដ៏អាក្រក់នេះ ខ្ញុំអត់ហ៊ាននិយាយប្រាប់គេហើយ កាលណាដល់ គេហៅមកប្រជុំនៅភ្នំពេញ កន្លែង ធី.ភី.អូនោះ ហើយក្មេងនោះគេក្មេងជាងខ្ញុំផង គេហ៊ាននិយាយលាតត្រដាងរឿងហ្នឹង ហើយដល់ខ្ញុំ គេឮសួរថា អ្នកណាដែលគេបង្ខំរៀបការខ្លះ។ ខ្ញុំក៏លើកដៃថា ខ្ញុំ គេបង្ខំចិត្តឲ្យរៀបការដែរ។ ទៅ គេកត់ឡើងមក បានចូលមកកន្លែងនេះទៀត។

**ស៖** លោកស្រីនៅចាំទេ លោកស្រីរៀបការលើកទី២ ក្នុងរបបខ្មែរក្រហមហ្នឹង នៅខែណា ឆ្នាំណា លោកស្រីចាំទេ?

**ឆ៖** ខ្ញុំអត់ចាំខែទេ ប៉ុន្តែខ្ញុំចាំតែចុងឆ្នាំ៧៥។

**ប្រធានអង្គជំនុំ៖**

លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី កុំអាលទាន់ឆ្លើយ ចាំមីក្រូហ្វូនលោកស្រីដំណើរការសិន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោកស្រី មុំ វុន៖**

**ឆ៖** ខ្ញុំបានប្រកែកថា ខ្ញុំអត់រៀបការទេ ខ្ញុំខ្លាចប្ដីមកវិញ ព្រោះទើបតែហៅប្ដីខ្ញុំទៅ។ ឲ្យខ្ញុំរៀបការម៉េចបាន បើប្ដីខ្ញុំទើបតែនឹងទៅសោះ ហើយហៅខ្ញុំមករៀបការ ខ្ញុំអត់រៀបការទេ។ ហើយគេឆ្លើយមកខ្ញុំវិញថា "មិនរៀបការ ក៏ត្រូវតែរៀបការដែរ"។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ហើយអ្នកណាដែលប្រាប់លោកស្រីឲ្យរៀបការហ្នឹង?

[១១:១៧:០៥]

**ឆ៖** មេកង ប្រធានខ្សែគេ ឈ្មោះ មិត្តស៊ា គេប្រាប់ខ្ញុំឲ្យរៀបការហ្នឹង។ គេហៅខ្ញុំមកសួរ ត្រូវតែរៀបការហ្នឹង គេប្រាប់ហើយ គេដើរចេញទៅ។ ហើយខ្ញុំក៏ចេះតែភ័យហើយ ថាទៅការឯណា បើប្ដីទើបតែទៅបាត់មួយថ្ងៃណោះ ហើយតែដល់វិលមកវិញអីទៅ មិនកើតរឿងរ៉ាវធំហើយ អ៊ីចឹងចេះ តែដល់នេះទៅ នៅស្ងៀមទៅ។

**ស៖** ពេលដែលគេហៅលោកស្រីទៅ តើគេមានប្រាប់លោកស្រីថា ត្រូវរៀបការជាមួយអ្នកណាទេ? ឈ្មោះអី? នៅកន្លែងណា? ភូមិអី? ធ្វើអីគេ? គេមានប្រាប់ទេ លោកស្រី?

**ឆ៖** កាលណាដែលគេហៅខ្ញុំទៅ គេអត់មានប្រាប់ថា ឈ្មោះណាមួយ គឺអត់មានទេ។ គេបង្ខំឲ្យខ្ញុំរៀបការនោះ គឺអ្នកកងចល័តដូចគ្នា ប៉ុន្តែមិនដឹងថាមុខមួយណាផង អត់ដែលខ្ញុំស្គាល់គ្នារលីងសោះ។ ប៉ុន្តែគេថាត្រូវតែរៀបការហើយ បើមិនរៀបការទេ ខ្លាចស្លាប់។ ម្ល៉ោះហើយក៏ខ្ញុំសុខចិត្តថា រៀបការចុះ។ រៀបការដោយបង្ខំចិត្តតែម្ដង។

**ស៖** តើគេហៅលោកស្រីទៅប៉ុន្មានដង ឬហៅតែម្ដងទេ លោកស្រី?

**ឆ៖** គេមកប្រាប់តែម្ដងហ្នឹងទេ។ ទាល់តែដល់ថ្ងៃរៀបទៀត បានគេប្រាប់ទៀត។ ប៉ុន្តែមុននឹងមាន -- មុននឹងរៀបការហ្នឹង ហេតុការណ៍វាកើតឡើង គួរឲ្យឈឺចាប់ណាស់។ នៅតែពីរថ្ងៃទៀតទេ នឹងរៀបការ ប៉ុន្តែនៅពេលយប់ ម៉ោងប្រាំពីរហ្នឹង មានពួកមិត្ត គេមកហៅខ្ញុំទៅកន្លែងឃ្លាំងអង្ករហ្នឹង ប្រាំនាក់ ហើយខ្ញុំអត់ស្គាល់មុខគេ វាងងឹត ម៉ោងប្រហែលប្រាំពីរហើយ ធ្វើម៉េចមើល មានភ្លើងឯណានឹងមើលឃើញគេ។ គេហៅទៅ ទៅដល់គេប្រាប់ខ្ញុំថា មិត្តឯងនៅតែពីរថ្ងៃទៀតទេ រៀបការហើយ។ ឥឡូវឡើងមកចេះមក ខ្ញុំថា ឡើងទៅអី។ ខ្ញុំអត់មានឡើងទេ ខ្ញុំវិលទៅវិញ។ ដល់មួយនៅនឹងដីនោះ គេឆក់ដៃខ្ញុំឡើងទៅហើយ គេមានវិធានការនឹងធ្វើបាបខ្ញុំ មុនពេលដែលខ្ញុំរៀបការហ្នឹង។ គ្នាគេប្រាំនាក់ហ្នឹង គេ

នឹងចាប់រំលោភខ្ញុំ។ ម្នាក់ម្ដង ម្នាក់ម្ដងហើយ ដល់អ្នកចុងក្រោយបានប្រាប់ខ្ញុំថា ឆាប់ចុះទៅវិញ ហើយខ្ញុំស្ទើរតែនឹងក្រោកមិនរួច ចុះមកវិញទេ។ ខំដើរមកដល់កន្លែងហើយសុខចិត្តថាយំ ដល់ខ្ញុំអត់ស្គាល់មុខគេ គេហៅទៅយប់ ម្ល៉ោះហើយខ្ញុំក៏ខំអត់ធ្មត់សង្កត់ចិត្តថា ដើម្បីរស់កូនខ្ញុំ ខ្ញុំសុខចិត្តទ្រាំចុះ។

[១១:២០:២៩]

**ស៖** ពេលដែលគេហៅលោកស្រីទៅហ្នឹង គេមានសម្លុតគំរាមកំហែងអីលោកស្រីទេ ឬក៏គេដោយលោកស្រីបញ្ជាក់ថាគេរំលោភហ្នឹង គេធ្វើតាមសម្រួលឬក៏យ៉ាងម៉េច សូមលោកស្រីបញ្ជាក់មើល?

**ឆ៖** គេសម្លុត កាំភ្លើងគេភ្ជង់នៅជាប់ក្បាលខ្ញុំ។ ហើយគេឲ្យខ្ញុំដោះអាវឲ្យអស់ គេរំលោភ។ ដោះអាវដោះខោចេញឲ្យអស់ ដើម្បីគេរំលោភទាំងប្រាំនាក់ហ្នឹង ម្នាក់ម្ដង ម្នាក់ម្ដង ហើយគេចុះ គេគំរាមកំហែងខ្ញុំឲ្យតែប៉ាននិយាយគឺស្លាប់។ ម្ល៉ោះហើយខ្ញុំបិទ អត់និយាយរហូតមកដល់ឥឡូវនេះ។

**ស៖** អរគុណលោកស្រី។ តើលោកស្រីអាចដឹងទេថា អ្នកដែលរំលោភលោកស្រីហ្នឹងជាអ្នកណា? ហើយអាយុប្រហែលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំអត់ដឹងថា មុខគេជាអ្នកណាទេ ព្រោះងងឹតមើលអត់ឃើញ ប៉ុន្តែមនុស្សនោះតាមស្មានដែលមកនៅជិតខ្លួនខ្ញុំ ខ្ញុំស្មានថាមនុស្សត្រឹម២៦, ២៧តែប៉ុណ្ណឹងទេ ទាំងអស់គ្នាហ្នឹង។ ដោយមុខគេខ្ញុំអត់មើលឃើញទេ ព្រោះយប់នោះ អាកន្លែងឃ្លាំងអង្ករនោះ ជញ្ជាំងគេជិត ធ្វើម៉េចស្គាល់មុខគេ។

**ស៖** អរគុណលោកស្រី។ បន្ទាប់ពីហេតុការណ៍នេះហើយ លោកស្រីនៅតែព្រមរៀបការទៀតឬក៏យ៉ាងម៉េច?

[១១:២២:៣៦]

**ឆ៖** ខ្ញុំនៅតែរៀបការ ព្រោះគេគំរាមខ្ញុំថា ត្រូវតែរៀបការ ហើយរឿងរ៉ាវដែលកើតឡើងនោះគេថាបើសិនជាខ្ញុំនិយាយក៏ស្លាប់។ ខ្ញុំមិនរៀបការក៏ស្លាប់ ខ្ញុំខ្លាចស្លាប់ ដើម្បីកូនខ្ញុំ ខ្ញុំសុខចិត្តរៀបការទាំងទឹកភ្នែកហ្នឹងតែម្ដង។

**ស៖** អរគុណលោកស្រី។ ខ្ញុំចង់ឲ្យលោកស្រីដែរបញ្ជាក់ថា ហេតុអីក៏ការរំលោភដែលលោកស្រីទើបរៀបរាប់ប្រាប់អំមិញហ្នឹង លោកស្រីអត់បានប្រាប់នាក់ដែលលោកស្រីឲ្យគេសរសេរពាក្យប្ដឹងធ្វើជាដើមបណ្ដឹងនៅតុលាការ ក៏ដូចជានៅក្នុងវេទិកាស្ត្រី ឬនៅក្នុងអង្គភាព ធី.ភី.អូ លោកស្រី?

**ឆ៖** កាលនោះខ្ញុំអត់ប៉ាននិយាយ ខ្ញុំខ្មាសគេ។ ខ្ញុំលាក់ទុករហូតមកដល់ថ្ងៃនេះ ខ្ញុំអត់ដែលនិយាយប្រាប់អ្នកណាសូម្បីតែមួយម៉ាត់។ បើខ្ញុំនិយាយប្រាប់គេទៅខ្ញុំខ្មាសគេ ម្ល៉ោះហើយខ្ញុំទុក ៗដល់

មកឡើង មកដល់កន្លែងនេះ ខ្ញុំនឹងនិយាយឲ្យអស់បងប្អូនរួមជាតិ អង្គការពិភពលោកទាំងអស់ឲ្យដឹងថា គេប្រព្រឹត្តមកលើរូបខ្ញុំបែបនេះមែន។

**ស៖** អរគុណលោកស្រី។ ឥឡូវយើងឆ្លងទៅដល់ការរៀបការ លោកស្រីបានបញ្ជាក់ហើយថា លោកស្រីនៅតែសម្រេចចិត្តរៀបការដដែល ព្រោះខ្លាចគេសម្លុត គេសម្លាប់ណា។ ខ្ញុំចង់បញ្ជាក់សួរលោកស្រីដែរថា ពេលដែលលោកស្រី មុនលោកស្រីរៀបការហ្នឹង លោកស្រីមានសួរកូនចៅអីលោកស្រីទេ ឬក៏ម៉ែឪអីទេមុននឹងសម្រេចចិត្តរៀបការ?

[១១:២៤:៤១]

**ឆ៖** មុននឹងសម្រេចចិត្តរៀបការ គឺអត់មានប្រាប់ម៉ែឪ កូនចៅ បងប្អូនណា ក៏អត់មានដឹងដែរ ព្រោះគេបង្ខំឲ្យរៀបការនេះ គេចាប់ដាក់រៀបការតែម្តង ព្រោះអ្នកដែលសាមីខ្លួនខាងប្រុសក៏ខ្ញុំអត់បានស្គាល់គេ ហើយខ្ញុំ -- គេខាងណោះក៏អត់មានស្គាល់ខ្ញុំ។ ហើយរៀបការនេះមិនមាន ១ច្បាប់ទម្លាប់អីសមរម្យនឹងរៀបការទេ ព្រោះអត់មានរៀបការនៅកន្លែងផ្ទះសម្បែងអីផង ការនៅកន្លែងការដ្ឋានសោះហ្នឹង។

**ស៖** អរគុណលោកស្រី។ ចុះខាងបុរសវិញ លោកស្រីមានដឹងថាគេពេញចិត្តលោកស្រីទេ?

**ឆ៖** នៅខាងប្រុស គេអត់ពេញចិត្តខ្ញុំទេ ព្រោះកាលដែលពួកមិត្តមកនិយាយប្រាប់ខ្ញុំថា ខាងប្រុសគេអត់ពេញចិត្តទេ ប៉ុន្តែតែត្រូវតែការ ព្រោះខាងស្រីមានកូនដល់ទៅប្រាំបីហើយ គេខាងប្រុសគេនៅយុវ័ន ធ្វើម៉េចគេយក គេមិនយកទេ។ ប៉ុន្តែអត់យកក៏ត្រូវតែយកដែរ គេអត់ពេញចិត្ត ខ្ញុំក៏អត់ពេញចិត្តគេ គេក៏អត់ពេញចិត្តខ្ញុំ ប៉ុន្តែគេបង្ខំឲ្យខ្ញុំការ ដើម្បីកូនខ្ញុំៗត្រូវតែការ ដើម្បីឲ្យកូនខ្ញុំបានរស់ជួបខ្ញុំផង។

**ស៖** អរគុណលោកស្រី។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ដែរថា តើលោកស្រីបានបញ្ជាក់ថាអ្នកដែលបង្ខំឲ្យលោកស្រីរៀបការហ្នឹងគឺ មិត្តស៊ា តើ មិត្តស៊ា នោះជាអ្នកណា លោកស្រី? ហើយពេលដែលគាត់បង្ខំលោកស្រីហ្នឹង តើគាត់ប្រាប់ពីមូលហេតុអីដែលត្រូវឲ្យលោកស្រីរៀបការ? គាត់មានបញ្ជាក់ពីមូលហេតុទេ?

[១១:២៦:៤៣]

**ឆ៖** គាត់អត់មានបញ្ជាក់ផង គាត់ដឹងតែហៅមករៀបការបណ្តោយ។ ហើយអ្នកដែលកងចល័តដែលអ្នកគូដែលរៀបការជាមួយខ្ញុំនោះ ក៏គាត់អត់បានដឹងដែរ ប៉ុន្តែដល់គេទៅប្រាប់ថា ត្រូវតែរៀបការហើយ ក៏រៀបការទៅ។ អត់មានបញ្ជាក់ អត់មានសួរថាយ៉ាងណាទេ គាត់អាងគាត់ជាមេកង

ហើយ ក៏គាត់ធ្វើតាមទំនើងចិត្តរបស់គាត់ ៗអ្នកធំហើយ យើងជាអ្នកប្រជាជនដែលរែកដីខ្លាំងនេះក៏គេចង់ធ្វើអី ក៏ធ្វើតាមចិត្តគេទៅ មិនបានប្រាប់អ្នកណាទាំងអស់។

**ស៖** អរគុណលោកស្រី។ តើលោកស្រីមានដឹងទេថា បើសិនជាយើងបដិសេធ តើវានឹងមានអ្វីកើតឡើងចំពោះយើង?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមជំទាស់សំណួរនេះ ពីព្រោះមិនត្រូវឲ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការសន្និដ្ឋានក្នុងកាលៈទេសៈដែលមិនមានកើតនោះទេ។ បាទ សូមអរគុណ។

**លោកស្រី ជេត វណ្ណលី៖**

ខ្ញុំនឹងប្ដូរសំណួរនេះឡើងវិញ។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** លោកស្រី តើលោកស្រីដឹងទេមានគូណាដែលបដិសេធទេ ក្រៅពីលោកស្រី?

[១១:២៨:០៩]

**លោកស្រី មុំ វុន៖**

**ឆ៖** គូដែលត្រូវបដិសេធ វាមានដូចគ្នា ក៏ប៉ុន្តែមិនអាចបដិសេធបាន ក៏ត្រូវតែធ្វើ ដូចតែគ្នាហ្នឹង។ បើសិនជាខាងស្រីបដិសេធ ខាងស្រីនឹងស្លាប់ បើខាងប្រុសបដិសេធ ខាងប្រុសនឹងស្លាប់។ វាដូចតែគ្នា គូវាទាំងពីរនេះ វាដើរស្មើគ្នាទាំងអស់។ ដោយមិនប៉ានប្រកែក មិនប៉ានតវ៉ា គឺខ្លាចតែរឿងមួយហ្នឹង គឺខ្លាចតែរឿងស្លាប់ហ្នឹងតែម្ដង។

**លោកស្រី ជេត វណ្ណលី៖**

អរគុណលោកស្រី។ លោកប្រធាន ដោយសារពេលវេលាដល់ តើខ្ញុំត្រូវសួរតទៅទៀត ឬក៏យើងសូមផ្អាកសិនចាស?

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការ

សវនាការ។

អង្គជំនុំជម្រះសូមអញ្ជើញលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញ ឲ្យបានមុនម៉ោងមួយកន្លះរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១១:២៩ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អញ្ជើញលោកស្រីមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបន្តសំណួរ!

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។ នាងខ្ញុំសូមបន្តសំណួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីតទៅទៀត។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** លោកស្រីដើមបណ្ដឹង ពីព្រឹកមិញ លោកស្រីបានបញ្ជាក់ពីការដែលគេហៅលោកស្រីដើម្បីឲ្យឡើងមករៀបការ។ ខ្ញុំចង់បញ្ជាក់សួរលោកស្រី ថាតើគេឲ្យដឹងដំណឹងលោកស្រីប៉ុន្មានថ្ងៃមុននឹងរៀបការហ្នឹង?

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស គេឲ្យដំណឹងខ្ញុំពីរថ្ងៃ ដល់ថ្ងៃរៀប។

**ស៖** ហើយអ្នកណាជាអ្នកឲ្យដំណឹងហ្នឹងលោកស្រី?

**ឆ៖** មេកង មិត្តស៊ា ហ្នឹងអ្នកឲ្យៗដំណឹង ថ្ងៃរៀបការនៅពីរថ្ងៃទៀតរៀបការ។

[១៣:៣១:០៤]

**ស៖** អរគុណលោកស្រី។ លោកស្រីអាចបញ្ជាក់ប្រាប់បានទេថា រយៈពេលដែលគេកំណត់ថ្ងៃ

រៀបការហ្នឹង គឺប្រហែលជានៅឆ្នាំណា ខែណាលោកស្រី?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ចាំមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហមសិន ចាំលោកស្រីឆ្លើយ។

**លោកស្រី មុំ វុន៖**

**ឆ៖** នៅក្នុងចុងឆ្នាំ៧៥ ដែលថ្ងៃរៀបការខ្ញុំ។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** អរគុណលោកស្រី។ នៅថ្ងៃរៀបការហ្នឹង ឥឡូវយើងចូលមកដល់ថ្ងៃរៀបការណ៎ា ឥឡូវនៅថ្ងៃរៀបការហ្នឹង លោកស្រី គេធ្វើពិធីហ្នឹងនៅកន្លែងណាលោកស្រី?

**ឆ៖** គេធ្វើពិធីការនេះនៅការដ្ឋានបែកឃ្លោក ការដ្ឋានវែកដីហ្នឹង គេមិនមែនរៀបការនឹងផ្ទះទេ គេរៀបការកន្លែងការដ្ឋានវែកដីនៅបែកឃ្លោក។

**ស៖** តាមដែលលោកស្រីនៅចាំ តើចំនួនអ្នកដែលត្រូវរៀបការហ្នឹងប៉ុន្មានគូដែរលោកស្រី?

**ឆ៖** ចំនួនមនុស្សដែលរៀបការក្នុងការដ្ឋានបែកឃ្លោកហ្នឹង ចំនួន៦០គូក្នុងមួយថ្ងៃហ្នឹងដែលគេត្រូវរៀបការ ហើយមានផ្កាពីរថ្ងដាក់ពីខាងមុខ ហើយមានមាន់មួយប៉ុណ្ណឹង។

[១៣:៣៣:៤៧]

**ស៖** អរគុណលោកស្រី។ ខ្ញុំឃើញនៅក្នុងឯកសារលេខ E3/7234 ជាភាសាខ្មែរលេខ 01003 335, ជាភាសាអង់គ្លេសលេខ 01077096 និងជាភាសាបារាំងលេខ 01030451 ដែលនៅក្នុងនោះលោកស្រីបានធ្វើសក្ខីកម្មនៅកន្លែងអង្គការ ធី.ភី.អូ ហើយនិងអង្គការសំឡេងស្ត្រី លោកស្រីបានបញ្ជាក់ថាមាន៤០គូ។ ហើយនៅកន្លែងសំឡេងស្ត្រី លោកស្រីបានបញ្ជាក់ថា៦០គូ។ ខ្ញុំចង់ឲ្យលោកស្រីនឹកឡើងវិញមើល តើចំនួនពិតប្រាកដប៉ុន្មានទៅ?

**ឆ៖** ចាស កន្លែងដែលរៀបការខ្ញុំ កន្លែងបែកឃ្លោកហ្នឹងគឺ៦០គូ នៅកន្លែងរហាលព្រួលហ្នឹង ៤០គូ វាមានពីរកន្លែង។ តែបញ្ជាក់ កន្លែងខ្ញុំគឺ៦០១គូ។

**ស៖** អរគុណលោកស្រី។ នៅថ្ងៃរៀបការហ្នឹង លោកស្រីមានអារម្មណ៍យ៉ាងម៉េចដែរ សប្បាយ

ចិត្ត រំភើប ឬក៏យ៉ាងម៉េចដែរលោកស្រី អារម្មណ៍របស់លោកស្រី?

**ឆ៖** អារម្មណ៍របស់ខ្ញុំអត់មានសប្បាយ គឺខ្ញុំភ័យហើយខ្ញុំខ្លាច ហើយខ្ញុំខ្លាចប្ដីវិលមកវិញ។ ដល់ថ្ងៃរៀបការហ្នឹង ខ្ញុំអត់មានសប្បាយចិត្តទេ ព្រោះខ្ញុំអត់ស្រឡាញ់ ខ្ញុំអត់សប្បាយទេ ព្រោះបង្ខំខ្ញុំឱ្យរៀបការតែម្ដង។

**ស៖** តើនៅថ្ងៃរៀបការហ្នឹង លោកស្រីមានបានត្រៀមខោអាវ ស្បែកជើង ឬក៏ត្រៀមក្នុងការរៀបការចំពិធីហ្នឹងម៉េចដែរទេ?

[១៣:៣៥:៥៣]

**ឆ៖** ចាស នៅពិធីរៀបការហ្នឹងខ្ញុំអត់មានខោអាវត្រៀមទេ មានតែខោអាវដែលស្លៀកពាក់រែកដីហ្នឹងឯង ទៅអង្គុយនៅជាជួរ ជាជួរនឹងគ្នា។ មានតែប៉ុណ្ណឹងទេ អត់មានស្បែកជើង អត់មានខោអាវថ្មីហូលផាមួងអីទេ មានតែខោអាវដែលរែកដីហ្នឹងឯងហៅទៅ។

**ស៖** ពេលដែលលោកស្រីមកដល់កន្លែងរៀបការ តើគេរៀបចំរបៀបម៉េច? លោកស្រីសូមរៀបរាប់បន្តិចមើល អង្គុយរបៀបម៉េច អីរបៀបម៉េច? ហើយមានគណៈអធិបតី ឬថ្នាក់ដឹកនាំណាចូលរួមទេលោកស្រី?

**ឆ៖** ចាសនៅកន្លែងរៀបការហ្នឹង ដោយពួកក្រុមស្រី មិត្តនារីហ្នឹងឈរដោយឡែក ដោយឡែក។ ដល់គេហៅឈ្មោះ គេហៅឈ្មោះឱ្យឡើង គូណាត្រូវនឹងគូណា គេឱ្យយើងអង្គុយតាមជាគូ ជាគូរ។ តែក្នុងមួយជួរ១៥គូ, បួនជួរ៦០គូ។ គូដែលស្រឡាញ់គឺគេហៅឈ្មោះ ចាប់ដៃអង្គុយ ចាប់ដៃអង្គុយ អត់មានកៅអីអង្គុយអ៊ីចឹងទេ យកស្បែកជើងហ្នឹងទ្រាប់អង្គុយទៅ គណៈអធិបតីគេក៏នៅខាងមុខទៅ យើងក៏អង្គុយនឹងដីនេះឯងទៅ អត់មានកៅអីអង្គុយទេ។

**ស៖** តើលោកស្រីនៅក្នុងគូទីប៉ុន្មានដែរ?

**ឆ៖** ខ្ញុំនៅគូទី៦ ដែលគេហៅមកឱ្យអង្គុយនៅគូទី៦ រៀបចំអង្គុយខ្លួនឯង។

**ស៖** អរគុណលោកស្រី។ ពេលហ្នឹងលោកស្រីបានឃើញគូដែលត្រូវលោកស្រីចាប់ដៃហើយមែនទេ? ហើយលោកស្រីប៉ាន់ស្មានមើល គូហ្នឹងគូដែលរបស់លោកស្រីហ្នឹង គេមានប្រកាសឈ្មោះអីទេប្រាប់លោកស្រីទេ? ហើយអាយុប្រហែលប៉ុន្មានដែរគូរបស់លោកស្រីហ្នឹង?

[១៣:៣៨:១០]

**ឆ៖** ចាស គេប្រកាសហៅឈ្មោះតើ។ គេហៅឈ្មោះ អ៊ុន ធិន ជាគូនឹងមិត្តនារី មុំ វុន គេហៅ

អ៊ីចឹង។ ដល់ហើយមកចាប់ដៃគ្នា ហើយក៏រៀបចំដាក់អង្គុយទៅ យកស្បែកជើងទ្រាប់អង្គុយទៅ។ ជាគូជាគូហ្នឹងគ្នាទៅ ហើយបានគេហៅគូផ្សេងទៀតមក។

**ស៖** នៅក្នុងពិធីនោះ តើលោកស្រីបានឃើញកម្មាភិបាលណាខ្លះដែលចូលរួមជាគណៈអធិបតីនៅក្នុងពិធីរៀបការហ្នឹងលោកស្រី?

**ឆ៖** ជាគណៈអធិបតី គឺមានកម្មាភិបាលមាន មិត្តរ៉ុម, មិត្តសន និងមិត្តស៊ា, បី ខុសពីនោះសុទ្ធតែក្រុមកងការពារគេទាំងអស់។ ពួកមិត្តៗគេនៅអង្គុយនៅនោះទាំងអស់គ្នា។ ហើយខុសពីនោះសុទ្ធតែគូដែលរៀបការនោះឯង ៦០គូ មានតែប៉ុណ្ណឹងទេ អត់មានម៉ែមានឪអីទៅចូលរួមទេ។

**ស៖** តើក្នុងការបើកពិធីរៀបការនេះ កម្មាភិបាលដែលចូលរួមហ្នឹងបាននិយាយអ្វីខ្លះ ណែនាំដល់គូស្រករថ្មីថ្មោងទាំងអស់ហ្នឹង?

**ឆ៖** ចាស កម្មាភិបាលដែលគេរៀបការឲ្យទាំង៦០គូហ្នឹង គេមានភារកិច្ចគេឡើងប្រកាសប្រាប់ថា គូស្រករដែលរៀបថ្មីជាប្ដីប្រពន្ធហើយនេះ ត្រូវចេះស្រឡាញ់គ្នា មើលថែរក្សាគ្នា ហើយខំបង្កបង្កើនផលឲ្យបានច្រើន ដើម្បីយើងយកសេដ្ឋកិច្ចនេះ ដើម្បីកម្ទេចខ្មាំងកុំឲ្យមានសល់ ហើយនិងខំបង្កបង្កើតផលកូនឲ្យបានច្រើនឲ្យអង្គការ។ ដល់រួចហើយ គេប្រកាសតែប៉ុណ្ណឹងទៅហើយ ក៏គេអង្គុយ។ ដល់រួចហើយ គេហៅគូ គូៗដែលប្ដីប្រពន្ធ ប្ដីប្រពន្ធដែលរៀបហ្នឹង ឲ្យឡើងមានការចាប់អារម្មណ៍ឲ្យគេស្ដាប់។

**ស៖** តើគូមួយៗដែលឡើងចាប់អារម្មណ៍ហ្នឹង មានខ្លឹមសារម៉េចដែរ? លោកស្រីនិយាយម៉េចពីអ្នកដែលឡើងចាប់អារម្មណ៍?

[១៣:៤០:៣៥]

**ឆ៖** នៅពេលនោះ ដែលគូរបស់ខ្ញុំដែលគេឲ្យឡើងនោះថា ហើយគាត់ដែលខាងសាមីខ្លួនខាងប្រុសហ្នឹង គាត់ឡើងហើយ គាត់ប្ដេជ្ញាចិត្តថា គាត់នឹងនៅថែរក្សាគ្នា ស្រឡាញ់គ្នាអស់មួយជីវិត ហើយនិងខំបង្កបង្កើនផលឲ្យបានច្រើន ១ហិកតាឲ្យបាន៣តោន។ ដល់រួចហើយ គាត់ថាគាត់នឹងខំថែរក្សា ឲ្យមានកូនឲ្យបានច្រើន ដើម្បីឲ្យអង្គការ បម្រើអង្គការ តែប៉ុណ្ណោះទេ។ ហើយចំណែកខ្ញុំវិញ ក៏ឡើងទៅ ក៏និយាយដូចតែគ្នា អត់មាននិយាយខុសគ្នាទេ។ ប្រឹងនិយាយថា ខ្ញុំខំប្រឹងធ្វើការងារ ដើម្បីធ្វើស្រែឲ្យបានច្រើន ១ហិកតាឲ្យបាន៣តោន ឲ្យអស្ចារ្យ មហាលោតផ្លោះក្នុងសម័យនោះ។ ហើយខ្ញុំក៏បានប្ដេជ្ញាចិត្តថា ខ្ញុំនឹងឲ្យមានកូនឲ្យបានច្រើន ដើម្បីធ្វើកងទ័ពបដិវត្ត ឲ្យបានច្រើនទៀត ថាយ៉ាងចេះ។

**ស៖** អរគុណលោកស្រី។ លោកស្រីអាចបញ្ជាក់បានទេថា គូស្រករដែលរៀបការនៅពេលនុ៎ង

មានអាយុប្រហែលប៉ុន្មានដែរ ខ្ពង់ប្រហែលប៉ុន្មាន?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី រង់ចាំមីក្រូហ្វូនប្រតិបត្តិការសិន។

**លោកស្រី មុំ វុន៖**

**ឆ៖** ខ្លះណាក៏ប្រហែលអាយុ២៥ ខ្លះណាក៏២០ ប្រហែល២០ទៅ ខ្លះណាក៏ប្រហែល២៦, ២៧ អ៊ីចឹងទៅ គ្រប់រូប។

[១៣:៤២:២១]

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**សៈ** ហើយពិធីរៀបការនេះ លោកស្រីបានរៀបចំចាប់ពីម៉ោងប៉ុន្មាន? ហើយចប់នៅពេលណាដែរ? ហើយមានពិធីជប់លៀង មានភ្លេងភ្លាត់អីទេ លោកស្រី?

**ឆ៖** ក្នុងពិធីរៀបការនេះ អត់មានភ្លេងភ្លាត់អីទេ។ មានតែពួកមិត្តទាំងអស់គ្នា ដែលរៀបការហ្នឹងឯង អត់មានភ្លេង អត់មានអាចារ្យ អត់មានលោក មានអីទេ។ ៦០គូ ទៅរកលោកមកពីណាមក បើមួយជំនាន់នោះ អត់មានលោកផង ទៅការឯណា មានលោកនោះ។ បើការមួយគូ មួយគូទៅ វាមានលោក បើការដល់៦០គូ មានលោកមកពីណា។ ដែលគេបង្ខំឲ្យរៀបការ ចេះតែចាប់ដាក់ទៅ អត់ស្គាល់គ្នាសោះ ក៏តែចាប់មក មិនថាអ្នកជើងជាដៃជា សូម្បីតែពិការក៏ដោយ។ អ្នកពិការកំបុតជើងទៅ គេការឲ្យអ្នកជើងល្អទៅ។ គេបង្ខំបែបនេះឯង។ ម្ល៉ោះហើយក៏រៀបការទាំងទឹកភ្នែកហ្នឹងឯងទៅ។ មិនអាចប្រកែកបាន តែប្រកែកគឺចប់។

**សៈ** អរគុណលោកស្រី។ ឥឡូវយើងឆ្លងចូលទៅដល់ក្រោយពិធីរៀបការ។ ឥឡូវពិធីរៀបការយើងឃើញថា វាដូចជាចប់ហើយណ៎ា ប៉ុន្តែក្រោយពិធីរៀបការរួច តើគេឲ្យលោកស្រីធ្វើអីទៀត?

[១៣:៤៣:៤៦]

**ឆ៖** ក្រោយពិធីរៀបការរួច គេឲ្យ – ម៉ោងបីហ្នឹងគេឲ្យខ្ញុំទៅផ្ទះ តែមិនមែនផ្ទះយើងមែនទែនទេ ផ្ទះនៅកន្លែងការដ្ឋានហ្នឹងណ៎ា។ គេឲ្យទៅផ្ទះ គេឲ្យទៅផ្ទះហើយ ក្នុងមួយពេលយប់ហ្នឹង គេឲ្យយើងដេកនៅកន្លែងហ្នឹង អត់ឲ្យមានទៅណាទេ។ គេឲ្យយើងដេកហើយ យើងអត់ដឹងខ្លួនថា ឈ្លបគេតាមដានយើងយ៉ាងម៉េច យ៉ាងម៉េចគឺអត់ដឹងទេ។ ប៉ុន្តែគូភាគីប្ដីប្រពន្ធខ្ញុំទាំងពីរនេះ បាននិយាយថា យើង

ការ ៗសិនទៅ បើស្រុកស្រួលបួល ចាំយើងសុំបែកគ្នា។ និយាយអ៊ីចឹងទៅ អត់ដឹងថាឈ្លបគេនៅក្រោមផ្ទះទេ។ ដល់ឈ្លប គេឮសួរថាអ៊ីចឹង គេឡើងភ្លែតមក ស្រមកបីនាក់បណ្ដោយ។ ឡើងមកបីនាក់ហើយគេថា មិនព្រមទៀត នៅចាំបែកគ្នាដល់ណាទៀត។ រួចមក គេយកកាំភ្លើងមកភ្ជង់ ដោះអាវ ខាងប្រុសក៏ដោះអាវ ខាងស្រីក៏ដោះអាវឲ្យអស់ ដើម្បីរួមដំណេកជាមួយគ្នា។ គេកម្មាភិបាល គេឈ្លប គេមានពិលដល់ហើយ ទាំងពីរនោះក៏ដោះអាវ ដោះខោទៅតាមគេ ចុះគេមានកាំភ្លើង យើងអត់ ទៅស៊ូនឹងម៉េចរួច។ ហើយដោះខោដោះអាវហើយ។ ដល់រួចហើយមិនព្រមនឹងដេកជុំគ្នាទេ។ ដល់រួចហើយ ដល់វាថាឲ្យឆាប់ដេកជាមួយគ្នា។ រួចហើយវាឆ្លួលពិល វាឆ្លួលពិល មើលយើងហើយ វាចាប់ប្រដាប់ប្រដាមនុស្សប្រុសដាក់មកជាមួយយើង។ វាដូចចាប់ដាក់បាយជ្រូកអ៊ីចឹង។ ខ្ញុំមានសេចក្ដីខ្មាសអៀនយ៉ាងខ្លាំង។ ដល់ក្មេងអាយុប៉ុណ្ណឹងហើយ វាហ៊ានធ្វើប្រព្រឹត្តមកលើយើងអាយុច្រើនជាងវា។ ដល់អាកាលណាវាបំណងវាបានធ្វើរួចសម្រេចហើយ វានិយាយថា "ទៅ! យើងទៅតាមអាខាងនោះទៀត អាខាងនេះវាចុយគ្នាបានហើយ យើងទៅខាងនោះទៀត។" នេះខ្ញុំសូមប្រាប់ភាពអាម៉ាស់នេះ ខ្ញុំចាំមួយជីវិត ខ្ញុំចងចាំទាល់តែខ្ញុំស្លាប់ ក៏ខ្ញុំអត់ភ្លេចដែរ។

**ស៖** សម្រួលតវិយាបថបន្តិចទៅលោកស្រី។ តើលោកស្រីអាចរៀបរាប់បន្តទៀតបានទេ?

[១៣:៤៦:១៩]

**ឆ៖** អាចរៀបរាប់បន្តទៅទៀតបាន។ តែគេតាមដានខ្ញុំហ្នឹង មិនមែនតាមតែមួយយប់ហ្នឹងទេ។ គេតាមមួយយប់ហ្នឹង យើងបានសម្រេចហើយ ថ្ងៃស្អែកក៏គេមកទៀត។ គេមកហើយ ពួកខ្ញុំដឹងថាពួកគេមក ខ្ញុំដេកឱបគ្នា។ ដល់ដេកឱបគ្នាហើយ "ថាឥឡូវវាព្រមគ្នាហើយ យើងទៅខាងនោះទៀត" ប៉ុន្តែអត់ដឹងទៅខាងណាទេ គេថាតែទៅខាងនោះ។ ដល់គេទៅបាត់ហើយ ក៏នាំគ្នាដេកទៅ ស្ងាត់ស្ងៀម។ យប់ ពីរយប់ហើយ។ ដល់បីយប់មកទៀត បីយប់មកទៀត ឆ្លួលពីជណ្ដើរមើលទៅ ឃើញតែដេកឱប។ ម្ល៉ោះហើយថា "ឥឡូវស្រុះស្រួលហើយ យើងទៅទៀត" វាថាស្រុះស្រួលហ្នឹង អាឆ្លួលពិលបីយប់ហ្នឹងវាមករួចហើយ។ ដល់ក្រោយមកទៀត បីយប់ទៀតហ្នឹង វាមកស្ដាប់នៅក្រោមផ្ទះ តើព្រមឬក៏អត់។ ដល់មកដេកស្ងាត់ស្ងៀម វាថា "អត់អីទេទៅ យើងទៅវិញ ទៅកន្លែងផ្សេងទៀត"។ អានេះនិយាយពីរឿងដែលយើងរៀបចំរួចហើយ វាបានសម្រេចរបស់បំណាច់របស់វាហើយ វាតាមដានយើង វាឈប់។ ហើយកាលណាដល់វាមានកូន ដល់ខ្ញុំមានកូន ដល់មានកូនហើយនេះ វាត្រូវបំបែកប្តីឲ្យទៅឆ្ងាយទៀត។ បំបែកប្តីទៅឲ្យឆ្ងាយ អត់ឲ្យជួបគ្នាទេ។ ក្នុងពីរខែឲ្យមកជួបគ្នាតែម្ដងទេ។ នេះប៉ុណ្ណឹងឯង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** អរគុណលោកស្រី។ តើលោកស្រីនៅចាំទេ អ្នកដែលមកហ្នឹង លោកស្រីបានបញ្ជាក់ហើយថា មានគ្នាបួននាក់ ម្នាក់នៅខាងក្រោម បីនាក់ឡើងទៅលើ។ ហើយលោកស្រីមាននៅចាំឈ្មោះអ្នកទាំងនោះទេ?

[១៣:៤៨:០៥]

**ឆ៖** ឈ្លបទាំងបួននោះ ដែលគេមកយប់នោះ ខ្ញុំអត់បានចាំឈ្មោះគេទេ ព្រោះគេផ្លាស់ប្តូរ ផ្លាស់ប្តូរជារៀងរាល់ថ្ងៃ ព្រោះខ្ញុំអត់បានចាំឈ្មោះគេទេ។ តែពេលយប់គេចេញមកហើយ យើងដឹងថាគេឈ្លប ប៉ុន្តែមិនដឹងមួយណា ចុះអត់មានចង្កៀង មានភ្លើងអីនោះ ងងឹតតែសូន្យ មានពិលតែគេហ្នឹងឯង គេច្របាច់មើលយើងតែប៉ុណ្ណោះឯង។

**ស៖** ហើយពួកគេហ្នឹង ប្រហែលជាអាយុប្រហែលជាប៉ុន្មានដែរ លោកស្រី? ហើយគេមានកាំភ្លើងទេ?

**ឆ៖** អាយុគេប្រហែលជា១៦, ១៧ ឈ្លបហ្នឹង ព្រោះយប់មើលវាអត់ច្បាស់ផង អីផងទៅ អានេះទៅតាមការស្មានអាយុទេ។ គេមានកាំភ្លើង ហើយយើងអត់កាំភ្លើង ត្រូវតែខ្លាចគេតែរហូតហ្នឹង។ របស់ងាប់ និងរបស់រស់សុខចិត្តនៅរស់ហើយ មិនឱ្យគេបាញ់ទេ សុខចិត្តទៅយ៉ាងណា ក៏យ៉ាងអីចុះទៅឱ្យតែវាបានរស់។

**ស៖** ខ្ញុំចង់ -- តើលោកស្រីអាចបញ្ជាក់បានទេថា ការតាមដានហ្នឹងវាតាមដានតែចំពោះគូស្វាមីលោកស្រី ឬក៏ចំពោះគូផ្សេងទៀតដែរ ដែលរៀបការនៅថ្ងៃនោះ?

**ឆ៖** រឿងហ្នឹងខ្ញុំក៏អត់ដឹងដែរ ប៉ុន្តែគេតាមដានខ្ញុំរួចហើយ ដែលខ្ញុំដេកជាមួយគ្នារួចហើយ បានគេថា "ឥឡូវវាសម្រេចហើយ យើងទៅខាងនោះទៀត"។ គេទៅតាមតែរហូតហ្នឹងឯង បើគេថាគេទៅចប់ពីខាងណេះហើយ គេទៅខាងនោះទៀត គេតាមតែរហូតហ្នឹងឯង តែតាមស្មានមើលទៅនោះ។

**ស៖** អរគុណលោកស្រី។ ខ្ញុំចង់ឱ្យលោកស្រីបញ្ជាក់ដែរថា តើចំពោះប្តីទី២ របស់លោកស្រីដែលលោកស្រីត្រូវគេបង្ខំឱ្យគេរៀបការនេះ តើលោកស្រីរួមរស់នៅជាមួយគ្នារហូតដល់ពេលដែលដល់ឆ្នាំ៧៩ ឬក៏ក្រោយមកបែកគ្នាលោកស្រី?

[១៣:៥០:៣៧]

**ឆ៖** ចាស ខ្ញុំការប្តីទី២ ដែលមនុស្សយើងអត់ស្រឡាញ់គ្នាហ្នឹង ខ្ញុំនៅរស់រហូតដល់៧៩។ ៧៩ ហើយឆ្លងទៅដល់ឆ្នាំ៨២ ខ្ញុំកើតកូនពីរទៀត ដល់រួចហើយខ្ញុំកើតកូនហើយ ដល់៨៤គេសុំបែកមែន បែក

រហូតទាល់សព្វថ្ងៃ។

**ស៖** អរគុណលោកស្រី។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ដែរថា តើលោកស្រីមានកូនជាមួយប្ដីទី២ នេះចំនួនប៉ុន្មាននាក់?

**ឆ៖** មានប្ដី និងកូនទី២ ខ្ញុំមានកូនបួននាក់នៅរបបខ្មែរក្រហម។ ឆ្នាំ៧៦ខ្ញុំមានកូនពីរ ព្រោះកូនភ្លោះ ដល់ឆ្នាំ៧៧ពីរទៀត ភ្លោះទៀត ហើយក្នុងបួននោះ ស្លាប់មួយ នៅសល់បី។

**ស៖** អរគុណលោកស្រី។ តើលោកស្រីអាចបញ្ជាក់បានទេថា កូនមុន កូនទី១ ប្ដីទី១ លោកស្រីថាមានកូនប្រាំបីនាក់ ហើយឥឡូវកូនទី២ លោកស្រីថាមានកូនទាំងក្នុងរបបខ្មែរក្រហម នៅក្នុងរបបប៉ុល ពត និងក្រោយគឺប្រាំមួយនាក់ ដូច្នេះលោកស្រីមានកូនទាំងអស់សរុបប៉ុន្មានដែរ?

**ឆ៖** បើសរុបទៅដែលកើតឆ្នាំ៨២ សរុបទាំងអស់១៤នាក់។

**ស៖** អរគុណលោកស្រី។ តើកូនទាំង១៤នាក់ហ្នឹង កូនប៉ុន្មាននាក់ដែលស្លាប់នៅក្នុងរបបខ្មែរក្រហម?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកស្រីឆ្លើយម្ដងទៀត ពីព្រោះមីក្រូហ្វូនមិនទាន់ប្រតិបត្តិការ។

**លោកស្រី មុំ វុន៖**

**ឆ៖** កូនដែលកើតនៅក្នុងរបប ប៉ុល ពត បួននាក់តែស្លាប់មួយ នៅសល់បី។

[១៣:៥៣:០៥]

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ថានៅក្នុងរបបខ្មែរក្រហម តើលោកស្រី កូនទាំង១៤នាក់លោកស្រីថា មានកូន១៤នាក់ តើកូនដែលស្លាប់នៅក្នុងរបបខ្មែរក្រហមប៉ុន្មាននាក់?

**ឆ៖** កូនដែលស្លាប់នៅក្នុងរបបខ្មែរក្រហមពីរនាក់។

**ស៖** គាត់ស្លាប់នៅឆ្នាំណាដែរលោកស្រី? ហើយស្លាប់ដោយៗគ្រោះថ្នាក់ ឬក៏ដោយគេសម្លាប់ ឬក៏ដោយការខ្វះអាហារ ហូបមិនគ្រប់គ្រាន់ ឬដោយជំងឺ?

**ឆ៖** គឺស្លាប់ដោយសារអត់មានថ្នាំលេប ហើយអាហារហូបអត់គ្រប់គ្រាន់ បានជាគាត់ឈឺស្លាប់ទៅ។

**ស៖** ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ដែរថា ប្ដីទី២ដែលត្រូវខ្មែរក្រហមបង្ខំឲ្យលោកស្រីរៀបការហ្នឹង លោកស្រីបែកបាក់គ្នានៅឆ្នាំណា?

**ឆ៖** ប្ដីប្រពន្ធខ្ញុំដែលខ្ញុំរៀបការលើកទី២នេះ ខ្ញុំបែកបាក់នៅឆ្នាំ៨៤ បែករហូត។

**ស៖** អរគុណលោកស្រី។ ខ្ញុំបានពិនិត្យឃើញនៅក្នុងឯកសារលេខ 3/7234, ERN ជាភាសាខ្មែរលេខ 01003335, ERN ជាភាសាអង់គ្លេសលេខ 01077096 និងERNជាភាសាបារាំងលេខ 01030451 ដែលបញ្ជាក់នៅក្នុងការព្យាបាលសុខភាព ធី.ភី.អូ (អង្គការធី.ភី.អូ) លោកស្រីបានបញ្ជាក់ថានៅឆ្នាំ៧៦ លោកស្រីបានទៅច្រៀងចម្រៀងមួយនៅក្នុងមហាសន្និបាតដែលធ្វើនៅភ្នំគូលែន។ តើពិតប្រាកដអ៊ីចឹងទេ លោកស្រី?

[១៣:៥៥:៤៤]

**ឆ៖** ចាស នៅក្នុងពេលនោះ ក្នុងឆ្នាំ៧៦នោះ គេបានប្រាប់ឲ្យទៅធ្វើមហាសន្និបាតនៅភ្នំគូលែនមែន តែថ្ងៃនោះកុំអីក៏ខ្ញុំអត់បានទៅ តែ មិត្តស៊ា ហ្នឹងគាត់ប្រាប់ថា ទៅធ្វើមហាសន្និបាតហ្នឹង ក្រុមសិល្បៈស្រុក ណាគ្រី ហ្នឹងគេសុំឲ្យទៅជួយច្រៀងឲ្យគេតែមួយបទទេ។ ទៅខ្ញុំថាមិនបាច់ទៅទេដឹងព្រោះ ណាគ្រី គេចេះហើយ។ ប៉ុន្តែអត់ទេ គេព្រួសរថាមិត្តឯងច្រៀងពីរោះ ឥឡូវគេឲ្យទៅ ហើយខ្ញុំក៏ទៅៗ។ ទៅដល់នោះ ហើយក៏ដើរទេណា៎ មិនមែនៗមានឡានមានស្អីទេ ដើររហូតហ្នឹង តាំងពីព្រឹកទៅទាល់ម៉ោងបួនភ្លឺហ្នឹង ទាល់តែម៉ោងបួនល្ងាចនោះបានដល់ ដើរទៅ។ មិនមែនលេងៗ អត់មានរទេះ មានឡានអីជិះដូចសព្វថ្ងៃទេ គឺដើរសុទ្ធតែម្ដង។ ដល់កាលណាទៅដល់ហើយ នាំគ្នាដេកមួយយប់សិន ព្រឹកឡើងបានគេរៀបចំ។ ក្រុមសិល្បៈស្រុកហ្នឹង គឺគេទៅដល់ដែរ ប៉ុន្តែពួកនេះគេដឹករទេះណា៎ ក្រុមភ្លេងគេៗដឹករទេះទៅ អត់មានឡានទេ ដឹករទេះទៅ អ្នកភ្លេងហ្នឹង។

**ស៖** អរគុណលោកស្រី។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ដែរថា ហេតុអីបានជាលោកស្រីចេះច្រៀង? ហើយលោកស្រីចេះចម្រៀងហ្នឹងពីណាមក?

**ឆ៖** ចាស បទចម្រៀងនេះ ខ្ញុំចេះពីសិល្បៈស្រុកដែលគេលេងយប់ៗទៅ ខ្ញុំទៅមើលគេ ជារៀងរាល់ថ្ងៃ។ ដល់គេច្រៀងអាបទហ្នឹងហើយ ខ្ញុំនឹកឃើញថាស្រឡាញ់បទនេះមួយដល់ហើយ យកទៅច្រៀងលេងតាមវាលស្រែមើល។ ដល់តែច្រៀងតាមវាលស្រែមើលទៅ ហើយគេហៅយើងអាតាមវាលស្រែណោះ ហៅទៅ គេហៅទៅច្រៀងនៅភ្នំគូលែន នៅកន្លែងមហាសន្និបាត ដែលគេថាគេទទួលសម្ដេចឪហ្នឹង។ ហើយក៏អ្នកស្រុកទៅភ្លូកទឹកភ្លូកដី ចុះសម្ដេចឪមកហើយ និយាយអត់ទៅម៉េចបាន ទៅរក

មើល អត់ឃើញ ព្រោះបាត់យូរហើយ ថាយ៉ាងអ៊ីចឹង។ ហើយម្ដោះហើយ ក៏នាំគ្នាទៅ។ គេហៅទៅ ខ្ញុំក៏ទៅជាមួយនឹងគេហ្នឹងឯង។

[១៣:៥៨:០៤]

**ស៖** ពេលស្អែកឡើង ពេលដែលសន្និបាតបើក តើលោកស្រីមានឃើញសម្ដេចឪទេ?

**ឆ៖** នៅថ្ងៃស្អែកឡើងអត់មានឃើញសម្ដេចឪផង ឮសូរតែគេប្រកាសឈ្មោះ ប៉ុន្តែខ្ញុំអត់ដែលឃើញហើយ អត់ដែលស្គាល់ទៀត។ ប្រកាសឈ្មោះថា ថ្ងៃនេះគេមកទទួលលោក ខៀវ សំផន, លោក នួន ជា, លោក អៀង សារី ទៅ ខ្ញុំថាអ្ហ្នចុះអត់សម្ដេចឪទេចុះ មិនដែលឃើញផងរូបនេះ។ ដល់មកនៅលើវេទិកាទៅឃើញគាត់បីនាក់មែន ហើយកម្មាភិបាលផ្សេងៗទៀត ក៏អង្គុយនៅលើនោះដែរ នៅភ្នំគូលែន ៧៦។ ដល់ហើយសិល្បៈស្រុកគេ ក៏គេលេងគគ្រឹមទៅ ហើយខ្ញុំក៏អង្គុយមើលគេ ដល់រួចហើយគេហៅទៅ។ ដល់ហៅទៅហ្នឹង លោក នួន ជា គាត់បានឡើងប្រកាសហើយឲ្យសមមិត្ត យុវ័ន យុវជនមិត្តម៉ែ មិត្តពុក ឲ្យខំបង្កបង្កើតផលឲ្យបានច្រើនដើម្បីយកសេដ្ឋកិច្ច ស្បៀងឲ្យបានច្រើន ជំនួយកងទ័ពបដិវត្ត គាត់និយាយអ៊ីចឹង។ ដល់រួចហើយ គេហៅខ្ញុំទៅ។ ដល់គេហៅខ្ញុំឡើងទៅលើ ឈប់បានស្ដាប់ហើយ ដល់រួចហើយ គាត់ប្រកាសថាចប់ហើយ។ ចប់ហើយដល់រួចមក ខ្ញុំឡើងទៅលើឆាក ខ្ញុំច្រៀងបានមួយបទហ្នឹងឯង ខ្ញុំអត់មានច្រៀងច្រើនទេ ហៅខ្ញុំឲ្យទៅច្រៀងតែមួយ ខ្ញុំច្រៀងតែមួយហ្នឹងឯង អត់មានច្រៀងពីរទេ បទបដិវត្តហ្នឹង។ ហើយលោកស្រីបញ្ជាក់ហ្នឹង គិតយ៉ាងម៉េចវិញ?

[១៤:00:00]

**ស៖** ខ្ញុំចង់ឲ្យលោកស្រីរៀបរាប់ប្រាប់អង្គសវនាការដែរថា--

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីបើកមីក្រូហ្វូនសិន!

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ខ្ញុំចង់ឲ្យលោកស្រីរៀបរាប់ប្រាប់អង្គសវនាការដែរថា មហាសន្និបាតនេះដែលរៀបចំឡើងដែលមានថ្នាក់ដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យចូលរួម តើលោកស្រីមានដឹងថា ខ្លឹមសារនៃមហាសន្និបាតនិងការប្រជុំនេះវាមានខ្លឹមសារយ៉ាងម៉េចទេលោកស្រី?

**លោកស្រី មុំ វុន៖**

**ឆ៖** ការដែលប្រជុំធ្វើមហាសន្និបាតនេះ គឺថាមានខ្លឹមសារត្រង់ថាឲ្យកន្លែងប្រជាជនទាំងអស់

យុវ័ន យុវនារីទាំងអស់ហ្នឹងដែលបានធ្វើនេះឲ្យខំជួយ ធ្វើយ៉ាងណាឲ្យមានសេដ្ឋកិច្ចឲ្យបានច្រើន ដើម្បីជួយកងទ័ព។ នេះខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** អរគុណលោកស្រី។ តើចម្រៀងដែលលោកស្រីឡើងច្រៀងនោះមានអត្ថន័យម៉េចដែរលោកស្រី មានខ្លឹមសារយ៉ាងម៉េចដែរ?

**ឆ៖** ចាស ក្នុងបទចំរៀងបដិវត្តន៍នេះ បើសិនជាលោកស្រីដែលជាមេធាវីខ្ញុំ ព្រមទាំងលោកប្រធានចង់ឲ្យខ្ញុំបកស្រាយនូវបទចម្រៀងនេះខ្ញុំបកបាន ដើម្បីឲ្យអស់លោកហ្នឹងបានស្ដាប់ជ្រួបជ្រាបថាបទសម័យបដិវត្តន៍ "សូរិយាក្រហមឆ្អៅ" នេះ តើវាមានន័យបែបណានោះ ក៏សូមឲ្យលោកស្ដាប់បទចម្រៀងនេះហើយ បែងចែក និងពិចារណា និងសង្កមទាំងពីរ តើសង្គមណាល្អ ឬអាក្រក់ឲ្យលោកបានដឹងនៅក្នុងពេលនេះ។ ខ្ញុំនឹងបកស្រាយឲ្យបានស្ដាប់ទាំងអស់ក្នុងវគ្គនេះ។

[១៤:០២:០៣]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីមិនចាំបាច់ទេ។ សូមបន្តចម្លើយទៅតាមសំណួររបស់មេធាវី។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** លោកស្រីក្រោយពីអង្គសន្និបាតហ្នឹងហើយតើមានរឿងអ្វីដែលកើតឡើងចំពោះលោកស្រី?

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស ដល់កាលណាខ្ញុំច្រៀងចប់ហើយ ខ្ញុំចុះមកដី។ ដល់រួចហើយឈ្មោះ ចាន់ អេង ហ្នឹងដឹកអង្ករ ហើយគាត់បានដឹងថាន៎ៃនៅដល់ណាទៀត ពួកអ្នកដែលច្រៀងទាំងប៉ុន្មាននោះអាខ្លះឡើងឡានទៅអស់ហើយ ម៉េចក៏មិនឆាប់ទៅទេ នោះឡើងរទេះទៅ ហើយក៏ខ្ញុំដឹងខ្លួនហើយភ្លែត ឡើងលើរទេះគេគ្របកន្ទេល ហើយនិងប៉ាវដែលដឹកបន្លែ ដឹកបាយយកទៅឲ្យគេហ្នឹង ហើយខ្ញុំក៏រួចមកក៏បររទេះមក។ ដល់បររទេសមកដល់ផ្ទះហើយ ខ្ញុំអត់ហ៊ាននៅផ្ទះទៀត។ ខ្ញុំហួសទៅកន្លែងការដ្ឋាននោះ ខ្លាចគេមករកតាមទៀត។ បានខ្ញុំហួសទៅកន្លែងការដ្ឋានហ្នឹង គឺវាផុតអត់មានឃើញអ្នកណាទៅតាមទៀតទេ។ ខ្ញុំនៅកន្លែងនោះរហូត រែកដី ស្ទូងស្រូវជាមួយគេនៅកន្លែងនោះទៀត។

[១៤:០៣:១៤]

**ស៖** លោកស្រីអាចបញ្ជាក់បន្ថែមកន្លែងហ្នឹងបានទេ ថាហេតុអីបានលោកស្រីដឹងថាអ្នកច្រៀងអ្នកដែលឡើងច្រៀងត្រូវគេសម្លាប់? ហើយអ្នកណាជាអ្នកប្រាប់លោកស្រីហ្នឹង? ហើយពេលហ្នឹងដែល

លោកស្រីត្រូវគេចខ្លួន ហើយអ្នកណាដែលជួយលោកស្រីក្នុងការគេចខ្លួនហ្នឹង?

**ឆ៖** ចាស នៅក្នុងនោះដែលខ្ញុំគេចខ្លួន ព្រោះ បងចាន់ អេង ហ្នឹងគាត់បានដឹកអង្ករទៅ គាត់ឃើញគេឡើងៗឡាន។ ហើយដល់រួចមក ខ្ញុំដែលគាត់អីចុះហើយ ក៏ខ្ញុំដឹង គាត់ក៏ជួយឲ្យខ្ញុំឡើងរទេះមក ហើយក៏បរមកផ្ទះមក គាត់ជួយខ្ញុំរួចខ្លួនមក។ ដល់រួចហើយពួកនោះ ដឹងគេដាក់ឡាន ដឹងយកទៅណា អត់ឃើញរហូតទល់សព្វថ្ងៃមកវិញផង ដឹងទៅណា។

**ស៖** អរគុណលោកស្រី។ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ខ្ញុំចង់ដឹងថាតើកត្តាអ្វីដែលធ្វើឲ្យលោកស្រីមានភាពក្លាហាន ហ៊ានឡើងនិយាយអ្វីដែលកើតឡើងចំពោះលោកស្រីនៅក្នុងមុខសវនាការ ក៏ដូចជានៅក្នុងអង្គការ ធី.ភី.អូ ក៏ដូចជានៅក្នុងវេទិកាស្ត្រី?

**ឆ៖** បានជាខ្ញុំហ៊ានឡើងមកបកស្រាយ ព្រោះខ្ញុំមានសេចក្ដីឈឺចាប់ដែលរឿងហេតុដែលកើតឡើងទាំងប៉ុន្មាននេះ ខ្ញុំមិនអាចលាក់ទុកបាន បានជាខ្ញុំហ៊ានប្ដេជ្ញាចិត្តឡើងមកនិយាយប្រាប់បងប្អូនរួមជាតិទាំងអស់ឲ្យដឹងថា របបនេះគឺពិបាក ៗដោះស្រាយ ធ្វើបាបគ្មានគិតពិចារណា ថាបង ឬប្អូន មា ក៏មីងទេ ធ្វើបាបទាំងអស់។

**លោកស្រី ដេត វណ្ណលី៖**

សូមអសរគុណលោកស្រី ដែលបានឆ្លើយបំភ្លឺយ៉ាងក្បោះក្បាយនៅចំពោះមុខតុលាការ។ លោកប្រធាន ខ្ញុំអស់សំណួរ។ ខ្ញុំសូមប្រគល់វេទិកានេះ ឲ្យសហមេធាវីនាំមុខអន្តរជាតិ គាត់ចង់មានសំណួរបន្ថែម លោកប្រធាន។

[១៤:០៥:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីអន្តរជាតិ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរពីរបី ដើម្បីសួរបន្ត។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ លោកស្រីបានប្រាប់ថា លោកស្រីមានផ្ទៃពោះនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ហើយលោកស្រីមានកូនជាច្រើនមុនរបបសម័យខ្មែរក្រហម។ តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ អំពីលក្ខខណ្ឌជីវិត ហើយនិងលក្ខខណ្ឌការងារ

ចំពោះស្ត្រីមានផ្ទៃពោះ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនេះដែរឬទេ? តើកាលនោះ លោកស្រីធ្វើការ លោកស្រីមានសិទ្ធិសម្រាកដែរឬទេ? តើការដែលលោកស្រីមានផ្ទៃពោះនេះ តើលក្ខខណ្ឌការងារលោកស្រីយ៉ាងម៉េចដែរ សូមលោកស្រីជួយរៀបរាប់បន្តិចមើល?

[១៤:០៦:៣២]

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស អរគុណ។ តែការងារដែលខ្ញុំមានផ្ទៃពោះនៅក្នុងរបបខ្មែរក្រហមហ្នឹង គឺថាមានពោះចាប់ពីមួយខែទៅ គឺរែកដីរហូត អត់មានទេ។ ពោះទាល់តែដល់ខ្ញុំ៧ខែ គេឲ្យមកធ្វើការស្រាល គឺកិនស្រូវ។ នេះស្រាលហើយ ទាញត្បាល់កិនហ្នឹង។ កិនស្រូវ ហើយម៉្លោះហើយសុខភាពវាអត់ត្រូវទទួលខុសត្រូវ ហើយហូបក៏មិនឆ្អែត។ កិនស្រូវ ធ្វើបាន ធ្វើស្រែស្រូវបានរាប់តោន ក៏ប៉ុន្តែដល់ទៅហូប ហូបបបរ លាយសម្បកដំឡូង ព្រលឹតត្រកួន។ នេះគឺអស្ចារ្យ។ បើសិនជាសម្លគេវិញ ស្លឲ្យហូប គេស្លត្រីឆ្អិនត្រីកញ្ចុះ ហើយស្លម្ជូរឈ្លើងថែមទៀត។ ស្លម្ជូរឈ្លើងនេះ វានៅនឹងដើមត្រកួនហ្នឹង។ ចុងភៅគេអត់លាងទេ ដល់កាលណារៀបហូបហើយ អាកាលណាដែលមានផ្ទៃពោះ មើលទៅ ចេះតែស្រង់ទៅហូបទៅ។ ដល់ហុតទឹកអស់ហើយ ដល់រួចមក មើលនឹងបាតចាន ឃើញឈ្លើងពីរ ប៉ុន១មេដៃ នៅខ្ទៀនហ្នឹងឯងក្អួតណាចេញ បើឆ្អែតហើយ។ ឃ្លានហើយ ចេះតែហូបទៅ។ សុខភាពដែលអ្នកមានផ្ទៃពោះហ្នឹង អត់ស្រួលទេ។ គេប្រើ អត់មានថា អ្នកមានផ្ទៃពោះ ឬអត់ផ្ទៃពោះទេ គឺប្រើទាំងអស់។ ក្នុងមួយថ្ងៃ ដឹងតែ៦ម៉ែត្រ បើអត់បាន៦ម៉ែត្រ គឺគ្មានបបរហូបទេ។ ហើយកិនស្រូវក៏ដោយ មួយថ្ងៃ បើអត់រួចប្រាំបួនកញ្ជើហ្នឹង គឺអត់បានបាយហូបដែរ ដូចគ្នា។ នេះអ្នកមានផ្ទៃពោះ ខ្ញុំសូមជម្រាបលោកស្រីមេធាវីនាំមុខឲ្យបានជ្រាប។

**ស៖** បាទ សូមអរគុណ។ ហើយក្រោយពីលោកស្រីបានសម្រាលកូនហើយនោះ តើលោកស្រីមានលទ្ធភាពថែទាំកូនចៅដែរឬទេ? អាចនៅជិតកូនបានដែរឬទេ ក្រោយពីពេលលោកស្រីសម្រាលកូនហើយនោះ<តើមានអ្វីកើតឡើង>?

[១៤:០៨:៣៣]

**ឆ៖** ចាស ក្រោយពីពេលសម្រាលកូនហើយ នាងខ្ញុំបាននៅជិតកូនតែក្នុងមួយខែកន្លះទេ តែមួយខែកន្លះនោះ ក៏អត់មែននៅថែទាំកូននឹងផ្ទះទេ ទៅនៅនឹងសហករណ៍កិនស្រូវ។ មួយខែកន្លះហ្នឹង គឺកិនស្រូវទៀត សរសៃខ្ចីហ្នឹង។ ហើយម៉្លោះហើយ កាលណាដល់នេះទៅ ស្គមរីងរៃ ហើយគ្មានទឹកដោះ

ដល់កូនបៅទេ។ ម៉្លោះហើយកូនក៏ម្ដងឈឺនេះ ម្ដងឈឺនោះ ព្រោះវាបៅអត់ឆ្អែត។ ម៉្លោះហើយអាម៉ែក៏ឈឺ អាកូនក៏ឈឺ ប៉ុន្តែនៅតែទៅធ្វើការឲ្យគេតែដដែល។ បើសិនជាយើងអត់ទៅ អត់មានបបរហូបទេ បើអត់ទៅ។ នេះបែបនេះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។

សូមអញ្ជើញលោកព្រះរាជអាជ្ញា មានសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណី។

[១៤:០៩:៥៨]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**ស៖** ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រម ភាគីទាំងអស់ ខ្ញុំឈ្មោះ វ៉ាំងសង់ ដឺវីល។ ខ្ញុំនឹងចោទសំណួរទៅលោកស្រី ក្នុងតំណាងឲ្យការិយាល័យសហព្រះរាជអាជ្ញា ជាសំណួរដែលសួរបន្តពីអ្វីដែលលោកស្រីបានពន្យល់ទៅលោកស្រីមេធាវី ជេត វណ្ណលី ហើយនិងលោកស្រីមេធាវី ម៉ារី ហ្គីរ៉ូដ៍។ ខ្ញុំចោទសំណួរទៅលោកស្រី ទាក់ទងទៅនឹងការប្រមូលមនុស្សនៅភ្នំគូលេន ដែលលោកស្រីបាននិយាយអម្បាញ់មិញនេះ។ លោកស្រីអាចបញ្ជាក់បានដែរឬទេថា នៅឆ្នាំណាដែរ? លោកស្រីចាំទេ គេប្រមូលផ្ដុំនៅឆ្នាំណា?

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស គេប្រមូលផ្ដុំទៅធ្វើមហាសន្និបាត គឺឆ្នាំ១៩៧៦។

**ស៖** តើនៅពេលនុ៎ង លោកស្រីបានរៀបការហើយឬនៅ? ព្រោះលោកស្រីបានប្រាប់ពីព្រឹកមិញថា នៅចុងឆ្នាំ៧៥ គេបានបង្ខំឲ្យលោកស្រីរៀបការ អ៊ីចឹងបានន័យថា គេប្រមូលផ្ដុំមនុស្សនោះទៅប្រជុំហ្នឹងនៅឆ្នាំ៧៦ បានន័យថាក្រោយពេលដែលលោកស្រីរៀបការហើយ ឬក៏យ៉ាងម៉េច?

**ឆ៖** ទៅក្រោយខ្ញុំរៀបការ។ ខ្ញុំរៀបការចុង៧៥, ៧៦ទៅ ៗប្រជុំតែមួយថ្ងៃទេ អត់ទៅយូរទេ

និងវិលត្រឡប់មកផ្ទះវិញ។ ហើយប្រជាជនដែលប្រជុំចប់នោះ ក៏ត្រូវមកទាំងអស់គ្នាដែរ អត់មានអ្នកណានៅទេ មកទាំងអស់ មកផ្ទះតាមរៀងៗខ្លួន។ ការដ្ឋានណា ក៏យើងទៅតាមការដ្ឋានហ្នឹងទៅ ការងារដែលធ្វើហ្នឹងឯង។

[១៤:១១:៥៥]

**ស៖** ឥឡូវទាក់ទងនឹងអ្នកដឹកនាំដែលបានចូលរួមទៅក្នុងកិច្ចប្រមូលផ្តុំប្រជុំហ្នឹង លោកស្រីបាននិយាយពី នួន ជា, ខៀវ សំផន, អៀង សារី។ តើហេតុអ្វីបានជាលោកស្រីដឹកថា អ្នកទាំងអស់ហ្នឹងជា នួន ជា, អៀង សារី, ខៀវ សំផន? តើមានគេប្រកាសផ្សាយជាសាធារណៈឲ្យដឹងតែម្តង ឬក៏មានអ្នកណាម្នាក់បានប្រាប់លោកស្រីថា បុគ្គលទាំងអស់នុំង សុទ្ធជា នួនជា, អៀង សារី, ខៀវ សំផន អីនេះ?

**ឆ៖** ចាស គេប្រកាសតើ។ គេប្រកាសប្រាប់ក្នុងមហាសន្និបាតហ្នឹងឯង។ គេប្រកាសប្រាប់ឈ្មោះ តែខ្ញុំអត់ស្គាល់ទេ។ ប៉ុន្តែដល់ប្រកាស ខ្ញុំគ្រាន់តែមើលឃើញថា ជារូបគាត់ហើយ ក៏ខ្ញុំក៏មិននិយាយថាម៉េចដែរ។ ខ្ញុំគ្រាន់តែអើតមើលហើយ។ ដល់រួចហើយ គេហៅខ្ញុំទៅកន្លែងផ្សេង ទៅកន្លែងដែលគេលេងសិល្បៈហ្នឹងទៅ។ ខ្ញុំអត់បាននៅនឹងកន្លែងនោះទេ។

**ស៖** តើមានអ្នកដឹកនាំអតីតភូមិភាគឧត្តរដែរឬទេ?

**ឆ៖** ចាស អ្នកដឹកនាំភូមិភាគឧត្តរនោះ ក៏ខ្ញុំអត់ស្គាល់ដែរ ព្រោះខ្ញុំជាប្រជាជន អត់ដឹងថាអ្នកណាមួយមិត្តភូមិភាគ អ្នកណាក៏ឧត្តរ ក៏ខ្ញុំអត់ដឹង ប៉ុន្តែឃើញអង្គុយនៅលើនោះច្រើនគ្នាដែរ។ ប៉ុន្តែដល់គេប្រកាស គេប្រកាសតែបី។ ហើយខ្ញុំដឹងថាបីនោះ ក៏ស្តាប់តែចុងពាក្យ គាត់និយាយដូចខ្ញុំនិយាយពីមុនមក។ តែបួន -- ខ្ញុំស្តាប់បានតែគាត់និយាយបួនប្រាំមាត់នោះឯង ដល់រួចហើយ គេហៅខ្ញុំទៅកន្លែងផ្សេងទៅ ខ្ញុំទៅកន្លែងសិល្បៈគេហ្នឹងទៅ។ តែប៉ុណ្ណឹងឯង។

**ស៖** តើមានតែ នួន ជា ទេដែលឡើងនិយាយ ឬក៏ ខៀវ សំផន ហើយនិង អៀង សារី ហ្នឹងក៏ឡើងធ្វើបទឧទ្ទេសនាមដែរ?

[១៤:១៤:១២]

**ឆ៖** អត់ទេ និយាយតែមួយទេ។ បើនិយាយមួយ ខ្ញុំប្រាប់ថាមួយ បើនិយាយទាំងអស់ ខ្ញុំប្រាប់ថាទាំងអស់។ គាត់និយាយតែមួយទេ។

**ស៖** លោកស្រីបាននិយាយថា លោកស្រីបានទៅកន្លែងទីនោះមួយថ្ងៃមុន ហើយព្រឹកឡើងបានគេប្រមូលផ្តុំប្រជុំ។ តើគេប្រជុំនុំងអស់រយៈពេលប៉ុន្មានដែរ? តែមួយព្រឹកទេ ឬក៏ព្រឹកហើយទាំងរសៀល

ទៀត?

**ផ៖** គេប្រជុំចាប់ពីព្រឹកទៅដល់ម៉ោងពីរ គេរំសាយ។ គេប្រជុំពីព្រឹកដល់ម៉ោងពីរ គេរំសាយ តែប៉ុណ្ណឹងទេ ប៉ុន្តែហើយក៏ចែកផ្លូវគ្នាមកផ្ទះទាំងអស់គ្នា អត់មានធ្វើយូរទេ។

**ស៖** នៅក្នុងចំណោមអ្នកដែលចូលរួមប្រជុំនោះ តើមានមនុស្សប៉ុន្មាននាក់ដែរនៅកំពុងចូលរួមហ្នឹង? តើដឹងថាមកពីណា អ្នកដែលចូលរួមហ្នឹងមកពីណាដែរ? ឧទាហរណ៍ខ្ញុំសួរថាតើអ្នកដែលមកពីកងចល័តអ្នកស្រីហ្នឹង មានចូលរួមក្នុងកិច្ចប្រជុំហ្នឹងទេ?

**ផ៖** ចាស ដែលទៅចូលរួមប្រជុំនោះ កងចល័តក៏ទៅ អ្នកស្រុកក៏ទៅ ទៅច្រើនគ្នា។ គេថាទៅទទួលសម្តេចឪនោះ វាបាក់អ្នកស្រុកទៅ អាអ្នកមានប្តីមានកូននោះក៏ទៅទាំងអស់គ្នា កងចល័តក៏ទៅៗទាំងអស់តែម្តង។ គ្នាច្រើនណាស់ មិនមែនតិចទេ។

**ស៖** តើលោកស្រីដឹងដែរឬទេ ហេតុអ្វីបានគេប្រាប់ថា សម្តេចឪលោកនឹងយាងមកនោះ ហើយតាមពិតទៅ សម្តេចឪលោកអត់បានយាងមកទេ? តើ<គេមានប្រាប់>លោកស្រី<>ពីមូលហេតុ<>ទេ?

[១៤:១៦:៤៥]

**ផ៖** ចាស ខ្ញុំនៅយល់ហេតុការណ៍បែបនេះ ព្រោះប្រធានខ្សែគេប្រាប់ គេថាឲ្យអ្នកស្រុកទៅជួយទទួលសម្តេចឪ។ ហើយខ្ញុំក៏ថា សម្តេចឪ អូ! សម្តេចឪមកហើយ ត្រូវតែទៅ ប្រាប់អ្នកស្រុកទាំងអស់ កងចល័តទាំងអស់គេទៅ។ ដល់ទៅហើយ អត់ឃើញមានសម្តេចឪផង។ ទៅដល់កន្លែងហ្នឹង អត់ឃើញមានសម្តេចឪ។

**ស៖** អម្បាញ់មិញលោកស្រីបាននិយាយថា នួន ជា គាត់បាននិយាយថា ត្រូវបង្កបង្កើនផលបានច្រើនដើម្បីឧបត្ថម្ភដល់កងទ័ពបដិវត្តន៍។ អ៊ីចឹងខ្ញុំសួរលោកស្រីថា សួរថា តើគាត់អាចមាននិយាយលោក នួន ជា ហ្នឹងគាត់មាននិយាយអំពីអ្វីផ្សេងទៀតទេ ឧទាហរណ៍ដូចនិយាយអំពីវិន័យអីជាដើម?

**ផ៖** ចាសគាត់និយាយឲ្យបង្កបង្កើនផល ដើម្បីជួយទាហានបដិវត្តន៍ ហើយគាត់ជំរុញក្នុងវិន័យដែលធ្វើការងារឲ្យមានពេលគោរពវិន័យត្រូវតែធ្វើ បើគេដាក់ប៉ុនណាគឺធ្វើប៉ុណ្ណឹងទៅ។ គាត់អត់មាននិយាយអីទៀតទេ គាត់និយាយតែប៉ុណ្ណឹងទេ។

**ស៖** ក្រៅពីគោរពវិន័យហ្នឹង តើគាត់មាននិយាយអំពីនិយមន័យនៃខ្មាំងរបស់បដិវត្តន៍ដែរឬទេ? តើលោកស្រីមានឮគាត់និយាយពីនិយមន័យ ចង់និយាយថា តើខ្មាំងបដិវត្តន៍ហ្នឹងជាអ្វីដែរឬទេ?

**ឆ៖** ចាស ខ្មាំងបដិវត្តន៍គឺយួន នេះគឺខ្មាំងបដិវត្តន៍។

**ស៖** នួន ជា ជាអ្នកនិយាយអ៊ីចឹង ថាខ្មាំងរបស់បដិវត្តន៍ហ្នឹងគឺយួន ក្នុងពេលប្រជុំហ្នឹងគាត់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

[១៤:១៨:៥៥]

**ឆ៖** និយាយថាអ៊ីចឹងឯង។

**ស៖** តើគាត់មាននិយាយប្រាប់ថាត្រូវធ្វើយ៉ាងម៉េចចំពោះពួកយួនដែរឬទេក្នុងឱកាសប្រជុំហ្នឹង?

**ឆ៖** ខ្ញុំអត់បានឮគាត់និយាយតទៅទៀតទេ ព្រោះដែលគេហៅខ្ញុំទៅនោះ គាត់និយាយបានតែប៉ុណ្ណោះឯង ខ្ញុំដើរចេញពីនោះទៅ អត់បានស្ដាប់គាត់ទៀតទេ។

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះខ្ញុំសូមចូលទៅនិយាយប្រធានបទមួយទៀត ខ្ញុំសូមការបំភ្លឺពីលោកស្រីអំពីឪពុករបស់លោកស្រី។ លោកស្រីបាននិយាយថា គេបានកោះហៅគាត់ហើយ ក៏គាត់បាត់ខ្លួនរហូត។ អ៊ីចឹងខ្ញុំសួរលោកស្រីថា នៅក្នុងរបបសង្គមរាស្ត្រនិយមហ្នឹង ឪពុករបស់លោកស្រីហ្នឹង គាត់មានមុខងារអ្វីដែរនៅក្នុងភូមិ ឃុំដែលគាត់ធ្វើការហ្នឹង?

**ឆ៖** ចាស ឪពុកខ្ញុំកាលពីសង្គមរាស្ត្រនិយម គាត់ធ្វើស្រែ ប៉ុន្តែតែដល់គាត់និយាយលេងនេះទៅគេហៅថាលោកមេឃុំគោមេ ទៅតាមគាត់ ការពិតគាត់អ្នកភ្លេងការទេ គាត់មិនបានមេឃុំទេ។ គេហៅគាត់មេឃុំគោមេ គាត់មានគោមេច្រើនដល់ទៅ៦០ក្បាលឯណោះ។

**ស៖** ចង់និយាយថា ជាផ្លូវការហ្នឹងគាត់ជាមេឃុំមែនទែន ឬក៏គ្រាន់តែគេហៅគាត់ថាមេឃុំគោមេអ៊ីចឹងទេ គាត់អត់មានតំណែងអីជាផ្លូវការទេ ឬក៏ម៉េច?

**ឆ៖** គាត់អត់មែនជាមេឃុំទេ ប៉ុន្តែគេហៅគាត់លេងថា "មេឃុំគោមេ" ហ្នឹងហើយ ព្រោះគោគាត់ច្រើនទៅ គេហៅគាត់តែមេឃុំគោមេ តាមការពិតគាត់ជាអ្នកស្រែទេ គាត់អត់មានមេឃុំមេអីទេ។

[១៤:២១:២៩]

**ស៖** ក្រោយពេលគេចាប់ខ្លួនគាត់ហើយហ្នឹង សួរថាខ្មែរក្រហមដែលចាប់គាត់ទៅហ្នឹងណា គេមានដឹងថាគាត់ហ្នឹងពីមុនមានគោច្រើនអ៊ីចឹងទេ គោមេច្រើនអ៊ីចឹងទេ? ហើយដោយហេតុអ៊ីចឹងហើយបានគេហៅគាត់ថា "មេឃុំគោមេ" ហ្នឹង? គេដឹងទេ ចាប់ខ្លួនគាត់ហើយ គេដឹងទេ?

**ឆ៖** អត់ដឹងថាគេដឹង ឬក៏អត់ដឹងទេ ប៉ុន្តែដល់អ៊ីចឹងទៅ គេហៅគាត់ទៅតែម្ដង គេថាគាត់រដ្ឋការតាមការពិតគាត់ជាអ្នកស្រុកធ្វើស្រែទេ។ ហើយគាត់ជាអ្នកភ្លេងការ មិនបានអ្នកមេឃុំមេអីទេ ចាស

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គាត់ធ្វើតែស្រែទេ។ ប៉ុន្តែដល់គេហៅ “មេឃុំគោមេៗ” នេះគាត់គោវាច្រើនទៅ គេហៅលោកមេឃុំគោមេ គេហៅលេងទេ។

**សៈ** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីបានរៀបការជាលើកទី១នៅក្នុងឆ្នាំ ទសវត្សរ៍ឆ្នាំ៦០ ហើយលើកទី២ហ្នឹង គេបង្ខំឲ្យលោកស្រីរៀបការនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អ៊ីចឹងលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ អំពីភាពខុសគ្នានៃពិធីរៀបការទាំងពីរហ្នឹង គឺលើកទី១ លោកស្រីរៀបការហ្នឹងតាមបែបប្រពៃណី ហើយនិងពិធីរៀបការក្នុងរបបខ្មែរក្រហមហ្នឹង ពីរហ្នឹងខុសគ្នាយ៉ាងម៉េចដែរ?

**ឆៈ** ចាស ក្នុងពិធីរៀបការក្នុងរបបសង្គមរាស្ត្រនិយម គឺខុសក្នុងរបប ប៉ុល ពត ខ្មែរក្រហមហ្នឹង។ រៀបការលើកទី១ ខ្ញុំកូនស្រីគាត់ដែល គាត់លើកឲ្យគេហ្នឹង គាត់ស៊ីលុយ៦០.០០០ – ៦០.០០០ពីសង្គមហ្នឹង ហើយហៅភ្ញៀវដល់ទៅ១០០នាក់។ មានលោក មានភ្លេងការ មានអាចារ្យត្រឹមត្រូវទាំងអស់ មានហែកូនប្រុសចូលរោងជ័យ មានទាំងអស់។ ដល់ការលើកទី២ អត់មានទេ អត់មានភ្លេង អត់មានភ្ជាប់អី មាន៦០គូតែម្ដង បង្ខំចិត្តរៀបការតែម្ដង អត់មានស្រឡាញ់សោះ។ ហើយវាខុសគ្នា ខុសគ្នាអាកន្លែងថារៀបការហើយ តែងតែមានជប់លៀង មានសាច់ជ្រូក សាច់គោ សាច់មាន់អីទទួលភ្ញៀវ ដល់នេះអត់មានទេ ស្លម្ល[ស្ល]រព្រលឹត។ យើងអ្នករៀបការនេះ ស្លម្ល[ស្ល]រព្រលឹតត្រីផ្អិនឲ្យហូប។ ៦០គូហ្នឹងស្លម្ល[ស្ល]រឲ្យហូប អត់មានៗដូចខ្ញុំរៀបការពីសង្គមទេ។

[១៤:២៤:៣៧]

**សៈ** នៅពេលរៀបការលើកទី១នោះ តើមានលោកសង្ឃនិមន្តមក ហើយឲ្យពរឲ្យជ័យទៅដល់គូស្វាមីភរិយាដែរឬទេ ពេលដែលលោកស្រីរៀបការលើកទី១នោះ?

**ឆៈ** ចាស ខ្ញុំលើក -- ខ្ញុំរៀបការលើកទី១គឺមានលោកសង្ឃ។ មានលោកសង្ឃមកឲ្យពរឲ្យជ័យ អាចារ្យឲ្យពរឲ្យជ័យ ហើយដល់ពេលវេលាម៉ោងដែលភ្ញៀវ គេត្រូវមកអបអរសាទរក្នុងពេលដែលខ្ញុំរៀបការហ្នឹង គឺមានភ្ញៀវច្រើនមកចូលរួមទាំងអស់ ហើយមានសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវទាំងអស់។ ម៉ែឪខាងប្រុស ម៉ែឪខាងស្រី អាចទទួលស្គាល់ថា ខ្ញុំទាំងពីររូបនោះ ជាគូភរិយាស្វាមី ដែលរៀបការ មានលោកសង្ឃ មានភ្លេងការ មានអាចារ្យ មានភ្ញៀវគគ្រឹកគគ្រេង ចាស។

**សៈ** បើតាមអ្វីដែលលោកស្រីនិយាយទៅអង្គការ ធី.ភី.អូ នោះ គឺលោកស្រីអាយុ១៦ឆ្នាំទេ អង្កាល់រៀបការហ្នឹង។ ហើយអង្កាល់នុ៎ង លោកស្រីយល់ព្រមរៀបការដែរឬទេ អង្កាល់រៀបការតាម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រពៃណីខ្មែរហ្នឹង ហើយលោកស្រីមានអាយុ១៦ឆ្នាំនោះណា?

**ឆ៖** ចាស កាលដែលខ្ញុំ១៦ឆ្នាំហ្នឹង ឪពុកខ្ញុំ ព្រោះខ្ញុំទៅតាមម៉ែ តាមឪខ្ញុំដែលគាត់រៀបអាពាហ៍-ពិពាហ៍ឲ្យហ្នឹង គាត់សួរខ្ញុំ គាត់ឲ្យខ្ញុំ ខ្ញុំស្ម័គ្រចិត្ត។ ខ្ញុំស្ម័គ្រចិត្តទាំងអស់គ្នា ទាំងសងខាង សុខចិត្តស្រឡាញ់គ្នា បានខ្ញុំរៀបការ។ សុខចិត្តស្រឡាញ់គ្នា បានខ្ញុំរៀបការ។

[១៤:២៦:៣៩]

**ស៖** ឥឡូវខ្ញុំមកនិយាយអំពីរយៈពេលក្រោយខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមបានដណ្ដើមយកភ្នំពេញ ហើយនិងតំបន់ផ្សេងៗទៀត ក៏ដូចជាតំបន់ដែលលោកស្រីនៅដែរ។ អ៊ីចឹងលោកស្រីកាលណោះនៅក្នុងភូមិនោះ តើគេមានបំបែកលោកស្រីពីក្រុមគ្រួសារលោកស្រីដែរឬទេ ដូចជាឪពុកម្ដាយ បងប្អូន ឬក៏ប្ដីលោកស្រីអីជាដើមនោះ គេមានបំបែកទេ?

**ឆ៖** នៅរបបខ្មែរក្រហមហ្នឹង? នៅរបបខ្មែរក្រហម គេបំបែកតើ ប្ដីទៅផ្សេង ប្រពន្ធទៅផ្សេង កូនទៅផ្សេង អត់មាននៅជុំគ្នាទេ។ កូននៅកងចល័តផ្សេងទៅ ម៉ែនៅខាងចល័តផ្សេង ឪពុកខាងចល័តផ្សេង។ អាតូចៗនៅជាមួយយាយៗ ដែលដាំបាយដាំបន្លែអី ឲ្យមើលក្មេងៗដែលតូចៗហ្នឹង។ ម៉ែៗជម្លៀសអស់ -- ចល័តអស់ហើយ អត់មាននៅទេ។

**ស៖** តើលោកស្រីមានដែលដឹងដែរឬទេ ថាហេតុអ្វីបានគេបំបែកក្រុមគ្រួសារទាំងអស់ហ្នឹងដោយដាច់ចេញពីគ្នាទាំងអស់អ៊ីចឹង លោកស្រីមានដឹងពីមូលហេតុទេ?

**ឆ៖** រឿងដែលគេបំបែកចេញពីគ្នានេះ ខ្ញុំអត់ដឹងមូលហេតុទេ។ ឲ្យគេឲ្យទៅណា ក៏ទៅណោះដែលប៉ានប្រកែកទេ។ គេឲ្យទៅស្ទូង គេប្រាប់ឲ្យទៅចល័ត ទៅខាងណោះ ក៏ទៅ។ ប្ដីទៅណោះទៅប្រពន្ធក៏ទៅខាងណោះទៅ អត់ដឹងផែនការថាគេបំបែកនោះ គេបំបែករបៀបណាទេ។ ហើយបំបែកនោះ មិនមែន កូនៗក៏បំបែក អត់បានវិលមកផ្ទះវិញទេ ទៅសម្រាកនៅការដ្ឋាន កន្លែងនោះឯងទៀត។ ប្ដីក៏ដូចគ្នា។ ហើយខ្ញុំដែលមានកូននៅតូច ល្ងាចគេឲ្យមកវិញ។ គ្រាន់តែចល័តទៅថា ដូចជាមួយភូមិប្អូនប្រាំគីឡូអ៊ីចឹងទៅ យើងទៅៗ ល្ងាចឡើងវិលមកជួបកូនវិញ។ ចាស ដល់កូនធំ លែងបៅដោះហើយនោះ គេចល័តមែនទែនហើយនោះ គេឲ្យទៅឆ្ងាយៗ យើងអាចទៅសម្រាកនៅខាងនោះបាន គេអត់ឲ្យមកវិញទេ។ ក្នុងពីរខែ បានគេឲ្យមកផ្ទះម្ដង ឬមួយខែកន្លះអី បានគេឲ្យមកជួបកូនម្ដង។

[១៤:២៨:១២]

**ស៖** មុននឹងត្រឡប់មកនិយាយអំពីពិធីរៀបការរបស់លោកស្រីវិញនោះ ខ្ញុំចោទសំណួរមួយ

ទាក់ទងនឹងប្ដីដំបូងរបស់លោកស្រី ដែលថាគេបញ្ជូនទៅឲ្យរៀនសូត្រ ដោយសារគាត់ហ្នឹង គាត់និយាយថា គាត់ជាអតីតទាហានលន់ នល់ ដោយសារកាលនោះគាត់ស្រវឹង។ អ៊ីចឹងខ្ញុំសូមសួរលោកស្រីថា តើ <ធ្វើយ៉ាងម៉េច>បានជាលោកស្រីដឹងថា គេបញ្ជូនគាត់ទៅអប់រំកែប្រែឡើងវិញនេះ?

**ឆ៖** គេបញ្ជូនទៅ គេបញ្ជូនទៅនោះ គេបញ្ជូនឲ្យទៅរៀនទេ មិនមែនគេបញ្ជូនទៅអប់រំទេ។ គេឲ្យទៅរៀនទេ គេបញ្ជូនឲ្យទៅរៀន អត់ឃើញមកវិញផងហ្នឹង។

**ស៖** អ៊ីចឹងខ្ញុំសួរលោកស្រីថា អ្នកណាដែលនិយាយប្រាប់លោកស្រីថា គេឲ្យថាគាត់ទៅរៀនហ្នឹង?

**ឆ៖** គឺកម្មាភិបាល គេឲ្យទៅរៀន។ មេកង គេមកប្រាប់ថា ឥឡូវពួកឯងត្រូវតែទៅរៀន ទៅតែបួនដប់ថ្ងៃទេ មកវិញហើយ។ ដល់ទៅបួនដប់ថ្ងៃ អត់ឃើញមកសោះ ទៅតែរហូត។ ខ្ញុំក៏នៅចាំ តាមពាក្យសន្យាថា១០ថ្ងៃ ដល់ឥឡូវអត់ឃើញមក អត់មករហូតទាល់តែឥឡូវ អត់ឃើញវិលមកវិញ។ ដឹងជាមេរៀនគាត់ប៉ុនណាទៅ បានជារៀនអត់ចេះចប់ បានវិលត្រឡប់មកវិញ។ ឆ្ងល់កន្លែងហ្នឹងមែន។

[១៤:៣១:០០]

**ស៖** ឥឡូវខ្ញុំត្រឡប់មកនិយាយអំពីពិធីរៀបការរបស់លោកស្រី ដែលលោកស្រីថា គេបានបង្ខំឲ្យលោកស្រីរៀបការ។ អម្បាញ់មិញនេះលោកស្រីបាននិយាយថា ឈ្មោះ ស៊ា ដែលប្រាប់លោកស្រីថា លោកស្រី២ថ្ងៃទៀតនឹងរៀបការ។ តើលោកស្រីដឹងដែរឬទេថា អ្នកណាជាអ្នកជ្រើសរើសប្ដីរបស់លោកស្រីហ្នឹងសម្រាប់អ្នកស្រី ដើម្បីរៀបការហ្នឹង?

**ឆ៖** ចាស ដែលគេជ្រើសរើសហ្នឹងគឺ មិត្តរ៉ុម គេអ្នកជ្រើសរើស។ មិត្តរ៉ុម អ្នកជ្រើសរើស មិត្តស៊ាគេជាអ្នកចាប់ដាក់រៀបការ។

**ស៖** តើ រ៉ុម ហ្នឹងគាត់មានតួនាទីជាអ្វីដែរនៅក្នុងឃុំ ស្រុក ឬក៏សហករណ៍ហ្នឹង គាត់មានមុខងារអីដែរ?

**ឆ៖** កម្មាភិបាល ៗនៅក្ដាប់នៅកន្លែងការដ្ឋានហ្នឹង។

**ស៖** តើកម្មាភិបាលក្ដាប់នៅការដ្ឋានហ្នឹង គាត់មានធ្លាប់បានប្រាប់លោកស្រីថា គាត់ផ្ទាល់ហ្នឹងគាត់បានទទួលសេចក្ដីណែនាំពីថ្នាក់លើមកឲ្យរៀបការលោកស្រីដែរឬទេ? <តើគាត់បាននិយាយអំពីការណែនាំពីថ្នាក់លើទេ?>

**ឆ៖** ចាស គាត់និយាយថាអ៊ីចឹង ថាពីថ្នាក់លើមក គេឲ្យ ត្រូវតែឲ្យមិត្តឯងទាំងអស់គ្នានេះរៀប

ការ។ ដល់រួចហើយ បានគេប្រាប់ មិត្តស៊ា ហ្នឹងឲ្យដើរប្រាប់អ្នកដែលមានគូរៀបការទាំងអស់នោះ ឲ្យប្រាប់ទាំងអស់គ្រប់គូហ្នឹងតែម្ដង។

**ស៖** លោកស្រីមានដឹងដែរទេថា តើការដ្ឋានហ្នឹងស្ថិតនៅក្រោមឱវាទអ្នកណាដែរ? ដូចជាអង្គភាពលោកស្រីជាដើមនេះ អង្គភាពលោកស្រីហ្នឹង <ដែលគ្រប់គ្រងដោយឈ្មោះ> រ៉ុម នេះ មិត្តរ៉ុម ហ្នឹងគាត់ស្ថិតនៅក្រោមស្រុក ឬក្រោមតំបន់ ឬក្រោមថ្នាក់ណាដែរ?

[១៤:៣៣:៣៩]

**ឆ៖** គាត់ជាប់ជាមួយនឹងស្រុក។ ស្រុកបញ្ជាគាត់មកឲ្យប្រាប់ គាត់ធ្វើ។

**ស៖** អម្បាញ់មិញលោកស្រីបាននិយាយអំពីពិធីការពីរ គឺថាពេលដែលលោកស្រីការ គឺ៦០គូ ហើយម្ដងទៀត៤០គូ។ អ៊ីចឹងខ្ញុំនិយាយអំពី៦០គូហ្នឹង។ ខ្ញុំសួរថា តើបើក្នុងចំណោម៦០គូហ្នឹង មានអ្នកខ្លះដែលគាត់យល់ព្រម ដោយចិត្តឯង គាត់រើសគូគ្នាដែរឬទេ ដោយមិនមានអ្នកណាបង្ខំ?

**ឆ៖** ក្នុង៦០គូនោះ សុទ្ធតែចាប់បង្ខំចិត្តទាំងអស់។ អត់មានអ្នកណាស្ម័គ្រចិត្តជាមួយគ្នាទេ សុទ្ធតែអត់ស្រឡាញ់ទាំងអស់។ ប៉ុន្តែចាប់បង្ខំឲ្យរៀបការនោះ គឺចេះតែការទៅ ព្រោះខ្លាចស្លាប់ហើយ បានចេះៗតែការ។ បើសិនជាកុំឲ្យស្លាប់ ប្រកែកបាន អត់ការទេ។

**ស៖** តើទាំង៦០គូហ្នឹងនោះសុទ្ធតែអ្នកមកពីប្រភេទមនុស្សដូចគ្នា ឬក៏ថាថ្នាក់ដូចគ្នា? ឧទាហរណ៍ ដូចលោកស្រី ៗមកពីប្រជាជនចាស់ <តើ>លោកស្រីការជាមួយប្រជាជនចាស់ដែរ? អ៊ីចឹងខ្ញុំចង់សួរលោកស្រីថា តើប្រជាជនចាស់ហ្នឹងមានរៀបការជាមួយប្រជាជនថ្មីទេ គេអនុញ្ញាតឲ្យធ្វើអ៊ីចឹងទេ ប្រជាជនចាស់រៀបការជាមួយប្រជាជនថ្មីអីនេះ?

**ឆ៖** ចាស ប្រជាជនចាស់ៗមានច្រើន ដល់ប្រជាជនថ្មីមានតែបីគូទេ ដែលគេចង់បានហើយស្នើរៀប ប៉ុន្តែខាងស្រីអត់ស្រឡាញ់ យំឡើងមែនទែនមុននឹងរៀបការហ្នឹង តែមិនការងាប់ សុខចិត្តថាការទៅ។

**ស៖** លោកស្រីបាននិយាយពីប្រធានកងរបស់លោកស្រីឈ្មោះ ស៊ា ហើយនិងម្នាក់ទៀតនោះ មិត្តរ៉ុម <នេះបើ>ខ្ញុំ<យល់>មិន<ខុសទេ> នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រី គឺ <E3/7234> ជាភាសាខ្មែរគឺ 0--

[១៤:៣៦:២៨]

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យគាត់ លោកព្រះរាជអាជ្ញាផ្តល់លេខ ERN មួយសាទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញាសូមលោកផ្តល់ ERN ម្តងទៀតឲ្យសម្រួលដល់អ្នកបកប្រែ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** គឺជាកិច្ចសម្ភាសន៍នៅ ភី.ធី.អូ នៅខែ៣ ឆ្នាំ<២០១៣> ឯកសារ <E3/7234> ជាភាសាខ្មែរគឺទំព័រ 01003336, ជាភាសាអង់គ្លេសគឺ 01077096 ហើយជាភាសាបារាំងគឺ 01030451 ដល់ 52។ លោកស្រីបានឆ្លើយដូចតទៅនេះ គឺលោកស្រីបាននិយាយឈ្មោះកម្មាភិបាលមួយទៀត ខ្ញុំមិនដឹងថាឈ្មោះ រ៉ុម ឬឈ្មោះណាទេ។ ឥឡូវខ្ញុំសូមដល់ស្រង់៖ “គឺមិត្តថន ជាប្រធានក្រុមដែលបានរៀបចំពិធីរៀបការហ្នឹង ហើយគាត់ជាអ្នកត្រួតពិនិត្យទៅលើប្រធានសហករណ៍ទាំងអស់។” សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងខ្ញុំសួរលោកស្រីថា កម្មាភិបាល ថន ហ្នឹងជាមនុស្សតែមួយទេជាមួយនឹង មិត្តរ៉ុម ហ្នឹង កម្មាភិបាល រ៉ុម ហ្នឹង ឬក៏មនុស្សពីរនាក់ខុសគ្នា?

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស មិត្តរ៉ុម ហ្នឹងខ្លះណា គេហៅមិត្តរ៉ុម ទៅ ខ្លះណាគេហៅ មិត្តថន ឈ្មោះគេមែនទែនឈ្មោះ ថន ដល់ឈ្មោះគេនៅក្នុងបដិវត្តន៍ហ្នឹងគេឈ្មោះ រ៉ុម។

[១៤:៣៨:២២]

**ស៖** បាទ សូមអរគុណ។ លោកស្រីបាននិយាយអំពីឈ្លបដែលមកតាមដានលោកស្រី ឬក៏មកស្តាប់លោកស្រីនៅយប់ទី១ ហើយនិង<>ប្រាំយប់<ក្រោយពីនោះទៀត>។ លោកស្រីបាននិយាយថា <លោកស្រីមិនស្គាល់ពួកគេទេ ហើយ>ពួកគេហ្នឹងមានអាយុ១៦, ១៧ឆ្នាំ ពួកគាត់បួនប្រាំនាក់ហ្នឹង។ អ៊ីចឹងខ្ញុំសួរលោកស្រីថា តើពួកនុ៎ង ឈ្លបទាំងអស់ហ្នឹងទទួលបញ្ជាមកពីណា? គេត្រូវគោរពអ្នកណាដែរ?

**ឆ៖** ចាស ឈ្លបទាំងអស់នោះគេត្រូវទទួលស្តាប់មិត្ត រ៉ុម និង មិត្តស៊ា ហ្នឹងឯង ដែលគេអ្នកដើរតាមដានអ្នកដែលរៀបការរួច។ បញ្ជាពីណោះមក បានអាពួកនោះមក។

**ស៖** អម្បាញ់មិញលោកស្រីនិយាយថា វាហួសពីខ្មាសទៅទៀត លោកស្រីបាននិយាយអំពីដំបូងហ្នឹងដែលថា ពួកឈ្លបហ្នឹងមកចាប់ប្រដាប់ភេទរបស់ប្តីលោកស្រីហ្នឹងបញ្ចូលមកក្នុងប្រដាប់ភេទរបស់លោកស្រី ថាវាលើសពីការខ្មាសទៀត។ <ដូចយើងដឹងហើយថា នៅក្នុងប្រទេសកម្ពុជា ការរួមភេទគឺ

ជាប្រធានបទដែលមិនអាចប៉ះពាល់បានទេ។ នៅក្នុងបរិបទមួយដែល>យើងត្រូវរួមភេទដោយមាន<> ឈ្លបមើល <តើ>លោកស្រីមានអារម្មណ៍ថាវាជាការអាម៉ាស់មួយសម្បើមណាស់<ទេ?> អ៊ីចឹងលោកស្រី ខ្ញុំចង់សួរលោកស្រីថា បន្ទាប់ពីទទួលការប្រព្រឹត្តបែបហ្នឹងមកលើលោកស្រីហើយ តើវាប៉ះពាល់ដល់អារម្មណ៍លោកស្រីកម្រិតណា? ហើយវាប៉ះពាល់ដល់ភាពទុកចិត្តខ្លួនឯងហ្នឹង បានកម្រិតណាដែរសម្រាប់ថ្ងៃអនាគតនោះ?

**ឆ៖** ចាស ក្នុងពេលនោះមក ខ្ញុំមានអារម្មណ៍អៀនខ្មាស ចុកចាប់ក្នុងចិត្តខ្ញុំ ចុកចាប់ខ្លាំងមែនទែន ប៉ុន្តែខ្ញុំចង់តវ៉ាជុំគេដែរ ប៉ុន្តែខ្ញុំអត់ហ៊ាន ខ្លាចគេសម្លាប់ចោល។ ម្ល៉ោះហើយការខ្មាសអៀនទាំងអស់នេះ ខ្ញុំឆាចោលថាក្តីអាម៉ាស់របស់ខ្ញុំនេះ ក្នុងមួយជីវិតខ្ញុំនេះ សំណាងអាក្រក់ដែលមកជួបហេតុការណ៍បែបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណ។ ខ្ញុំនៅសល់សំណួរបីបួនទៀតត្រូវសួរទៅគាត់ទៀត ប៉ុន្តែមើលទៅម៉ោងនោះ តើលោកប្រធានត្រូវសម្រាកឥឡូវ ឬក៏យ៉ាងម៉េចលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅ។

*(សវនាការសម្រាកពីម៉ោង ១៥:៤១ នាទី ដល់ម៉ោង ១៥:៥០ នាទី)*

[១៥:00:0៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយ!

សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី អម្បាញ់មិញលោកស្រីបាននិយាយថា មុនពេលដែលគេបង្ខំរៀបការហ្នឹង លោកស្រីបានជំទាស់<ម្តង> ហើយបន្ទាប់មកមនុស្សប្រាំនាក់មករំលោភលោកស្រីនៅពេលយប់។ គឺថាពីរថ្ងៃមុនពេលដែលលោកស្រីរៀបការដោយបង្ខំហ្នឹង។ អ៊ីចឹងលោកស្រីបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បញ្ជាក់ថា ដោយសារលោកស្រីជំទាស់ មិនព្រមរៀបការហ្នឹងហើយ បានគេរំលោភលោកស្រី។ អ៊ីចឹងខ្ញុំសួរលោកស្រីថា ហេតុអ្វី លោកស្រីមានមូលដ្ឋានអ្វីដែលអាចឲ្យលោកស្រីសន្និដ្ឋានថា ដោយសារលោកស្រីជំទាស់មិនព្រមរៀបការហ្នឹងហើយ បានគេមករំលោភលោកស្រីហ្នឹង?

**លោកស្រី មុំ វុន៖**

**ឆ៖** ក្នុងដែលគេមករំលោភខ្ញុំហ្នឹង ដល់គេរំលោភហើយ ខ្ញុំត្រូវរៀបការ។ ដល់រៀបការហើយ អ្នកដែលរំលោភខ្ញុំហ្នឹង គេនិយាយថា គិតទៅ មនុស្សយកប្រពន្ធតែងដែលគេ។ ខ្ញុំព្រួ ខ្ញុំខឹង ខ្ញុំឈឺចាប់ ខ្ញុំសឹងតែនឹងសម្លាប់ខ្លួន ដែលវារំលោភហើយ វានិយាយថាអ៊ីចឹង ខ្ញុំសឹងតែនឹងសម្លាប់ខ្លួន។ ប៉ុន្តែខ្ញុំអាណិតកូនខ្ញុំ ខ្ញុំមិនអាចសម្លាប់ខ្លួនបាន។ វាថាស៊កឲ្យប្ដីខ្ញុំ ខ្លួនខ្ញុំ ថាប្ដីខ្ញុំនេះយកប្រពន្ធដដែលគេ។ ដដែលគេ ដដែលពួកគេដែលគេចាប់រំលោភហ្នឹងហើយ។

[១៥:០២:១០]

**ស៖** ខ្ញុំសូមការបំភ្លឺមួយ ទាក់ទងទៅនឹងពេលដែលលោកស្រីរៀបការដោយបង្ខំ ដែលមាន៦០គូហ្នឹង គឺមានគូលោកស្រីផងដែរ។ គឺមានឯកសារដែលជាកិច្ចសម្ភាសន៍របស់ ធី.ភី.អូ គឺឯកសារ E3/7234 ដែលលោកស្រីបានផ្ដល់ឆ្នាំ ដូចខុសពីហ្នឹងទេ។ ERN ជាភាសាបារាំង គឺនៅទំព័រ 01030451 នៅចុងទំព័រហ្នឹង, ជាភាសាខ្មែរគឺចុងទំព័រ 01003335, ជាភាសាអង់គ្លេសគឺ 01077096។ នៅក្នុងឯកសារហ្នឹងមានសរសេរដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "នៅចុងឆ្នាំ១៩៧៦នោះ <អង្គការ>បានចាប់ផ្ដើមឲ្យបង្ខំរៀបការរួមគ្នាជាទូទៅហ្នឹង ជាញឹកញាប់គឺមាន៤០គូ<ត្រូវបានរៀបការក្នុងមួយលើក>។ គេបង្ខំឲ្យខ្ញុំរៀបការ យកប្ដីមួយទៀត។ ហើយកាលនោះមានមាន់មួយ ហើយនិងផ្កាពីរថ្ងៃប៉ុណ្ណឹងទេ ដើម្បីរៀបចំពិធីការហ្នឹង។" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងយើងមើលនៅទីនេះ លោកស្រីនិយាយថា នៅចុងឆ្នាំ១៩៧៦។ អ៊ីចឹងខ្ញុំចង់បញ្ជាក់ជាមួយលោកស្រី ព្រោះថាអម្បាញ់មិញលោកស្រីបាននិយាយថា នៅចុងឆ្នាំ១៩៧៥ <ប៉ុន្តែនៅក្នុងឯកសារនេះបញ្ជាក់ថានៅចុងឆ្នាំ១៩៧៦>។ អ៊ីចឹងខ្ញុំសួរលោកស្រីថាតើនៅក្នុងឯកសារដែលខ្ញុំដកស្រង់អម្បាញ់មិញនេះ មានកំហុស ឬក៏យ៉ាងម៉េច <ឬក៏ការរៀបការនេះបានកើតឡើងនៅក្នុងឆ្នាំ១៩៧៦ទេ>?

**ឆ៖** ចាស អត់ត្រឹមត្រូវ។ ខ្ញុំឆ្លើយអត់បាន ព្រោះខ្ញុំការនៅចុងឆ្នាំ៧៥។

**ស៖** តើគូទាំងអស់នោះ ដែលគេបង្ខំឲ្យរៀបការហ្នឹង ក្នុងពេលជាមួយគ្នាជាមួយនឹងលោកស្រីហ្នឹង ឬក៏រៀបការក្រោយលោកស្រីហ្នឹង មានបានជំទាស់មិនព្រមផ្សំដំណេកដែរឬទេ? តើករណីហ្នឹង

មានកើតឡើងទេ?

[១៥:០៤:៤៨]

**ផ៖** កើត។ គូខ្លះក៏មានជំទាស់ដែរ គូខ្លះក៏អត់ហ៊ានជំទាស់ ខ្លាចស្លាប់។ ប៉ុន្តែពីរគូដែលជំទាស់នោះ ឃើញគេហៅទៅនោះ អត់ដឹងថាទៅណាទេ ពីរគូនោះ។ ក្នុង៦០នោះ គេហៅពីរគូទៅនោះ អត់ដឹងថាទៅណាទេ។ គេផ្លាស់ចល័តផ្សេងក៏មិនដឹង គេហៅទៅណាក៏មិនដឹងដែរ ព្រោះជំទាស់ជាមួយគេ ៗ ហៅទៅ ខ្ញុំអត់ដឹងដែរ។

**ស៖** នៅក្នុងជំនួបនៅឆ្នាំ២០១៣ គឺឯកសារ E3/7235 លោកស្រីបាននិយាយពី មិត្តប៉ុល ដែលរឹងរូស – មិត្តផុល ដែលជាភាសាបារាំងគឺ 01112072, ជាភាសាអង់គ្លេស 01074565, ជាភាសាខ្មែរគឺ 01003343។ ខ្ញុំសូមអានឲ្យគ្រប់ជ្រុងជ្រោយនៃសម្រង់ហ្នឹង គឺពាក្យពេចន៍របស់លោកស្រី៖ "ខ្ញុំមិនដែលហ៊ានជំទាស់គេទេ។ ខ្ញុំសុខចិត្តទប់ចិត្តខ្លួនដើម្បីឲ្យរស់បាន។ ខ្ញុំសុខចិត្តរួមភេទចំពោះមុខពួកវាដើម្បីឲ្យនៅរស់។ ខ្ញុំនៅទប់ចិត្តមែនទែន ព្រោះពួកវាកាន់អាវុធនៅនឹងដៃ ហើយពួកហ្នឹងវាស្រួលណាស់ក្នុងការសម្លាប់មនុស្ស។ ហើយវាបានសម្លាប់ មិត្តផុល ហ្នឹងដែលរឹងរូស។ ខ្ញុំឃើញសោកនាដកម្មហ្នឹង។ អ៊ីចឹងហើយបានខ្ញុំសុខចិត្តគោរពតាមពួកវា ហើយនិងសុខចិត្តអាម៉ាស់ដើម្បីនៅរស់បន្តទៀត។"

អ៊ីចឹងខ្ញុំសួរលោកស្រីថា <តើមិត្តផុលហ្នឹងជានរណា?> តើមានរឿងអីកើតឡើងចំពោះ មិត្តផុល ហ្នឹង? ហើយ<ហេតុអ្វីបានជាពួកគេ>និយាយថា គាត់ហ្នឹងរឹងរូសហ្នឹង សុំពន្យល់បន្តិចមើល។

**ផ៖** ចាស មិត្តផុល នោះដែលគាត់រឹងរូស គាត់សុខចិត្តស្លាប់នោះ គាត់ថាគាត់អត់ព្រមស្រឡាញ់។ គាត់អត់ព្រមស្រឡាញ់គេ គាត់ជំទាស់រហូតហ្នឹង។ ដល់ឃើញគំរូហ្នឹងហើយ បានខ្លាច ខ្លាចស្លាប់ មិនហ៊ានជំទាស់។ សុខចិត្តទៅការ ដើម្បីកូន។

[១៥:០៧:៤៤]

**ស៖** មិត្តផុល នោះគេសម្លាប់គាត់មុន<>ពេលលោកស្រីរៀបការទៀត ឬក៏ក្នុងពេលជាមួយគ្នាហ្នឹង ពេលដែលគេរៀបការលោកស្រីហ្នឹងដែរហ្នឹង?

**ផ៖** មុនពេលរៀបការ។ ឃើញគំរូអាក្រក់ហ្នឹងហើយ បានខ្លាច។ សុចចិត្តតែស៊ូទ្រាំ ដើម្បីរស់ហ្នឹង ខ្លាចវាទៅដូចគ្នា។

**ស៖** អម្បាញ់មិញនៅពេលដែលលោកស្រីឆ្លើយតបទៅនឹងសំណួររបស់លោកស្រីមេធាវី ម៉ារី ហ្គីរ៉ូដ៍ លោកស្រីបាននិយាយអំពីស្ថានភាព<>ពេលលោកស្រីបានរៀបការ<ជាលើកដំបូង>។ លោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្រីថា លោកស្រីមានកូនភ្លោះផង។ អ៊ីចឹងខ្ញុំសួរលោកស្រីថា នៅពេលដែលលោកស្រីមានផ្ទៃពោះហ្នឹង តើមានថ្នាំសង្កូវអីដែរឬទេ? តើគេមានឲ្យលោកស្រីហ្នឹងធ្វើការតិចជាងមុនទេ? ហើយគេមាន<បង្កើន> របបអាហារ<ដល់លោកស្រីទេ បើធៀបនឹងអ្នកផ្សេង>ដែលមិនមានផ្ទៃពោះ<នោះ>?

**ឆ៖** ចាស អ្នកដែលមានផ្ទះពោះក៏ឲ្យធ្វើការ ចាប់ពីមានកូនមួយខែទៅដល់ប្រាំខែ គេឲ្យធ្វើការ ៦ម៉ែត្រពេញ។ ៦ម៉ែត្រពេញ ដល់កូនទម្ងន់បាន៦ខែទៅ៧ខែ អានោះគេបន្ថយឲ្យ៤ម៉ែត្រ។ ៤ម៉ែត្ររហូត ទៅដល់៩ខែ បានគេឲ្យសម្រាក ឲ្យទៅកិនស្រូវវិញ។ គេអត់ឲ្យមានសម្រាកនេះទេ ហើយរឿងអាហារ ហូបចុក អត់មានទេ។ ហូបធម្មតាដូចតែអ្នកធ្វើការធម្មតា បបរហូបដូចតែគ្នា។ សហករណ៍គេវៃជួង ទៅ យើងកាន់ចានទៅដល់នេះទៅ ក៏កាន់តែស្លាបព្រាចានទៅ ក៏ទៅហូបនឹងសហករណ៍ហ្នឹងទៅ។ មាន អីហូប ក៏ហូបនឹងសហករណ៍ហ្នឹងទៅ។ បើអត់ក៏អត់នឹងសហករណ៍ហ្នឹងទៅ។ អត់មានយកមកហូប នឹងផ្ទះបានទេ។ នៅលើផ្ទះ ឲ្យតែអង្ករតែកន្លះកំប៉ុង យប់នេះបាត់ហើយ អត់មានមនុស្សនៅផ្ទះទេ។ យើងលាក់អង្ករស៊ីឯកជន ស៊ីសួនតួ គេយកទៅសម្លាប់ហើយ គេអត់មានទុកទេ។

[១៥:១០:១៤]

**ស៖** ទាក់ទងទៅនឹងថ្នាំព្យាបាលនេះ តើគេមានឲ្យថ្នាំហ្នឹងពេលលោកស្រីមានផ្ទៃពោះហ្នឹង ហើយនិងពេលដែលសម្រាលកូនហ្នឹង គេមានឲ្យថ្នាំសមរម្យទេ គ្រប់គ្រាន់ទេ?

**ឆ៖** ចាស នៅពេលមានផ្ទៃពោះអត់ដែលមានថ្នាំអីទេ។ ពេលកើតហើយ ក៏ដាំកាប់តែដើមឈើ ហ្នឹងយកមកស្ងោរដែលត្រូវថានឹងកូន ខ្ចីក៏យកមកស្ងោរហូប អត់មានថ្នាំអីចែកទេ អត់មានទទួលខុស ត្រូវទេ។ បើគេប្រើគេប្រើ ដល់ទទួលខុសត្រូវនឹងថ្នាំសង្កូវដែលយើងសម្រាល ឬក៏មានផ្ទៃពោះ អត់មាន ទេ អត់មានឲ្យទេ។

**ស៖** លោកស្រីបាននិយាយថា នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺលោកស្រីមានកូន បួន <គឺ>មានកូនភ្លោះពីរដង។ អ៊ីចឹងខ្ញុំសួរលោកស្រីថា ក្រោយពីសម្រាលកូនលើកទី១ ហើយហ្នឹង អស់រយៈពេលប៉ុន្មានបានលោកស្រីរួមភេទជាមួយប្ដីលោកស្រីទៀត? អ៊ីចឹងខ្ញុំសួរលោកស្រីថាតើពេល ដែលរួមភេទហ្នឹង ក្រោយពេលសម្រាលកូនហើយហ្នឹង អស់រយៈពេលប៉ុន្មាន? ហើយពេលរួមភេទហ្នឹង លោកស្រីស្ម័គ្រចិត្ត ឬក៏ជាការបង្ខំ?

**ឆ៖** ចាស កាលដែលកាលណារួមភេទនឹងគាត់ ដូចជាបង្ខំចិត្តខ្លួនឯងដែរ។ បើសិនជាយើងរើ រុះ វានាំឲ្យមានរឿងហេតុ ម្ល៉ោះហើយក៏សុខចិត្តទៅ។ ក្នុងបីខែកន្លះហ្នឹង គេមក ហើយគេចូលមករួម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ភេទជុំយើង។

**ស៖** លោកស្រីបាននិយាយថា នៅពេលដែលលោកស្រីមានទម្ងន់ហ្នឹង ពេលហ្នឹងគឺត្រូវបែកពីប្ដី អ៊ីចឹងខ្ញុំសួរលោកស្រីថា ហេតុអីបានបែកពីប្ដី លោកស្រីដឹងទេ?

[១៥:១២:២៣]

**ឆ៖** បែកពីប្ដីនេះ គេបំបែកទៅ។ គេបំបែក មិនមែនងាប់ទេ បំបែករស់ គេបំបែកឲ្យទៅធ្វើការផ្សេង ឆ្ងាយៗពីយើង មិនឲ្យនៅជិតគ្នាទេ។

**ស៖** តើលោកស្រីធ្លាប់ឮកម្មាភិបាលខ្មែរក្រហមនិយាយថា កូនរបស់លោកស្រី ទោះបីកើតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ហើយនិងកូនរបស់លោកស្រីដែលកើតមុនរបបខ្មែរក្រហមនោះ លែងជាកូនរបស់លោកស្រីទៀតហើយ សុទ្ធតែជាកូនរបស់អង្គការទាំងអស់។ លោកស្រីមានធ្លាប់ឮកម្មាភិបាលខ្មែរក្រហមនិយាយដូច្នេះដែរឬទេ?

**ឆ៖** ចាស ខ្ញុំឮនិយាយថាអ៊ីចឹង ដែលគេឲ្យចល័តទៅ គេថា មានកូនអីទៀត នេះជាកូនរបស់អង្គការទេ។ ហើយម៉្យាងទៀតឲ្យខ្ញុំនេះកូន មានកូនឲ្យច្រើនទៅដើម្បីបម្រើអង្គការ គេនិយាយថាអ៊ីចឹង។ កូនៗរបស់ខ្ញុំទាំងអស់នោះក៏អត់មែនកូនខ្ញុំដែរ ព្រោះវាបែកចេញទៅអស់ហើយ មានតែអង្គការអ្នកកាន់កាប់។ ម្ល៉ោះហើយដែលកូនតូចៗនៅពីរបីឆ្នាំ អានោះវានៅជុំនឹងយាយៗ ហើយខ្ញុំក៏អត់មានកូនទៀតដែរ ទៅចល័តឆ្ងាយៗដែរ។

**ស៖** ឥឡូវខ្ញុំចូលទៅនិយាយពីប្រធានបទមួយទៀត។ នៅក្នុងកងចល័តរបស់លោកស្រី នៅក្នុងឃុំរបស់លោកស្រីហ្នឹង តើមាន<>នារី<ក្មេងៗ>ត្រូវបានគេរំលោភដែរឬទេ? <ខ្ញុំកំពុងនិយាយអំពីករណីផ្សេងៗទៀត ក្រៅពីករណីរបស់លោកស្រី ដែលត្រូវបានគេ>រំលោភ <ហើយក្រោយមក>កម្មាភិបាលមូលដ្ឋានហ្នឹងដើម្បីបង្ខំឲ្យពួកគាត់រៀបការ<> មានករណីហ្នឹងកើតឡើងទេ?

**ឆ៖** នៅក្នុងការដ្ឋានដែល--

[១៥:១៤:៤៤]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីសូមកុំអាលទាន់ឆ្លើយ!

អញ្ជើញលោកមេធាវីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមជំទាស់នឹងរបៀបចោទសំណួរនេះ។ យើងដឹងថា <អំពើហិង្សាផ្លូវភេទខ្លះមិនស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះនេះទេ។> បើរឿងដើមបណ្តឹងរដ្ឋប្បវេណី គាត់និយាយពីខ្លួនគាត់ផ្ទាល់ហ្នឹង មិនបញ្ហាអ្វីទេ ក៏ប៉ុន្តែសំណួរដែលសួរអម្បាញ់មិញនោះ ខ្ញុំឃើញថា វាមានទំនាក់ទំនងមួយដែលមានបញ្ហា គឺថា គាត់នាំមុខដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ខ្ញុំសូមឲ្យព្រះរាជអាជ្ញា គាត់កែសំណួរឡើងវិញរៀបចំសំណួរឡើងវិញ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាងលេ៖**

**ស៖** ខ្ញុំចោទសំណួរម្តងទៀត។ ក៏ប៉ុន្តែមានទំនាក់ទំនងច្បាស់ណាស់ជាមួយនឹងពិធីរៀបការ។ ឥឡូវខ្ញុំនិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកស្រីវិញម្តង លោកស្រីបាននិយាយថា គេរំលោភរបស់ស្រី ដោយសារលោកស្រីបានជំទាស់ មិនព្រមរៀបការ ហើយក្រោយមក គេរំលោភហើយបានគេបង្ខំឲ្យរៀបការទៅ។ អ៊ីចឹងខ្ញុំសួរលោកស្រី ថាតើមានស្ត្រី ឬក៏នារីផ្សេងទៀតហ្នឹងត្រូវបានគេរំលោភដែរឬទេ មុននឹងពេលរៀបការហ្នឹង?

[១៥:១៦:០៧]

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស មុននឹងពេលនេះ ដែលគេរំលោភ គឺខ្ញុំដឹងតែខ្លួនខ្ញុំទេ អ្នកផ្សេងទៀតគឺខ្ញុំអត់ដឹង។ ដឹងតែខ្លួនឯង។ អ្នកផ្សេងទៀតអត់បានឃើញ អត់បាននិយាយ។ និយាយតែរឿងការពិតទាំងអស់។

**ស៖** ដើម្បីឲ្យច្បាស់លាស់តែម្តង ខ្ញុំសូមដកស្រង់នៅក្នុងប្រតិចារឹកនៃជំនួបនៅឆ្នាំ២០១៣ របស់ដើមបណ្តឹងរដ្ឋប្បវេណី គឺឯកសារ E3/7235 គឺ<ភាសាខ្មែរ> <01003344>, ជាភាសាអង់គ្លេសគឺ 01074566, ជាភាសាបារាំងគឺ <01112074>។ បើតាមការរៀបរាប់របស់លោកស្រីហ្នឹង គឺថាមានរៀបរាប់អំពីនារី ប្រាំនាក់។ លោកស្រីនិយាយដូចតទៅនេះ នៅទំព័រហ្នឹង ខ្ញុំសូមដកស្រង់៖ "ជាពិសេសនៅឆ្នាំ១៩៧៧ហ្នឹងពួកគេ--

**កញ្ញា អង់តា ហ្គីសសេ៖**

លោកសហព្រះរាជអាជ្ញា ខ្ញុំសូមជំទាស់សិន ខ្ញុំសូមជំទាស់សិន <បើលោកសួរសំណួរមុនពេលខ្ញុំជំទាស់ នឹងមានបញ្ហាហើយ។> សូមឲ្យឆ្លើយនឹងសំណួរខ្ញុំសិន ពីព្រោះថា លោកមិនបានឃើញខ្ញុំក្រោកឈរទេ។ អ៊ីចឹងខ្ញុំសូម លោកប្រធាន ខ្ញុំសូមអភ័យទោស ព្រោះថាក្នុងស្ថានភាពនេះ គឺថាយើង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មានបញ្ហាហើយ ព្រោះឥឡូវវិសាលភាពនៃការជំនុំជម្រះនេះខុសហើយ។ ខ្ញុំឃើញថាព្រះរាជអាជ្ញា គាត់ចង់បង្ហាញពីភាពផ្ទុយគ្នានៃចម្លើយពីមុនមករបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ក៏ប៉ុន្តែបើយើងមើលពីរបៀបនៃការឆ្លើយរបស់គាត់នេះ គាត់ឆ្លើយថា គាត់មិនដឹងអំពីករណីផ្សេងទៀត ករណីរំលោភក្រៅពីករណីគាត់ផ្ទាល់។ អ៊ីចឹង<ពេលនេះមិនចាំបាច់សួរព័ត៌មាននេះបន្ថែមទៀតទេ។> អ៊ីចឹងបានថា មុននឹងចូលទៅមើលប្រតិចារឹកហ្នឹង ខ្ញុំសូមឲ្យគាត់ចោទសំណួរបើកជំហរសិន ជាទូទៅសិន មុននឹងចូលទៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ ដែលមែនទែនទៅវានៅក្រៅវិសាលភាពផង។ អ៊ីចឹងសូមឲ្យចោទសំណួរជាលក្ខណៈទូទៅសិនទៅ ដើម្បីកុំឲ្យវាបង្កជាបញ្ហា<នៅពេលក្រោយ>។

[១៥:១៨:៤៧]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវី ប្រហែលជាលោកស្រីអនុញ្ញាតឲ្យគាត់ដកស្រង់សិនទៅ ដើម្បីឲ្យយើងដឹងថា យើងទៅដល់ទីណា។ បន្ទាប់មកទៀត យើងអាចនិយាយថា ថាតើយើងអនុញ្ញាតឲ្យឆ្លើយ ឬក៏អត់? ឥឡូវហ្នឹងយើងអត់ដឹងថាតើព្រះរាជអាជ្ញា គាត់នឹងដកស្រង់សម្រង់ណាមួយផងហ្នឹង។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាងលេ៖**

**ស៖** សូមអរគុណលោកស្រីចៅក្រម។ ខ្ញុំគ្រាន់សូមបញ្ជាក់អំពីផ្នែកដែលខ្ញុំនឹងអាន គឺថាដោយ-សារវាមានទំនាក់ទំនងជាមួយនឹងការរៀបការ ហើយនិងអ្វីដែលកើតឡើងចំពោះពួកបុគ្គលទាំងអស់ហ្នឹងនៅពេលក្រោយទៀត។ គឺថាគាត់និយាយដូចតទៅនេះ ថា៖ "ជាពិសេសក្នុងឆ្នាំ១៩៧៧ហ្នឹង <គាត់បានដេកជាមួយក្មេងស្រីជាច្រើន ដែលអ្នកទាំងនោះត្រូវបានគេកំណត់ទុកឲ្យ>រៀបការ<នឹងអ្នកផ្សេងនៅពេលក្រោយ។ ក្រោយពីរឿងនេះ ប្ដីប្រពន្ធទាំងនោះលែងចង់រស់នៅជាមួយសង្សាររបស់ពួកគេ ហើយនៅទីបញ្ចប់ពួក>កម្មាភិបាល<បានសម្លាប់ពួកគេទាំងពីរនាក់ ទាំងប្ដី ទាំងប្រពន្ធ។" បញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំមិនដឹងថាតើយើងកំពុងតែនិយាយអំពី>ពហុវចនៈ ឬឯកវចនៈទេ <ព្រោះថាពេលយើងបកប្រែមកពីភាសាខ្មែរមកនោះ វាមិនច្បាស់>។

អ៊ីចឹងខ្ញុំចង់សួរលោកស្រីថា តើ<>មាន<>ករណីហ្នឹង<កើតឡើង>ដែរឬទេ ថាស្ត្រីដែលនឹងរៀបការជាមួយនឹងអនាគតប្ដីរបស់គាត់ហ្នឹង ហើយប្ដីរបស់គាត់ហ្នឹង បដិសេធមិនព្រមរៀបការជាមួយគាត់ទេ ដោយសារស្ត្រីទាំងអស់ហ្នឹង ត្រូវបានគេរំលោភមុនហើយ បានយកទៅរៀបការ?

[១៥:២០:២៥]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយហើយ គាត់ថា គាត់អត់មានដឹងរឿងណា ក្រៅពីរឿងរបស់គាត់ទេ។ ដូច្នេះនេះជាចម្លើយច្បាស់លាស់មួយហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមអធ្យាស្រ័យ នៅក្នុងតុលាការនេះ គឺក៏យើងអនុញ្ញាតឲ្យមេធាវីការពារក្ដីឲ្យ<ព្យាយាមរំឭកការចងចាំរបស់>សាក្សី <ឬ>ដើមបណ្ដឹងរដ្ឋប្បវេណី <ដោយប្រើប្រាស់>សក្ខីកម្មរបស់សាក្សីផ្សេង និងដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងផងដែរ។ នេះជាការព្យាយាមរបស់ខាងសហព្រះរាជអាជ្ញា ចង់ធ្វើអ៊ីចឹង ប៉ុន្តែបើសិនជាគាត់គ្មានបំណងណាក្រៅពីហ្នឹងទេ គឺថាគាត់អាចធ្វើទៅបាន។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកស្រីចៅក្រម តាមពិត នេះជាពាក្យសម្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះឯង។

[១៥:២១:២៦]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** អ៊ីចឹងខ្ញុំសួរលោកស្រី តើសម្រង់នេះ អ្វីដែលខ្ញុំអានជូនលោកស្រីស្ដាប់អម្បាញ់មិញហ្នឹង ធ្វើឲ្យលោកស្រីនឹកឃើញអំពីអ្វីដែលលោកស្រីបាននិយាយពីមុនមកទេ? ហើយអាចរៀបរាប់ជូនតុលាការបញ្ជាក់ពីចំណុចហ្នឹងបានទេ?

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស ខ្ញុំឆ្លើយបញ្ជាក់បាន។ តែខ្ញុំ ដែលលោកនិយាយមកអំមិញ ខ្ញុំស្មានថា អ្នករៀបការៗដូចខ្ញុំហ្នឹង វាយ៉ាងម៉េច។ ដល់គេថា អ្នកកម្មាភិបាលដែលគេហៅពួកស្រីៗ ប្រាំនាក់ហ្នឹងទៅនោះ អាហ្នឹងរឿងហ្នឹង ខ្ញុំដឹង ប៉ុន្តែដល់ថា គេរំលោភ គេអត់យកគ្នានោះ អានេះខ្ញុំអត់ដឹងមែន។ ប៉ុន្តែអាកន្លែងដូចថា កម្មាភិបាលគេហៅប្រាំនាក់ទៅ កន្លែងគេនោះ ខ្ញុំឃើញគេហៅទៅមែន។ អាកន្លែងហ្នឹងហៅទៅ ប្រាំនាក់។ តែពួកនារីៗហ្នឹង គេដេកនឹងរនាប ហើយអ្នកកម្មាភិបាលហ្នឹងគេដេកលើអង្រឹង។ តែដល់យប់ឡើង ដែលពួកខ្ញុំនៅនឹងជិតនោះ ឮស្នូរតែមាត់យំ ហើយរឿងរ៉ាវទាំងអស់នោះ វាកើតឡើង។

**ស៖** បាទ ខ្ញុំមានពេល សល់ពេលតិចណាស់ ខ្ញុំមានពីរបីសំណួរទៀត។ ខ្ញុំចោទសំណួរបើក តើលោកស្រីមានស្គាល់ឈ្មោះ ឌិន ទេ លោកស្រី?

**ឆ៖** ចាស ខ្ញុំស្គាល់ឈ្មោះ ឌិន។ ឈ្មោះ ឌិន នេះគាត់ជាវៀតណាម។ គាត់ជាវៀតណាមនោះគាត់នៅតាំងពីយូរហើយ ប៉ុន្តែដល់រួចមក ពួកក្រុមមិត្តៗនេះ គាត់ស៊ើបថា ភូមិយើងមានវៀតណាមដែរឬអត់។ ហើយមិត្ត ឌិន នេះគាត់នៅកន្លែងសហករណ៍ គាត់នៅដាំបាយ។ ដល់កាលណា គេស៊ើបដឹងហើយ គេហៅមិត្ត ឌិន ហ្នឹងយកទៅ។ ទៅនៅវត្តកំពង់ក្តីហ្នឹង។

[១៥:២៣:៥៩]

**ស៖** តើលោកស្រីដឹងថា មានរឿងអីកើតឡើងចំពោះ ឌិន ហ្នឹងនៅកំពង់ក្តីដែរឬទេ?

**ឆ៖** ចាស មានហេតុការណ៍ ដោយមិត្ត ឌិន ហ្នឹងគាត់វៀតណាម ដល់រួចហើយពួកមិត្ត កោះហៅយកទៅ។ នៅវត្តកំពង់ក្តីហ្នឹង ហៅដល់រួចហើយ គ្នាគេបួននាក់ហ្នឹងគេយកទៅ ពួកខ្ញុំនៅរែកដីពីវត្តកំពង់ក្តីហ្នឹង ចេញទៅខាងកើតភូមិហ្នឹង រែកដីដាក់ស្រែ។ ដល់ហើយឮសូរតែមាត់ស្រែក។ ដល់រួចហើយ គេទាំងបួននាក់នោះ គេរំលោភហើយ ដល់រួចមក គេពុះឆ្អឹងខ្នង។ គេពុះយកឆ្អឹងខ្នង គេយកប្រមាត់ត្រាំស្រា។ ពុះយកប្រមាត់ត្រាំស្រាហើយ ដល់រួចហើយគេយកស្រានោះមកផឹក ហើយគេដើរស្រែកទៀតថា ស្តាយណាស់ បើសិនកុំរំលោភ យកតែប្រមាត់ ពុះយកតែប្រមាត់វាមកត្រាំស្រាមក អត់ធុំសាសោះ។ វានិយាយថាអ៊ីចឹង។ ហើយបើកាលណាពួកខ្ញុំនៅប្រហែលជា១០ម៉ែត្រពីគ្នា ឮសូរវាស្រែកថាអ៊ីចឹង អត់មានហ៊ានងើបទេ រែក តែអង្រែកបង្គីហ្នឹង ឈ្ងោកទៅរហូតបណ្តោយ។ ដាក់នៅបង្គន់យាយរាង បង្គន់យាយរាង នៅសព្វថ្ងៃ ដែលដាក់ឈ្មោះ មិត្តឌិន ហ្នឹង វៀតណាម។ ឲ្យតែវៀតណាមគឺហៅយកសម្លាប់ទាំងអស់ អត់មានទុកទេ។ បើចិនបាននៅ។

**ស៖** សំណួរចុងក្រោយ តើមានជនជាតិចាមដែរឬទេ ដែលរស់នៅឃុំរបស់លោកស្រី ឬក៏ដែលគេបញ្ជូនទៅឃុំរបស់លោកស្រី ឬក៏នៅក្នុងកងចល័តរបស់លោកស្រីដែរឬទេ?

[១៥:២៥:៥០]

**ឆ៖** ចាស ចំណែកឯចាមអត់មានទេ ចាស អត់មានចាមទេ។ មានវៀតណាម មានតែមួយប៉ុណ្ណឹងឯង។ ហើយគេហៅទៅសម្លាប់តែមួយហ្នឹងទៅ វាអស់វៀតណាម អត់មានទេ។ ដល់ចាម អត់មានទេ អត់មាននៅក្នុងឃុំ នៅក្នុងកងចល័តក៏អត់មានចាមដែរ។ ហើយម្យ៉ាងទៀតក៏គេអត់និយាយប្រាប់គេថាចាម ថាអីយ៉ាងណាក៏មិនដឹង។ បើឮគេថា តែខ្មែរៗតែទាំងអស់ ក៏ខ្មែរទៅ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ យើងអស់សំណួរហើយ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា!

**លោក លីវ សុវណ្ណា៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមគោរពភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំឈ្មោះ លីវ សុវណ្ណា ជាមេធាវីជាតិនៅក្នុងក្រុមការពារក្ដីលោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួនសួរលោកស្រី។ សំណួរទី១ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ឲ្យបានច្បាស់ថា តើក្នុងជីវិតរបស់លោកស្រី ៗមានប្ដីប៉ុន្មាននាក់?

[១៥:២៧:២៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សំណួរដូចជាសំណួរច្រំដែល។

**លោក លីវ សុវណ្ណា៖**

បាទ លោកប្រធាន គាត់អត់ -- គ្រាន់តែគាត់ប្រាប់ថាប្ដីមុន ប្ដីក្រោយ ប៉ុន្តែខ្ញុំបាទចង់ដឹងថាតើវាមានប៉ុន្មាន តែពីរហ្នឹង ឬក៏លើសពីពីរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្ដឹងរដ្ឋប្បវេណី ឆ្លើយតាមសំណួរ។

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស ប្ដីខ្ញុំមានតែពីរហ្នឹងឯង។ ការពីសង្គមរាស្ត្រនិយម ការដោយក្ដីបង្ខំ មានតែពីរគត់ អត់មានបីទេ។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បាទ អរគុណលោកស្រី។

**ឆ៖** ចាស។

**ស៖** តើប្ដីទី១របស់លោកស្រី គាត់ឈ្មោះអីដែរ?

**ឆ៖** ប្ដីទី១របស់ខ្ញុំឈ្មោះ តាន់ ហ៊ឹង។ ប្ដីទី២ឈ្មោះ អ៊ុន ធិន។

**ស៖** បាទ អរគុណលោកស្រី។ ខ្ញុំចង់ដឹងថា មុខរបបរបស់ប្ដីលោកស្រីមុន ៗឆ្នាំ១៩៧៥ បានន័យថា មុនរបបកម្ពុជាប្រជាធិបតេយ្យ តើគាត់ធ្វើអីដែរ?

[១៥:២៨:៥៤]

**ឆ៖** ចាស មុខរបបរបស់គាត់ ចាប់តាំងពីខ្ញុំការរួចមក គាត់ឡើងតែត្នោតរហូត អត់មានធ្វើអីទេ។ ឡើងតែត្នោត ធ្វើស្រែ អត់មានធ្វើអីទេ។ មិនមានមន្ត្រីរាជការអីក៏អត់មានដែរ។

**ស៖** បាទ លោកស្រី ដោយសារម៉ោងខ្លី ខ្ញុំចង់បញ្ជាក់មួយទៀត តើកូនលោកស្រីប្ដីមុន ជាមួយប្ដីមុនចំនួនប្រាំបីនាក់ហ្នឹង គាត់កើតនៅមុនឆ្នាំ១៩៧៥ បានន័យថា មុនរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏មានកើតក្រោយកម្ពុជាប្រជាធិបតេយ្យដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកស្រីចាំមីក្រូហ្វូនប្រតិបត្តិការសិន ចាំឆ្លើយ។

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស កូនខ្ញុំដែលនេះ កើតៗមុន។ ចាស កើតតាំងពីឆ្នាំ១៩៦៥, ៦៦មក។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បាទៗ អរគុណ។

**ឆ៖** ចាស។

**ស៖** ដោយសារពេលវេលា ខ្ញុំសូមកាត់លោកស្រី។ អំមិញលោកស្រីថា ប្ដីលោកស្រីក្រោយឈ្មោះ ធិន។

[១៥:២៩:៥៤]

**ឆ៖** ចាស។

**ស៖** អ៊ីចឹងមុខរបបរបស់គាត់ លោកស្រីដឹងទេ មុខរបបគាត់មុនរបបកម្ពុជាប្រជាធិបតេយ្យ គាត់ធ្វើអីដែរ?

**ឆ៖** ប្ដីមុន ក៏ក្រោយ?

**ស៖** បាទ ប្ដីក្រោយឈ្មោះ ធិន ហ្នឹងហើយបាទ?

**ឆ៖** ប្ដីក្រោយអត់ដឹងប្រវត្តិគាត់ទេ ដឹងតែចល័តមករៀបការបណ្ដោយ។ អត់មានៗគោលដ្ឋានថា ធ្វើអីនិងធ្វើអីពីនោះមក អត់មានទេ ដឹងតែនឹងកងចល័តហ្នឹងឯង។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែហើយមើលទៅ ព្រោះថា ខ្ញុំឮនៅក្នុងចម្លើយជាភាសាបារាំងនេះ ថា<កូនគាត់ទាំងប្រាំបីនាក់>ហ្នឹង<បាន>កើតចន្លោះឆ្នាំ<១៩៦៥> និង<៦៧>។ អ៊ីចឹងកាលបរិច្ឆេទនេះវាមិនសមស្របទេ ព្រោះអ៊ីចឹងអាចបំភ្លឺចំណុចហ្នឹងបានទេ<>?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគិតថា ប្រហែលជាដោយសារតែពិបាកក្នុងការស្ដាប់ ដោយសារតែពួកគាត់ទាំងពីរហ្នឹងនិយាយភាសាខ្មែរដូចគ្នា។ ដូច្នេះខ្ញុំយល់ថាល្អ គួរតែពួកលោកទាំងពីរហ្នឹងគឺទុកចន្លោះបន្តិចសិន មុននឹងឆ្លើយ ឬក៏សួរបន្ត។

[១៥:៣១:២៨]

**លោក លីវ សុវណ្ណា៖**

បាទ សូមអរគុណលោកស្រីចៅក្រម។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បាទ អ៊ីចឹងយើងអំមិញយើងពិភាក្សាប្ដីក្រោយរបស់លោកស្រីឈ្មោះ ធិន។ អ៊ីចឹងលោកស្រីថា មុខរបរមុនឆ្នាំ៧៥ លោកស្រីអត់ដឹងទេ។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅក្នុងកម្ពុជាប្រជាធិបតេយ្យ ជាពិសេសគាត់ពេលរៀបការជាមួយលោកស្រីហើយ តើគាត់ធ្វើការងារអីដែរ?

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស ដែលក្នុងរបបប្រជាធិបតេយ្យនេះ គាត់ការរួចហើយ ក៏គាត់ចល័ត គាត់អត់មានមុខរបរអី ព្រោះគាត់នៅតែចល័តដដែលហ្នឹង នៅតែលើកដី នៅតែទៅធ្វើការងារផ្សេងៗទៀត ព្រោះដែលខ្ញុំការបង្ខំចិត្ត មិនអាចដឹងប្រវត្តិគេថាយ៉ាងណាទេ។ ព្រោះការបង្ខំចិត្ត ចេះតែការដូចខ្ញុំបានជម្រាបលើក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មុនថា បើសិនជាខ្ញុំមិនការ ខ្ញុំនឹងត្រូវស្លាប់ ម្ល៉ោះហើយខ្ញុំចេះតែការទៅ ដើម្បីឲ្យរួចខ្លួន។ កន្លែងត្រង់នេះហើយបានខ្ញុំបញ្ជាក់ឲ្យបានដឹង ព្រោះច្រឡំ ប្រយ័ត្នច្រឡំប្ដីទី១ កូនប្រាំបួនកូន ប្ដីក្រោយនេះកូនបួន ប្រយ័ត្នច្រឡំអាកន្លែងហ្នឹង។

**សៈ** អ៊ីចឹងខ្ញុំចង់ដឹងប្ដីក្រោយរបស់លោកស្រី ព្រោះខ្ញុំបញ្ជាក់អំមិញថា ប្ដីក្រោយហើយ។ អ៊ីចឹងខ្ញុំចង់ដឹងថា សូមលោកស្រីបញ្ជាក់ពីប្រភេទមុខរបរ ការងារដែលគេឲ្យគាត់ធ្វើហ្នឹង គាត់គេឲ្យធ្វើអីខ្លះ សូមលោកស្រីបញ្ជាក់ឲ្យបានច្បាស់បន្តិច?

[១៥:៣៣:០៦]

**ឆះ** បញ្ជាក់ក្នុងការងារដែលរបបខ្មែរក្រហមហ្នឹង? អត់មានមុខរបរអីក្រៅតែពីរែកដី លើកទំនប់ទេ គឺចល័តរហូត សូម្បីតែខ្ញុំមានផ្ទៃពោះពីរបីខែហើយនោះក៏ទៅដែរ។ ទៅហើយពីរខែបានវិលមកជួបប្រពន្ធវិញ អត់មានទៅរហូត អត់មានលែងលះគ្នាទេ។ កាលណាដែលទៅហើយ បើកាលណាខ្ញុំកើតកូន គាត់មកបានតែពីរថ្ងៃទេ គេហៅទៅទៀត គេថាខ្ញុំនេះមានពេទ្យមើលថែហើយ វាអ៊ីចឹង។ ដល់តែកាលណារួចហើយ គាត់ក៏ទៅវិញទៅ មុខរបរមានតែប៉ុណ្ណឹងឯងរហូតទៅដល់ឆ្នាំ៨២ ខ្ញុំកើតកូនមួយទៀត កើតកូនពីរទៀតម្ល៉ោះហើយស្លាប់ កើតរួចហើយស្លាប់។ ដល់រួចមកបន្តទៅទៀតហ្នឹង ទៅដល់៨៤ បែកគ្នារហូត។ នេះស្ដាប់ឲ្យបានន័យកន្លែងហ្នឹង ព្រោះខ្ញុំបានបញ្ជាក់ជាមួយនឹងមេធាវីហើយថា បែកគ្នានៅ៨៤ ប្ដីក្រោយខ្ញុំហ្នឹង។ ហើយបែកគ្នានោះ ក៏គាត់មិនដឹងថាទៅណាមកណាដែរ គឺខ្ញុំអត់ដឹងដែរ ព្រោះបែកហើយ វាបែកទៅ បែកឲ្យរហូតទៅ សូមបែកគ្នាហើយ ក៏បែកទៅ អត់មានពិបាកសាំញ៉ាំច្រើនទេ ជាមួយខ្ញុំនោះ។ វាបានតែទៅអ៊ីចុះទៅហើយ ឲ្យវាទៅឲ្យផុតទៅចុះ វាផុតហើយ។

**សៈ** បាទ សូមទោសលោកស្រី ខ្ញុំសូមកាត់លោកស្រីបន្តិច។ អ៊ីចឹងគាត់ តើគាត់ហ្នឹងគាត់មានឪពុកម្ដាយដែរទេ ប្ដីក្រោយរបស់លោកស្រីហ្នឹង?

[១៥:៣៤:៣៥]

**ឆះ** ចាស ចំណែកឪពុកម្ដាយគាត់ បងប្អូនគាត់បួននាក់ដែលបានរស់នៅនោះ គាត់ថាដែលគាត់ចេញមកនោះ គេសម្លាប់ចោលអស់ហើយ គាត់អត់មានឪពុកម្ដាយទេ។ ដល់រួចហើយគាត់ដើរមកចល័តពេញទាំងអស់។ តែស្រុកភូមិគាត់នៅក្រឡាញ់ ប៉ុន្តែម៉ែឪគាត់ស្លាប់អស់ហើយ គាត់អត់មានទៅចូលស្រុកវិញទេ។ ដល់មកការជាមួយខ្ញុំហ្នឹង ដល់រួចមកបែកជាមួយខ្ញុំហ្នឹង អត់ដឹងថាគាត់ទៅណា ទៅម៉ែឪបងប្អូនវិញ ក៏មិនដឹងថាទៅណាទេ ព្រោះអត់មានម៉ែឪនោះ ទៅឯណា អត់ដឹងថាទៅណាទេ។ ពី

៨៤ ទៅបែករហូត អត់មាននៅទេ។ បើនៅខ្ញុំប្រាប់ថានៅ ព្រោះខ្ញុំអត់ចេះកុហក ខ្ញុំស្អប់បំផុតមនុស្សកុហក។ និយាយណា គឺនិយាយនោះ ១០គឺ១០, ២០គឺ២០។ បើនិយាយក្រឡាស់សម្ដី មនុស្សអត់បានការ ហើយខ្ញុំស្អប់ ៗដល់ឆ្អឹង ស្អប់ក្នុងជីវិតខ្ញុំ ស្អប់រហូតអ្នកកុហក។

**ស៖** បាទ លោកស្រី ដោយសារពេលវេលា ខ្ញុំសូមបន្តសំណួរខ្ញុំ។ នៅក្នុងពេលព្រឹកមិញលោកស្រីថា ពេលរៀបការលោកស្រីហ្នឹង គឺមានតែមាន់មួយ ហើយនិងផ្កាពីរថ្ង។ អ៊ីចឹងខ្ញុំចង់ដឹងថា តើមាន់មួយហ្នឹង គេទុកសម្រាប់ធ្វើអ្វីដែរ?

**ឆ៖** ចាស សម្រាប់មាន់មួយ និងផ្កាពីរថ្ងហ្នឹង គឺសម្រាប់រៀបការក្នុង៦០គូហ្នឹងឯង ឲ្យមានមាន់មួយទៅ ប៉ុន្តែអត់មានធូបដោតទេ មានតែមាន់ និងផ្កាពីរថ្ងហ្នឹងហើយដែលជាចងក្រងនឹងការរៀបការហ្នឹង ឲ្យបានល្អទាំងអស់៦០គូ ព្រោះមាន់តែមួយហ្នឹងឯង មេបាស៊ីមាន់តែមួយហ្នឹងឯង៦០គូ។

**ស៖** អ៊ីចឹងមាន់មួយហ្នឹង គេទុកសម្រាប់សែន បើតាមលោកស្រី បើខ្ញុំថាលោកស្រីថា ទុកមេបាហ្នឹង គឺមាន់មួយហ្នឹងគឺសែនមែន ឬមិនមែនបាទ?

[១៥:៣៦:៤១]

**ឆ៖** វាដែលគេដាក់នៅលើតុអ៊ីចឹង ប្រៀបធៀបថា ដូចគេដាក់សែនហ្នឹងហើយ ផ្កាពីរថ្ង មាន់មួយហ្នឹង គឺប្រៀបធៀបទៅដូចគេដាក់សែនហើយ ព្រោះកាលណាដែលរៀបការរួចហើយ មាន់នោះពួកគេអ្នកនោះឯង គេយកទៅហូប។ អាពួកយើងសម្ដូរព្រលឹត ដូចខ្ញុំបានជម្រាបមុនអ៊ីចឹង។

**ស៖** បាទ អរគុណលោកស្រី។ ឥឡូវយើងចូលដល់ចំណុចមួយទៀត ខ្ញុំចង់ដឹងពីកូនលោកស្រី តើកូនលោកស្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង លោកស្រីថា ឆ្លងទន្លេបានកូនប្អូននាក់។ អ៊ីចឹងខ្ញុំចង់ដឹងថា តើឆ្លងទន្លេពេលណាខ្លះ?

**ឆ៖** ចាស ឆ្លងទន្លេលើកទី១ ពី១៩៧៦ ចុងឆ្នាំ កើតពីរ កូនភ្លោះ ស្រីមួយ ប្រុសមួយ។ កូនទី២ កើតចុងឆ្នាំ១៩៧៧ ភ្លោះប្រុសទាំងអស់ចាស។ ហើយដល់ឆ្លង អាហ្នឹងនិយាយសរុបទាំងអស់ណ៎ា ក្នុងកូនលើកទី៣ ភ្លោះទៀត កើតក្នុងឆ្នាំ១៩៨២ហ្នឹង ស្លាប់ទាំងអស់ កើតហើយស្លាប់។ ព្រោះកាលណាកាលនេះ សុខភាពខ្ញុំវាអត់ល្អ កាលណាដល់រួចមក វាកើតស្លាប់តែម្ដង។ ហើយកាលណាដែលបែកប្ដីខ្ញុំ ៨៤ នេះជម្រាបកុំឲ្យសង្ស័យទាំងអស់។

**ស៖** បាទ អរគុណលោកស្រី។ ខ្ញុំចង់បញ្ជាក់ចំណុចមួយទៀត គឺលោកស្រីអំមិញថា ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិថា ឈ្មោះ រ៉ុម និងឈ្មោះ ថន មនុស្សតែមួយ។ អ៊ីចឹងខ្ញុំ

ចង់ដឹងថា តើឈ្មោះ រ៉ុម ឬឈ្មោះ ថន ហ្នឹងគាត់ស្រី ឬប្រុស?

**ឆ៖** ចាស គាត់ប្រុស កម្មាភិបាល។ ចាស គាត់ប្រុស មិនមែនស្រីទេ។ មិត្តស៊ា, មិត្តសន មិត្ត រ៉ុម ហ្នឹងសុទ្ធតែប្រុសទាំងបីរូប អត់មានស្រីទេ។

**ស៖** បាទ តួនាទីរបស់ មិត្តរ៉ុម ហ្នឹងពិតប្រាកដ គាត់មានតួនាទីអីដែរ? សូមលោកស្រីបញ្ជាក់ឲ្យ ច្បាស់បន្តិចបាទ។

[១៥:៣៩:២២]

**ឆ៖** គាត់ពីអង្គាល់នោះ គាត់នៅសាខាស្រុក។ តែប្រធានស្រុកគេដាក់មកគាត់ គឺគាត់មានតួនាទី មករៀបចំ។ គាត់មករៀបចំនៅកន្លែងការដ្ឋាន បើគេខាងស្រុក គេបញ្ជាមកថា ឥឡូវមិត្តឯងត្រូវរៀប កន្លែងនោះឲ្យរៀបការ គាត់ចុះមកហើយរៀបចំ។ អ្នកណានឹងគូនឹងអ្នកណា គឺគាត់អត់ដឹងទេ ដឹងតែ រៀបចំតែម្តងហើយ អត់មានទេ។ ស្រលាញ់ក៏ដោយ មិនស្រលាញ់ក៏ដោយ រៀបចំ ហៅរៀបការតែទាំង អស់ហ្នឹងឯង។ ម៉ាអាគេអត់យកចេះតែរៀបទៅ គេមិនស្រលាញ់ក៏រៀបទៅ អំណាចនៅលើគេហើយ គេចង់ធ្វើអី ក៏ធ្វើទៅ រឿងផន់គេ។ អាយើងអ្នករងទុក្ខ ក៏ទុក្ខតែរហូតហ្នឹង។

**ស៖** បាទ ខ្ញុំសូមបន្តសំណួរខ្ញុំ។ អ៊ីចឹងបើលោកស្រីថា គាត់ជាសាខាស្រុក។ អ៊ីចឹងខ្ញុំចង់ដឹងថា តើអ្នកណាគេជាប្រធានខ្សែ គេហៅថា ខ្សែក្តាប់លើប្រធានសហករណ៍ហ្នឹង អ្នកណាគេវិញទៅ?

**ឆ៖** ចាស ដែលលោកប្រធានខ្សែហ្នឹងគឺ មិត្តស៊ា។ អ្នកដែលក្តាប់ពីលើប្រធានសហករណ៍នោះ គឺ មិត្តស៊ា គាត់អ្នកក្តាប់។ កន្លែងការដ្ឋាន កន្លែងអីទាំងប៉ុន្មាន គឺនៅលើ មិត្តស៊ា ទាំងអស់។

**ស៖** លោកប្រធាន ខ្ញុំបាទសូមអនុញ្ញាតអានឯកសារមួយ ដើម្បីរំឭកការចងចាំរបស់សាក្សី គឺ ឯកសារលេខ E3/7234 ត្រង់ ERN ជាភាសាខ្មែរ 01003336, ជាភាសាអង់គ្លេសមានលេខ 00077 096, ជាភាសាបារាំងមានលេខ 01030452។ ក្នុងហ្នឹងលោកស្រីបានឆ្លើយថា ខ្ញុំសូមដកស្រង់៖ "ការ រៀបចំនេះធ្វើឡើងដោយសមមិត្ត ថន ដែលជាប្រធានខ្សែក្តាប់លើប្រធានសហករណ៍ទាំងអស់។" អ៊ីចឹង សំណួរខ្ញុំចង់សួរថា ហេតុអីបានជា អំមិញខ្ញុំសួរបញ្ជាក់លោកស្រីថា ឈ្មោះ ស៊ា ជាអ្នកប្រធានខ្សែក្តាប់ លើសហករណ៍ទាំងអស់ តែនៅក្នុងឯកសាររបស់លោកស្រី បែរជាលោកស្រីសមមិត្ត ថន វិញ។ បាទ សូមលោកស្រីបញ្ជាក់បន្តិចមើល តើអាហ្នឹងវាខុសគ្នាម៉េច?

[១៥:៤១:៥៨]

**ឆ៖** មិត្តថន នោះគឺ មិត្តរ៉ុម មនុស្សតែមួយទេ ប៉ុន្តែឈ្មោះពីរ។ អាខាងនោះគាត់អ្នកសាខាស្រុក

គេបញ្ជាមក មកលើប្រធានខ្សែខាងណោះ មិត្តស៊ា ហ្នឹងហើយ។ នេះខ្ញុំបញ្ជាក់។

**ស៖** ឥឡូវថាមិត្តថន និងមិត្តរ៉ុម ប៉ុន្តែខ្ញុំសំណួរខ្ញុំចង់ដឹងថា អំមិញលោកស្រីអះអាងថា មិត្តស៊ាជាប្រធានខ្សែក្តាប់លើប្រធានសហករណ៍ទាំងអស់។ ប៉ុន្តែនៅក្នុងចម្លើយរបស់លោកស្រីគឺ មិត្តថន ឬ មិត្តរ៉ុម ជាប្រធានខ្សែវិញ។ ហេតុអីបានជាចម្លើយពីរនេះវាផ្ទុយគ្នា លោកស្រីអាចពន្យល់អង្គសវនាការបានទេ?

**ឆ៖** ចាសមិត្តថន ជាមួយមិត្តរ៉ុម មនុស្សតែម្នាក់ទេ ប៉ុន្តែឈ្មោះពីរ ឈ្មោះពីរ។ ប្រធានខ្សែ និងសាខាស្រុក ខាងស្រុក គេធំជាងខ្សែ។ បញ្ជាពីខាងស្រុកហ្នឹងមក អ្នកខាងខ្សែ អ្នករៀបចំ។ ត្រូវអត់?

**ស៖** ប្រហែលជាសំណួរខ្ញុំមិនច្បាស់។ ខ្ញុំសូមរឭកលោកស្រីវិញថា មុននេះខ្ញុំសួរថា តើអ្នកណាគេជាប្រធានខ្សែក្តាប់លើប្រធានសហករណ៍ទាំងអស់? លោកស្រីបានឆ្លើយថាគឺ មិត្តស៊ា។ ប៉ុន្តែនៅក្នុងចម្លើយដែលលោកស្រីបានផ្តល់ជូនទៅអង្គការ ធី.ភី.អូ ដែលមានឯកសារ E3/7234 ដែលខ្ញុំសុំដកស្រង់គឺលោកស្រីបាននិយាយថា ការរៀបចំការលោកស្រីហ្នឹង ធ្វើឡើងដោយសមមិត្តថន ដែលជាប្រធានខ្សែក្តាប់លើប្រធានសហករណ៍ទាំងអស់។ អ៊ីចឹងសមមិត្ត ថន ឬសមមិត្ត រ៉ុម ពេលនេះលោកស្រី នៅក្នុងឯកសារនេះ លោកស្រីថាជាប្រធានខ្សែក្តាប់លើប្រធានសហករណ៍ទាំងអស់។ ប៉ុន្តែមុនដែលខ្ញុំសួរលោកស្រីបែរជាថា មិត្តស៊ា។ អ៊ីចឹងខ្ញុំចង់ដឹង ហេតុអីបានជាមានភាពខុសគ្នារវាង មិត្តថន ហើយនិងមិត្ត រ៉ុម ឬមិត្តស៊ា ហ្នឹង អ្នកណាមួយជាប្រធានខ្សែឲ្យបានច្បាស់លាស់?

[១៥:៤៤:០៥]

**ឆ៖** ខ្ញុំបញ្ជាក់ហើយ ថាមិត្តរ៉ុម នោះគាត់អ្នកសាខាស្រុកទេ មិត្តរ៉ុម។ មិត្តរ៉ុម គឺមិត្តថន។ ស្តាប់បានកន្លែងនេះ ប្រយ័ត្នច្រឡំ។ ហើយកន្លែងមិត្ត ស៊ា ហ្នឹង ពីមិត្តរ៉ុម មកហ្នឹងមក បានធ្លាក់មកលើមិត្តស៊ា គេអ្នករៀបចំទៀត។ ចាស នេះបញ្ជាក់បានប៉ុណ្ណឹងឯង។ ដល់និយាយទៅថាម៉េចទៀត ខ្ញុំអត់ដឹង។

**ស៖** បាទ អ្វីដែលខ្ញុំសូមទោស ប្រហែលជាលោកស្រីស្តាប់ខ្ញុំអត់បាន។ អ្វីដែលខ្ញុំឆ្ងល់ មានចម្ងល់ថា ហេតុអីបានជានៅក្នុងឯកសារចម្លើយរបស់លោកស្រីពីមុននោះ លោកស្រីថា មិត្តថន ឬក៏ហៅថា មិត្តរ៉ុម ហ្នឹងដែលជាប្រធានខ្សែក្តាប់លើប្រធានសហករណ៍ទៅវិញ។ ហេតុអីបានជាវាខុសពីឥឡូវ ចម្លើយរបស់លោកស្រីបច្ចុប្បន្ននេះ ទៅវិញ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ជាសំណួរច្រំដែល។ យើងស្តាប់ឮប្អូនប្រាំដងមកហើយ។ អ៊ីចឹងចម្លើយនៅតែដដែលៗ។ អ៊ីចឹងម៉េចក៏មេធាវីមិនទៅមុខទៀតទៅ នៅតែសួរដដែលអ៊ីចឹងៗ។ ដើមបណ្តឹងរដ្ឋប្បវេណី គាត់បានបញ្ជាក់ទំនាក់ទំនងរវាង ស៊ា ហើយនិង ថន ហ្នឹងរួចទៅហើយ។ អ៊ីចឹងគាត់ឆ្លើយហ្នឹងគឺច្បាស់ហើយ។ ហើយមេធាវីនៅតែបន្តសួរដដែលៗ។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីបន្តទៅសំណួរផ្សេង។

[១៥:៤៥:៥៥]

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ឥឡូវមិនថ្វីទេ។ ឥឡូវខ្ញុំសូមបន្តទៅសំណួរមួយទៀត។ លោកស្រីឆ្លើយមុននេះថា នៅចុងឆ្នាំ១៩៧៦ លោកស្រីបានទៅចូលរួមសន្និបាត គឺប្រជុំនៅលើភ្នំគូលេន។ អ៊ីចឹងអាចុងឆ្នាំ១៩៧៦ តើលោកស្រីដឹងថា អាចចងចាំទេ ថាតើក្នុងខែណាមួយដែលចុងឆ្នាំហ្នឹង? លោកស្រីអាចរំឭកការចងចាំបានទេ?

**ឆ៖** ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំអត់បានស្តាប់ឮអ៊ីចឹងទេ ខ្ញុំឮឆ្នាំ៧៦ទេ ខ្ញុំអត់ឮចុង៧៦ទេ។ ជាភាសាបារាំង ខ្ញុំឮអ៊ីចឹង។ អ៊ីចឹងខ្ញុំមិនដឹងថាតើមេធាវីគាត់ស្តាប់ច្រឡំ ឬក៏យ៉ាងម៉េច? ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តាមចម្លើយរបស់គាត់ គឺគាត់ថា៧៦ គាត់មិនបានថាចុងឆ្នាំ៧៦ទេ។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បាទ អ៊ីចឹងឲ្យបានច្បាស់លាស់ សូមលោកស្រីឆ្លើយថា តើពេលណាដែលលោកស្រីទៅចូលរួមសន្និបាតនៅភ្នំគូលេនហ្នឹង? តើខែណា ឆ្នាំណា?

[១៥:៤៧:២៦]

**លោកស្រី ម៉ុំ វុន៖**

**ឆ៖** ទៅចូលរួមមហាសន្និបាតហ្នឹង គឺប្រាប់ថា៧៦ហើយតើ មានឆ្នាំណា ខែណាទៀត។ ខែខ្ញុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អត់ដឹងទេ ខ្ញុំដឹងតែ៧៦ ឆ្នាំ១៩៧៦។ ខ្ញុំដឹងតែប៉ុណ្ណឹងឯង ព្រោះខែបារាំង ខែខ្មែរអី វាពិបាកណាស់ ខ្ញុំមិនដែលបានគិតថាអ៊ីចុះទេ។ ប៉ុន្តែដឹងថា៧៦ហ្នឹង ទៅចូលរួមបណ្ដោយ។ រឿងខែ ខ្ញុំអត់ចាំ។

**ស៖** តើប្រហែលជាប៉ុន្មានខែ ក្រោយពីលោកស្រីរៀបការនោះ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

សូមលោកស្រីកុំអាលទាន់ឆ្លើយ! ចាំមីក្រូហ្វូនប្រតិបត្តិការសិន។

**លោកស្រី មុំ វុន៖**

**ឆ៖** ទៅតាមដែលខ្ញុំស្មានថា ប្រហែលជាបីខែ ដែលបានទៅធ្វើមហាសន្និបាតនៅកន្លែងនោះ។ ប៉ុន្តែដឹងក្នុងឆ្នាំ៧៦ អារឿងខែខ្ញុំអត់ចាំទេ ខ្ញុំដឹងថា គ្រាន់តែខ្ញុំស្មានថា ប្រហែលជាបីខែ ដែលទៅធ្វើមហាសន្និបាត។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បាទ អរគុណលោកស្រី។ ខ្ញុំចង់បញ្ជាក់ចំណុចមួយទៀត។ អំមិញ មុននេះលោកស្រីឆ្លើយថា លោកស្រីដឹងថាក្នុង៦០គូហ្នឹង គេចាប់បង្ខំទាំងអស់គ្នា។ អ៊ីចឹងខ្ញុំចង់ដឹងថា ហេតុអីបានជាលោកស្រីដឹងថា ៦០គូហ្នឹងគេចាប់បង្ខំទាំងអស់គ្នា?

[១៥:៤៨:១៥]

**ឆ៖** ចាស បានជាខ្ញុំដឹងថា គេចាប់បង្ខំទាំងអស់គ្នា ព្រោះគូភាគីដែលរៀបការនឹង៦០គូនោះ សុទ្ធតែយំទាំងអស់ យំទាំងអស់។ មកឈរជុំគ្នាយំទាំងអស់ ទាល់តែពួកគេមកដល់ បាននាំគ្នាជូតទឹកភ្នែកហើយ ឈប់យំ។ ចាំគេហៅដាក់តម្រៀបជួរគ្នាទៅ។ អត់មានអ្នកណាស្ម័គ្រចិត្តមួយទេ។ ៦០គូនោះ ជីដូនជីតាណាដែលរៀបការ៦០គូម្ដងនោះ បើមិនយំទេ ហួសពេក។ ទាំងខ្ញុំទាំងគេ យំតែទាំងអស់គ្នាហ្នឹងឯង មិនថាមេម៉ាយ មិនថាក្រមុំអីទេ យំតែទាំងអស់ហ្នឹង។ ណាមួយមិនស្គាយខ្លួន មិនមានសួរម៉ែប្រាប់ម៉ែមួយម៉ាត់ផង វាមានច្បាប់អី សូម្បីតែចំណុចមួយអក្សរមួយអង្គអី មានច្បាប់សុំពីម៉ែឪមករៀបការឯណាក៏គ្មាន ចាប់ដាក់ ចាប់ដាក់ស្រេចតែនឹងអំពើចិត្តដែលបានធ្វើនោះ។ អាកន្លែងត្រង់ណោះហើយដែលយំនោះ យំទាំងអស់គ្នា អត់មាននេះទេ។ មកជុំគ្នាទាំង៦០នាក់ហ្នឹងយំមើលមុខគ្នាបណ្ដោយទៅ។

**ស៖** សូមទោសលោកស្រីដោយសារពេលវេលា ខ្ញុំសូមកាត់លោកស្រី។ ហើយខ្ញុំចង់បញ្ជាក់ទៀត លោកស្រីថាឃើញពីរគូដែលគាត់អត់ព្រមរៀបការហ្នឹង គេបានយកទៅសម្លាប់ហ្នឹង។ អ៊ីចឹងតើ

ពីរគូហ្នឹងឈ្មោះអីគេខ្លះទៅលោកស្រី?

**ឆ៖** ពីរគូហ្នឹងមួយឈ្មោះមិត្តថុល មួយឈ្មោះមិត្តអ៊ិន គាត់អត់ព្រមរៀបការទេ គាត់សុខចិត្តស្លាប់។ ដល់ពួកខ្ញុំ ៦០គូនោះឃើញគំរូហ្នឹងហើយ ការទៅទាំងអស់គ្នា ប្រយ័ត្នងាប់។ បើយើងមិនការទេ ដឹងតែងាប់ហើយ គ្មានរស់ទេ។ វាឃើញគំរូស្រេចទៅហើយ មានតែប៉ុណ្ណឹងទេ ពីរឈ្មោះពីរនាក់ហ្នឹងឯងដែលរឹងទទឹងមិនព្រមរៀបការទេ។

[១៥:៥១:០៦]

**ស៖** បាទ ឥឡូវខ្ញុំចង់បញ្ជាក់ចំណុចលោកស្រីមួយ លោកស្រីបានអះអាងថា ប្ដីលោកស្រីមុនហ្នឹងគាត់អត់បានធ្វើអីទេ គាត់ធ្វើស្រែ ឡើងត្នោត។ ប៉ុន្តែនៅក្នុងចម្លើយរបស់លោកស្រីដែលនៅអង្គការ ធី.ភី.អូ ឯកសារលេខ E3/7234 ត្រង់ ERN ជាភាសាខ្មែរមានលេខ 01003333, អង់គ្លេសមានលេខ 01077095, បារាំងមានលេខ 01030450។ ខ្ញុំសូមដកស្រង់៖ “ឪពុកម្ដាយក៏សម្រេចចិត្តលើកនាងខ្ញុំឲ្យទៅគេ គាត់ជាគ្រូបង្រៀនចំណេះទូទៅក្នុងឆ្នាំ១៩៦៤ បានរៀបការ។ ពេលនោះខ្ញុំទើបតែមានអាយុ ១៦ឆ្នាំ។”

មួយទៀតប្ដីរបស់លោកស្រីឈ្មោះ តាន់ ហ៊ុំង ចម្លើយរបស់លោកស្រីនៅក្នុងទម្រង់បែបបទព័ត៌មានពីជនរងគ្រោះគឺឯកសារ E3/6307 ត្រង់ERN ជាភាសាខ្មែរមាន 00532025, ជាភាសាបារាំងមានលេខ 01137822, ជាភាសាអង់គ្លេសមានលេខ 01168543។ លោកស្រីបានបញ្ជាក់ថា៖ “នៅមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសារខ្ញុំរស់នៅក្នុងភូមិសង្កែមានជ័យ ឃុំកំពង់ក្ដី ស្រុកជីក្រែង ខេត្តសៀមរាប មុខរបរធ្វើស្រែ ចម្ការ។ ចំណែកប្ដីខ្ញុំឈ្មោះ តាន់ ហ៊ុំង ភេទប្រុស អាយុ៤៧ឆ្នាំ ជាទាហាន លន់ នល់។”

អ៊ីចឹងឥឡូវចម្លើយរបស់លោកស្រីមានបីដែលខុសគ្នា។ បច្ចុប្បន្នលោកស្រីថា ប្ដីលោកស្រីគឺឡើងត្នោត ធ្វើស្រែ តែនៅក្នុងចម្លើយនៅអង្គការ ធី.ភី.អូ គឺលោកស្រីបញ្ជាក់ថា គាត់ជាគ្រូបង្រៀន។ ហើយនៅក្នុងចម្លើយបំពេញបែបបទ ទម្រង់បំពេញបែបបទលោកស្រីថា គាត់ជាទាហាន លន់ នល់។ អ៊ីចឹងតើចម្លើយទាំងអស់នេះ ហេតុអីបានជាខុសគ្នាទាំងបីលើកបែបនេះបាទ?

[១៥:៥៣:៤២]

**ឆ៖** ចាស ចម្លើយទាំងបី ទាំងពីរដែលបានខុសគ្នានេះ គឺថាដែលគេធឹកគេអួតអាងខ្លួនគេ គេថាគេជាគ្រូបង្រៀន ហើយតែតាមការពិតឡើងត្នោតសោះ។ ហើយទាហាន លន់ នល់ នោះកាលណា

ស្រវឹង ខ្ញុំចង់ទៅធ្វើទាហាន លន់ នល់ អាកន្លែងនេះៗបានពាក្យគ្រូបង្រៀននេះ ពាក្យ ទាហាន លន់ នល់ នេះបានពាក្យពីអាកន្លែងផឹកហ្នឹងឯង ព្រោះប្ដីខ្ញុំឡើងត្នោតទេ អត់មានគ្រូបង្រៀន អត់មានៗទាហាន លន់ នល់ អីទេ។

**ស៖** បាទ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់មូលហេតុច្បាស់ជាងហ្នឹងបន្តិចទៀត ព្រោះលោកស្រីបាន ឆ្លើយអំមិញហ្នឹងថា ពេលដែលផឹកគាត់ប្រាប់ថាគ្រូបង្រៀន ហើយពេលដែលស្រវឹងគាត់ប្រាប់ថា ជា ទាហាន។ ប៉ុន្តែនៅក្នុងចម្លើយរបស់លោកស្រីគឺអត់បានបញ្ជាក់ថា ពេលដែលគាត់ស្រវឹងអីៗទេ គឺលោក ស្រីបញ្ជាក់ពីមុខរបររបស់ប្ដីលោកស្រីតែម្ដង គឺជាគ្រូបង្រៀនចំណេះដឹងទូទៅក្នុងឆ្នាំ១៩៦៤។ ហើយ ឯកសារមួយទៀតលោកស្រីបញ្ជាក់ថា គឺជាទាហាន លន់ នល់។ អ៊ីចឹងខ្ញុំចង់ឲ្យលោកស្រីជួយបញ្ជាក់ ឲ្យបានច្បាស់បន្តិច ដើម្បីជាផលប្រយោជន៍យុត្តិធម៌?

**ឆ៖** សូម្បីតែចម្លើយឆ្លើយបញ្ជាក់ទៅយ៉ាងណា ក៏ខ្ញុំដឹងថាជាប្ដីថាឡើងត្នោតតែប៉ុណ្ណឹងទេ និង ធ្វើស្រែ។ ដល់ទាហាន លន់ នល់ នោះ ពួកគេអ្នកចងក្រងគេថាទាហាន លន់ នល់ ទៅធ្វើទាហាន លន់ នល់ គ្រូបង្រៀន អើប្ដីអញគ្រូបង្រៀនមែនហើយហាង គ្រូបង្រៀនគ្រៀវជ្រូកទេ ខ្ញុំនិយាយថាអ៊ីចឹងឯង។ មកហើយដល់ខ្ញុំតែមកនិយាយនៅកន្លែងនោះ ក៏ខ្ញុំនិយាយពាក្យដូចអ៊ីចឹងដែរ ប៉ុន្តែទៅតាមការពិតប្ដីខ្ញុំ ឡើងត្នោតមែន កន្លែងដែលថាគ្រូបង្រៀនគ្រូអីគឺខ្ញុំអត់នេះទេ ខ្ញុំដឹងតែប្ដីខ្ញុំឡើងត្នោតមួយមុខប៉ុណ្ណឹងឯង។

[១៥:៥៥:៣៨]

**ស៖** បាទ លោកស្រី ឥឡូវខ្ញុំបន្តទៅមុខទៀត។ កាលពីមុននេះ លោកស្រីបានបញ្ជាក់ថាប្ដីមុន របស់លោកស្រី គឺលោកស្រីឆ្លើយពីពេលព្រឹកថា ប្ដីមុនរបស់លោកស្រីត្រូវបានខ្មែរក្រហមចាប់យកទៅ ដោយសារគាត់អួតថា ពេលស្រវឹងស្រាអួតថាជាទាហាន លន់ នល់។ ប៉ុន្តែបើពិនិត្យទៅលើឯកសារ ចម្លើយរបស់លោកស្រីដដែលនៅក្នុងឯកសារ E3/7234 ដែលលោកស្រីបានផ្ដល់ចម្លើយនៅអង្គការ ធី. ភី.អូ គឺឯកសារ E3/7234 ដែលមានលេខ ERN ជាភាសាខ្មែរគឺលេខ 00 -- សូមទោស 01003334, ជាភាសាអង់គ្លេសមានលេខ 01077095, ជាភាសាបារាំងមានលេខ 01030451។ លោកស្រីបាន ឆ្លើយថា៖ "នៅក្នុងឆ្នាំ១៩៧០ នៅពេលដែលមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ ខ្ញុំក៏បាន វិលត្រឡប់មកស្រុកកំណើតវិញ។ លុះដល់ឆ្នាំ១៩៧២ ដោយសារការរស់នៅមិនចុះសម្រុង ប្ដីខ្ញុំគាត់ទៅ មានស្រីថ្មី ហើយក៏បានលែងលះគ្នា ដោយបន្សល់ទុកនូវកូនចំនួនប្រាំបីនាក់។"

អ៊ីចឹងខ្ញុំចង់ដឹងឲ្យបានច្បាស់ថា ហេតុអីបានជាចម្លើយកាលពីឆ្នាំ២០១០ របស់លោកស្រីនៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អង្គការ ធី.ភី.អូ លោកស្រីថាប្ដីទី១របស់លោកស្រីគឺលែងលះគ្នា ប៉ុន្តែដល់ឥឡូវនេះ លោកស្រីបញ្ជាក់ថាប្ដីលោកស្រីត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់។ សូមលោកស្រីបញ្ជាក់មើលថា ហេតុអីបានជាផ្ទុយគ្នាបែបនេះ?

**ឆ៖** ចាស ប្ដីខ្ញុំ--

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[១៥:៥៧:៤៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

សូមអរគុណលោកប្រធាន។ ជាភាសាបារាំងគឺមានភាពខុសគ្នាយ៉ាងខ្លាំង នៅក្នុងឯកសារដែលបានដកស្រង់នេះ និយាយអំពីការបែកបាក់។ អ៊ីចឹងវាមិនមែនមានន័យថាជាការលែងលះទេ។ អ៊ីចឹងអាចសូមឲ្យមេធាវីការរៀបចំសំណួរឡើងវិញ ព្រោះថាក្នុងជាភាសាបារាំង និងអង់គ្លេសនោះ គេអត់មាននិយាយពីការលែងលះទេ គ្រាន់តែនិយាយអំពីការបែកបាក់គ្នា។

**លោកស្រី ដូរីន ជិន៖**

សូមអភ័យទោស គឺថានៅក្នុងឯកសារភាសាអង់គ្លេសគឺគេប្រើប្រាស់ពាក្យ "លែងលះ"។ ដូច្នេះហើយទើបយើងប្រើពាក្យ "លែងលះ" នៅទីនេះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប្រសិនបើអ៊ីចឹងយើងពិនិត្យមើលឯកសារខ្មែរទៅដើម្បីឲ្យវាដឹងច្បាស់។

**លោក លីវ សុវណ្ណា៖**

បាទ អ៊ីចឹងតើឲ្យអ្នកណាដែលអាន ព្រោះឯកសារហ្នឹងគឺមានលេខ E3/7234, ERN ជាភាសាខ្មែរ--

[១៥:៥៨:៤៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអានឯកសារហ្នឹងជាខ្មែរ ជាភាសាខ្មែរបាទ។

**លោក លីវ សុវណ្ណា៖**

បាទ អ៊ីចឹងខ្ញុំបាទ សូមអនុញ្ញាតដកស្រង់ឡើងវិញ។ "លុះដល់ឆ្នាំ១៩៧២ ដោយសារការរស់នៅមិនចុះសម្រុង ប្តីខ្ញុំគាត់ទៅមានស្រីថ្មី យើងក៏បានលែងលះគ្នា ដោយបន្សល់ទុកនូវកូនចំនួនប្រាំបីនាក់។" សូមចប់ការដកស្រង់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយនឹងសំណួរនេះ!

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស នៅក្នុងឆ្នាំ១៩៧២ ដែលមានការរកាំរកូសក្នុងគ្រួសារដែលបែកបាក់លែងលះគ្នា លែងលះគ្នាទៅបានតែកន្លះខែទេ ប្តីខ្ញុំមកសុំជា ជាមួយខ្ញុំវិញ។ នេះតាមដែលខ្ញុំដឹងខ្លួនខ្ញុំ ដែលថាខ្ញុំបែកបាក់ហ្នឹង គឺថាគ្រាន់តែលែងគ្នាមួយរយៈដែលខ្ញុំខឹងថាមានស្រីហើយ គេខឹងខ្ញុំ ក៏គេទៅ ដល់រួចហើយគេវិលមកជា ជាមួយខ្ញុំវិញ បាននៅរហូតដល់សព្វថ្ងៃ -- នៅរហូតដល់៧៥ហ្នឹង។ លែងគ្នាហើយ មកយកគ្នាវិញ។ កន្លែងនេះ បាននៅដល់ឆ្នាំ៧៥ហ្នឹង។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដកស្រង់បន្ត ពីទំព័រនេះដដែល។ ក្នុងលោកស្រីបានឆ្លើយបន្តទៀតថា៖ "បន្ទាប់ពីលែងលះប្តីទី១ ខ្ញុំទទួលការរងទុក្ខរហូត ដោយសារមានកូននៅក្នុងបន្ទុកចំនួនប្រាំបីនាក់។ ខ្ញុំពិតជាមានការលំបាកណាស់ដែលចិញ្ចឹមកូនតែម្នាក់ឯង។" អ៊ីចឹងចំណុចនេះ វាបញ្ជាក់បានថាលោកស្រីអត់បានចិញ្ចឹមកូនតែម្នាក់ឯង អត់មានឃើញលោកស្រីរំលេចថា ប្តីលោកស្រីមកវិលត្រឡប់មករកលោកស្រីវិញទេ។ អ៊ីចឹងសូមលោកស្រីបញ្ជាក់មើលចំណុចនេះ បាទ។

**ឆ៖** ចាស។ ទោះបីជាបញ្ជាក់តែយ៉ាងណាក៏ដោយ ប៉ុន្តែក្រុមគ្រួសារខ្ញុំដែលបែកបាក់គ្នាទៅ ខ្ញុំចិញ្ចឹមកូនមួយរយៈហ្នឹង ចិញ្ចឹមតែខ្លួនខ្ញុំមែន ប៉ុន្តែដល់គាត់វិលមកជួបវិញហើយ អត់មានបែកបាក់ទៀតទេ ខ្ញុំនៅជុំក្រុមគ្រួសារវិញ។ អាអង្កាល់ដែលយើងនិយាយ និយាយដែលអត់ទាន់បែកបាក់ អ៎! អាបែកបាក់។ ដល់អាមកវិញ អត់បែកបាក់ មកជួបជុំគ្នាវិញ។ នេះខ្ញុំបញ្ជាក់។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសមស្របនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសកិច្ចដំណើរនីតិវិធីសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ បញ្ចប់ ហើយសវនាការនឹងលើកបន្តធ្វើនៅថ្ងៃចន្ទ ទី

១៩ ខែកញ្ញា ឆ្នាំ២០១៦ ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

សវនាការនៅថ្ងៃចន្ទ សប្ដាហ៍ក្រោយ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-251 ពាក់ព័ន្ធនឹងអង្គហេតុបទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍ តាមរយៈប្រព័ន្ធសោតទស្សន៍ជាមុន ដោយសារតែបញ្ហាបច្ចេកទេស និងកាលវិភាគ ដែលបានកំណត់រួចហើយ។ បន្ទាប់មក អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បញ្ចប់។ ដូច្នេះសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកស្រី មុំ វុន ដំណើរការស្ដាប់សក្ខីកម្មរបស់លោកស្រីនៅពេលនេះមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីឲ្យមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃចន្ទសប្ដាហ៍ក្រោយទៀត។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី មុំ វុន ត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ និងអញ្ជើញគាត់ត្រឡប់មកវិញ រួមចូលរួមសវនាការ នៅថ្ងៃចន្ទ ទី១៩ ខែកញ្ញា ឆ្នាំ២០១៦។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.កវិញ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការវិញ នៅថ្ងៃចន្ទ ទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

អញ្ជើញសម្រាកចុះ៕

*(សវនាការអសាធារណៈផ្អាកនៅម៉ោង ១៦:០៣ នាទី)*

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*